**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវព្រហ្មទណ្ឌ<br>និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

ស្រាវជ្រាវពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក ឈីន ម៉ាណែត**

**កញ្ញា បេត យ៉ារី**

ណែនាំដោយ

លោកគ្រូ **ម៉ៅ មុណ្ណា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# **សេចក្ដីថ្លែងអំណរគុណ**

ខ្ញុំបាទ **ឈីន ម៉ាណែត** និងនាងខ្ញុំ **បេត យ៉ារី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២០-២០២៤។

**សូមគោរពលំឱនកាយវាចាចិត្ត ដើម្បីបង្ហាញនូវអំពីមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

លោកឪពុក **ឈីន វាសនា** អ្នកម្ដាយ **ឈីន ម៉ៃ**

លោកឪពុក **ប៊ិន ចេតនា** អ្នកម្ដាយ **អឿ ស៊ីនីម**

យើងខ្ញុំសូមសម្ដែងនូវការគោរព និងដឹងគុណដល់លោកអ្នកមានគុណទាំងទ្វេដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាអប់រំប្រៀនប្រដៅ ផ្ដល់ដំបូន្មានល្អៗ និងលះបង់ទាំងពេលវេលា ថវិកាដែលកើតចេញពីញើសឈាមដែលបានខំប្រឹងទាំងកម្លាំងកាយ កម្លាំងចិត្ត និងបញ្ញាស្មារតី សម្រាប់ជួយទំនុកបម្រុងគ្រប់បែបយ៉ាងដើម្បីឱ្យកូនៗមានអនាគតរុងរឿង។ ទន្ទឹមនេះលោកទាំងទ្វេតែងតែលើកទឹកចិត្តដល់កូនៗ ឱ្យខិតខំប្រឹងប្រែងអំណត់អត់ធ្មត់ និងយកចិត្តទុកដាក់ក្នុងការសិក្សា រៀនសូត្រ ដើម្បីក្លាយជាពលរដ្ឋល្អក្នុងសង្គម ដើម្បីជាធនធានក្នុងការចូលរួមចំណែកអភិវឌ្ឍប្រទេសឱ្យកាន់តែរីកចម្រើន។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** ជាសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោកព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់ ដែលបានដឹកនាំគ្រប់គ្រង មើលការខុសត្រូវ បង្ហាត់បង្រៀន អប់រំទូន្មានទាំងផ្នែកទ្រឹស្ដី និងការអនុវត្ត ជាពិសេសការផ្ដល់គំនិត និងបទពិសោធន៍ល្អៗ ដល់និស្សិតគ្រប់រូប ក្នុងគោលបំណងអភិវឌ្ឍន៍ និងបង្កើនធនធានមនុស្សសម្រាប់អនាគតឱ្យកាន់តែរីកចម្រើនក្នុងសង្គមជាតិ។ ទន្ទឹមនេះដែរ យើងខ្ញុំសូមលំឱនកាយគោរពថ្លែងអំណរគុណយ៉ាងក្រៃលែង ជូនចំពោះ លោកគ្រូ **ម៉ៅ មុន្នីណា** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ការកែតម្រូវ ការចង្អុលបង្ហាញ ដោយផ្ដល់គំនិតយោបល់សម្រាប់ជាគន្លឹះនៃការសិក្សាស្រាវជ្រាវចំពោះការសរសេរសារណារបស់ក្រុមយើងខ្ញុំកន្លងមក រហូតចេញជាផ្លែផ្កាវិលេចស្នាដៃនេះឡើង។

ជាមួយគ្នានេះដែរ យើងខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយគោរពដឹងគុណដល់បងប្អូនមិត្តភក្តិរួមថ្នាក់ទាំងមូលដែលតែងតែនៅក្បែរផ្ដល់ស្នាមញញឹមលើកទឹកចិត្ត ទាំងបញ្ញាស្មារតី និងឯកសារពិគ្រោះនានាតាមគ្រប់មធ្យោបាយស្រាវជ្រាវ និងលទ្ធភាពដែលអាចធ្វើទៅបាន។ យើងខ្ញុំក៏សូមរំលឹកដឹងគុណយ៉ាងធំធេងដល់បុព្វបុរសដូនតាខ្មែរ រួមទាំងថ្នាក់ដឹកនាំគ្រប់ជំនាន់ ដែលបានលះបង់ ខិតខំតស៊ូចេញពីចិត្ត ដើម្បីជំរុញឱ្យប្រទេសជាតិរីកចម្រើន និងបានបន្សល់ទុក វប្បធម៌ អរិយធម៌ សិល្បៈ រួមទាំងមរតកប្រវត្តិសាស្ត្រផ្សេងជាច្រើនទៀតដល់កូនចៅជំនាន់ក្រោយងាយស្រួលសិក្សាស្រាវជ្រាវ និងរៀនសូត្របន្ត។

# **អារម្ភកថា**

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ៤ឆ្នាំ កន្លងមកនេះ យើងខ្ញុំទទួលបានទាំងចំណេះដឹង ទាំងបទពិសោធន៍ដែលទាក់នឹងវិស័យគតិយុត្តយ៉ាងទូលំទូលាយ ដោយកើតចេញពីការខិតខំប្រឹងប្រែងក្នុងការសិក្សាកន្លងមក ដើម្បីទទួលបានចំណេះដឹងនិងជំនាញ ពីលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំជានិស្សិតត្រូវបានលើកទឹកចិត្ត និងទទួលការអនុញ្ញាតពីសាកលវិទ្យាល័យដើម្បីសរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទ "**ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល**"។

មូលហេតុដែលក្រុមយើងខ្ញុំបានរំលេចឡើងការស្រាវជ្រាវប្រធានបទនេះ ដោយសារចង់យល់ដឹងឱ្យកាន់តែស៊ីជម្រៅទាក់ទងទៅនឹង ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ផ្ដោតសំខាន់ទៅលើសិទ្ធិ និងករណីកិច្ចរបស់រូបវន្តបុគ្គល ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ រួមទាំងនីតិវិធីអនុវត្តទៅលើនីតិជន និងអនីតិជនដែលធ្វើយ៉ាងណាធានាសុវត្ថិភាព និងផលប្រយោជន៍របស់នីតិជន និងអនីតិជន។ លើសពីនេះទៅទៀត សារណានេះអាចលេចចេញជារូបរាងឡើងមកបានក៏ដោយសារ មានការណែនាំ ជួយជ្រោមជ្រែងពីសំណាក់ **លោកគ្រូ ម៉ៅ មុន្នីរ៉ា** ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ ជួយចង្អុលបង្ហាញផ្លូវក្នុងការសរសេរសារណានេះបញ្ចប់ដោយជោគជ័យ។

ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និងជាអ្នករៀបរៀងចងក្រងសៀវភៅនេះឡើង បើមានការខុសឆ្គងដោយប្រការណាមួយទៅលើអក្ខរាវិរុទ្ធ ពាក្យពេចន៍ ឃ្លោងឃ្លា និងអត្ថន័យ សូមខន្តីអភ័យទោសរាល់កំហុសខុសឆ្គងក្នុងការសរសេរសារណានេះឡើង។ ទោះបីយើងខ្ញុំបានព្យាយាមត្រួតពិនិត្យជាច្រើនលើកច្រើនសារ ក៏អាចនៅតែមានចំណុចខ្វះខាតប្រការណាមួយដោយអចេតនា។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងក្លាយជាឧបករណ៍ដ៏មានគុណប្រយោជន៍ រួមចំណែកលើកកម្ពស់វិស័យព្រហ្មទណ្ឌ ព្រមទាំងផ្ដល់វិភាគទានខាងពុទ្ធិ ដល់ការយល់ដឹង ការរៀនសូត្រ និងការសិក្សាស្រាវជ្រាវរបស់និស្សិត អ្នកស្រាវជ្រាវ បញ្ញវន្ត និងសាធារណជនទូទៅដែរ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ........ ១

៣. គោលបំណងនៃការស្រាវជ្រាវ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ........ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ........ ២

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........ ៣

**ជំពូកទី១**

**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល**

**ផ្នែកទី១៖ សញ្ញាណទូទៅ**........ ៤

**១.១. គោលការណ៍នីត្យានុកូលភាព**........ ៤

១.១.១. បទល្មើស........ ៥

១.១.២. ទោស........ ៦

១.១.៣. បច្ច័យ........ ៦

ក. គោលការណ៍បកស្រាយច្បាប់ព្រហ្មទណ្ឌ........ ៧

ខ. លក្ខណៈទូទៅ........ ៧

គ. អង្គហេតុ........ ៨

១.១.៤. ធាតុផ្សំនៃបទល្មើស........ ៩

ក. ធាតុនីត្យានុកូល ឬធាតុច្បាប់........ ១០

ខ. ធាតុសត្យានុម័ត ឬអំពើប្រព្រឹត្ត........................................................................................ ១១
គ. ធាតុអត្តនោម័ត ឬស្ថានភាពផ្លូវចិត្ត.................................................................................... ១២
១.១.៥. គោលការណ៍មិនប្រតិសកម្ម.......................................................................................... ១៣
១.១.៦. ច្បាប់ព្រហ្មទណ្ឌស្រាលជាង.......................................................................................... ១៤
១.១.៧. ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ........................................................................ ១៤
១.១.៨. ឯកត្តកម្មនៃទោស...................................................................................................... ១៥
១.១.៩. ការប្រកាសទោស....................................................................................................... ១៦
**ផ្នែកទី២៖ លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល**..................... ១៦
**២.១. ប្រភេទរូបវន្តបុគ្គល**..................................................................................................... ១៦
២.១.១. នីតិជន..................................................................................................................... ១៧
ក. ការទទួលខុសត្រូវព្រហ្មទណ្ឌ.......................................................................................... ១៧
ខ. អានុភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ.......................................................................... ១៨
២.១.២. អនីតិជន.................................................................................................................. ១៩
ក. ការទទួលខុសត្រូវព្រហ្មទណ្ឌ.......................................................................................... ១៩
ក.១. អនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ........................................................ ២០
ក.២. អនីតិជនមានអាយុក្រោម ១៤ឆ្នាំ.................................................................................. ២១
ខ. ប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ............................................................................ ២២
គ. ការអនុវត្តទោស.......................................................................................................... ២៤
គ.១. មូលទោស.............................................................................................................. ២៥
គ.២. ទោសបន្ថែម........................................................................................................... ២៦
គ.៣. ទោសជំនួស............................................................................................................ ២៧
**២.២. បុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ**.................................................................................. ២៨

២.២.១. ចារី........ ២៨
២.២.២. សហចារី........ ២៨
២.២.៣. អ្នកផ្តើមគំនិត........ ២៩
២.២.៤. អ្នកសមគំនិត........ ៣០

## ជំពូកទី២

## ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

**ផ្នែកទី១៖ មូលហតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ**........ ៣១
**១.១. មូលហេតុអត្តនោម័ត**........ ៣២
១.១.១. ជនវិបល្លាសស្មារតី........ ៣២
ក. វិបល្លាសស្មារតីទាំងស្រុង........ ៣៣
ខ. វិបល្លាសស្មារតីដែលបន្ថយការយល់ដឹង........ ៣៣
គ. វិបល្លាសស្មារតីដោយការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន........ ៣៤
១.១.២. អានុភាពនៃកម្លាំង ឬការបង្ខំ........ ៣៥
ក. លក្ខខណ្ឌនៃកម្លាំង ឬការបង្ខំ........ ៣៦
ខ. ប្រភេទនៃកម្លាំង ឬការបង្ខំ........ ៣៦
ខ.១. កម្លាំងបង្ខំលើរូបរាងកាយ........ ៣៦
ខ.២. កម្លាំងបង្ខំលើផ្លូវចិត្ត........ ៣៧
**ផ្នែកទី២៖ មូលហេតុសត្យានុម័ត**........ ៣៨
**២.១. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ**........ ៣៩
២.១.១. ច្បាប់........ ៣៩
២.១.២. អាជ្ញាធរ........ ៣៩
ក. អាជ្ញាធរស្របច្បាប់........ ៤០

ខ. បញ្ហាស្របច្បាប់.......................................................................................... ៤០

២.១.៣. ការការពារស្របច្បាប់.................................................................................. ៤១

ក. លក្ខខណ្ឌ.................................................................................................... ៤២

ខ. ការឈ្លានពាន.............................................................................................. ៤២

គ. ការការពារការឈ្លានពាន............................................................................... ៤៣

២.១.៤. សច្ចធារណ៍.................................................................................................. ៤៤

២.១.៥. ស្ថានភាពចាំបាច់........................................................................................ ៤៥

ក. ភាពអាសន្នគ្រោះថ្នាក់.................................................................................... ៤៦

ខ. ការការពារជាការចាំបាច់................................................................................. ៤៦

គ. វិសមាមាត្រ.................................................................................................... ៤៧

**២.២. កត្តាផ្សេងៗ**.................................................................................................... ៤៨

២.២.១. ជនអាយុក្រោម ១៤ឆ្នាំ.................................................................................. ៤៩

២.២.២. បទដ្ឋានគតិយុត្ត............................................................................................ ៥០

**សេចក្ដីសន្និដ្ឋាន**...................................................................................................... ៥២

**អនុសាសន៍**.............................................................................................................. ៥៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រជាពលរដ្ឋគ្រប់ៗរូបរស់នៅក្នុងសង្គមជាតិ សុទ្ធតែមានសេរីភាពក្នុងការរស់រានមានជីវិត និងសិទ្ធិអាចធ្វើសកម្មភាពបានសព្វបែបយ៉ាងក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ បើទោះមានសិទ្ធិអាចធ្វើអ្វីបានសព្វគ្រប់បែបយ៉ាងក៏ពិតមែន ប៉ុន្តែពុំមានន័យថាអាចធ្វើឡើងដោយមានការបំពានទៅដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ជនណាម្នាក់បានប្រព្រឹត្តសកម្មភាពបំពានទៅលើជនណាម្នាក់ផ្សេងទៀតដោយចេតនាក្តី អចេតនាក្តី ដែលធ្វើឱ្យមានការប៉ះពាល់ដល់សិទ្ធិសេរីភាព ផលប្រយោជន៍អ្នកដទៃមានលក្ខណៈធ្ងន់ធ្ងរ និងបង្កឱ្យមានការប៉ះពាល់ទៅដល់សង្គមជាតិមានការខូចខាតហេដ្ឋារចនាសម្ព័ន្ធ ធ្វើឱ្យប៉ះសណ្តាប់ធ្នាប់សាធារណៈ សង្គមជាតិអសន្តិសុខ និងគ្មានសុវត្ថិភាពក្នុងការរស់នៅ។ ហេតុនេះហើយទើបប្រទេសនីមួយៗ មានការបង្កើតច្បាប់ឡើង ដើម្បីបង្ការទប់ស្កាត់ និងគ្រប់គ្រងក្នុងការធានាបានសុខសន្តិភាព និងការរីកចម្រើន។

ការប្រព្រឹត្តបទល្មើសក្នុងសង្គម ដែលបង្កជាព្យសនកម្មដល់បុគ្គលណាម្នាក់ ឬច្រើននាក់ ដែលបទល្មើសនោះមានចែងក្នុងក្រមព្រហ្មទណ្ឌ បុគ្គលនោះនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ ដោយឡែកបុគ្គលទាំងឡាយដែលបង្កជាព្យសនកម្ម ដោយអំពើរបស់ខ្លួនដោយបុគ្គលនោះគ្រាន់តែការពារពីការឈ្លានពានពីអ្នកដទៃដែលបង្កព្យសនកម្មដល់ខ្លួនយ៉ាងធ្ងន់ធ្ងរ ដែលមិនអាចបញ្ចៀសបាន ដោយបានការពារខ្លួនក្នុងស្ថានភាពនោះ ដោយការប្រើអាវុធ ឬមិនប្រើអាវុធហើយមានភាពសមាមាត្រគ្នាទៅនឹងការឈ្លានពាន ក្នុងស្ថានភាពនោះ បុគ្គលនោះមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

ហេតុនេះ ក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់អំពី "**ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល**"។ ក្រមនេះត្រូវបានអនុវត្តពេលមានភាពអសន្តិសុខនៅក្នុងសង្គម និងផ្តន្ទាទោសបុគ្គលណាដែលបានប្រព្រឹត្តកំហុសខុសឆ្គងផ្ទុយនឹងច្បាប់ចែង។ ក្រមនេះបង្កើតឡើង ក្នុងគោលបំណងដាក់ទណ្ឌកម្មលើបុគ្គលទាំងឡាយណាដែលបង្កឱ្យមានភាពចលាចលក្នុងសង្គម ដើម្បីឱ្យបុគ្គលនោះរាងចាល និងកែប្រែកំហុសដែលខ្លួនបានប្រព្រឹត្តខុសឆ្គងពីមុនមក រួចអភិវឌ្ឍន៍ខ្លួនឱ្យចូលមករស់នៅក្នុងសង្គម ប្រែក្លាយជាពលរដ្ឋល្អ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឱ្យកាន់តែមានភាពងាយស្រួលក្នុងការបកស្រាយប្រធានបទមួយនេះកាន់តែច្បាស់លាស់ ក្រុមយើងខ្ញុំបានលើកយកចំណោទបញ្ហាដែលទាក់ទងនឹងមូលហេតុអ្វីត្រូវមានការទទួលខុសត្រូវព្រហ្មទណ្ឌ និងមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល យកមកធ្វើការចោទជាសំណួរ ដូចខាងក្រោម៖

- តើបុគ្គលរូបណាដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ?
- តើក្រមព្រហ្មទណ្ឌផ្តន្ទាទោសនីតិជន និងអនីតិជនយ៉ាងដូចម្តេច?
- ចំពោះអនីតិជន តើក្រមព្រហ្មទណ្ឌ បានកំណត់ពីការរួចផុតពីការទទួលខុសត្រូវដែរ ឬទេ?

- តើបុគ្គលរូបណាដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ?
- មូលហេតុអ្វីខ្លះដែលក្រមព្រហ្មទណ្ឌឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ?

ដោយសារតែមានចំណោទបញ្ហាគតិយុត្តខាងលើនេះហើយ ទើបយើងខ្ញុំបានសម្រេចចិត្តសរសេរសារណា បញ្ចប់ការសិក្សាលើប្រធានបទ"**ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល**" ក្នុងគោលបំណងដោះស្រាយរាល់ចម្ងល់ ដែលបានចោទសួរខាងលើនេះ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវប្រធានបទនេះ គោលបំណងសំខាន់ក្នុងការស្រាវជ្រាវលើបញ្ហាគតិយុត្ត នៃក្រមព្រហ្មទណ្ឌដើម្បីយល់ដឹងឱ្យកាន់តែច្បាស់បន្ថែមទៀត សម្រាប់ជាផលប្រយោជន៍ដ៏មានតម្លៃក្នុងការស្វែងរកដំណោះស្រាយឱ្យបានត្រឹមត្រូវ ដោយផ្អែកលើបទល្មើសដែលបានកើតឡើងជាក់ស្តែង និងចងក្រងទុកជាឯកសារមួយដែលមានតម្លៃ និងមានប្រយោជន៍យ៉ាងសំខាន់សម្រាប់អ្នកច្បាប់ទាំងអស់ ក៏ដូចជានិស្សិតជំនាន់ក្រោយក្នុងការងាយស្រួលសិក្សាស្រាវជ្រាវ។ ស្នាដៃដែលបានស្រាវជ្រាវនេះ បានលេចចេញជាសមិទ្ធផលដ៏ល្អមួយ រួមចំណែកក្នុងការលើកស្ទួយវិស័យច្បាប់នៅព្រះរាជាណាចក្រកម្ពុជាឱ្យមានការរីកចម្រើនទៅមុខយ៉ាងរលូន។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅនឹងបញ្ហាខាងលើដែលយើងខ្ញុំបានស្រាវជ្រាវ ការសរសេរសារណាបានលេចចេញជារូបរាងមួយនេះឡើងមក។ ក្នុងការសិក្សាស្រាវជ្រាវនេះដែរ យើងខ្ញុំបានផ្តោតតែលើច្បាប់ដែលមានចែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ក្នុងនោះរួមមាន រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងច្បាប់ស្តីវិសោធនកម្មរដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ច្បាប់ស្តីពីសិទ្ធិកុមារ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន រួមទាំងឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត សម្រាប់ដាក់បញ្ចូលក្នុងអត្ថបទសរសេរសារណាទាំងមូល។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃសារណាគឺប្រធានបទ "**ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល**" ដែលជាសមិទ្ធផលមួយដ៏ធំសម្រាប់យើងខ្ញុំដែលជាអ្នករៀបចំចងក្រងដោយផ្ទាល់។ ប្រធានបទមួយនេះ នាំឱ្យមានការយល់ដឹងកាន់តែច្បាស់លាស់ និងទូលំទូលាយ អំពីមូលហេតុនៃការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល សម្រាប់ចែករំលែកជាស្នាដៃមានតម្លៃមួយសម្រាប់ឱ្យនិស្សិតជំនាន់ក្រោយបង្កើនចំណេះដឹងកាន់តែរីកចម្រើន។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវរៀបចំសារណាមួយនេះឡើង កើតចេញពីការដកស្រង់ចេញពីឯកសារច្បាប់ផ្សេងៗ ដែលបានចងក្រង និងសិក្សាស្រាវជ្រាវពីសារណារបស់សិស្សច្បងជំនាន់មុនៗមួយចំនួន រួមទាំងតាមប្រព័ន្ធអ៊ីនធឺណេតមួយចំនួនដែរ។ ជាពិសេសទទួលបានការសហការក្នុងការពិភាក្សាផ្តល់មតិយោបល់គ្នាទៅវិញទៅមកជាមួយសាស្ត្រាចារ្យណែនាំផ្នែកច្បាប់ព្រមទាំងសៀវភៅច្បាប់មួយចំនួនដែលមានខ្លឹមសារពាក់ព័ន្ធនឹងប្រធានបទមួយនេះ មកចងក្រងជាសារណាមួយបែបតាមវិធីសាស្ត្រពិពណ៌នា និងវិភាគ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះត្រូវបែងចែកជា ២ ជំពូក រួមមាន៖

**ជំពូកទី១៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល**

**ជំពូកទី២៖ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល**

ក្នុងនោះដែរ ជំពូកនីមួយៗមានការបែងចែកជា ២ ផ្នែកធំៗ ផ្សេងទៀតដោយមានការចែកជាចំណងជើងរងជាច្រើនទៀត ដើម្បីជាភស្តុតាងក្នុងការពន្យល់បកស្រាយខ្លឹមសារតាមផ្នែកនីមួយៗ ឱ្យកាន់តែច្បាស់លាស់ថែមទៀត។

# ជំពូកទី១
# ការទទួលខុសត្រូវព្រហ្មទណ្ឌ
# របស់រូបវន្តបុគ្គល

# ជំពូកទី១

# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

## ផ្នែកទី១៖ សញ្ញាណទូទៅ

### ១.១. គោលការណ៍នីត្យានុកូលភាព

គោលការណ៍នេះ ចែងថាបុគ្គលនឹងត្រូវទទួលខុសត្រូវ និងផ្តន្ទាទោស លុះត្រាតែនៅពេលដែលគេប្រព្រឹត្ត អំពើល្មើស ហើយអំពើទាំងនោះទៀតសោតត្រូវបានគេចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌទៅតាមបទបញ្ញានៃច្បាប់ គោលការណ៍មួយនេះជាច្បាប់សារជាតុ (substantive justice)។ យោងតាមមាត្រា៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងយ៉ាងច្បាស់អំពីគោលការណ៍នីត្យានុកូលភាព។ ដោយមាត្រា៣ នៃក្រមនេះបានចែងថា មានតែអំពើ ដែលកើតឡើងជាបទល្មើស នៅពេលណាដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌ ទើបត្រូវផ្តន្ទាទោស ព្រហ្មទណ្ឌបាន។ ដូចនេះហើយមានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែល បទល្មើស ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបត្រូវប្រកាសបាន។[1]

ឧទាហរណ៍៖ បុរស ក ម្នាក់បានលួចកាបូបលុយរបស់ បុរស ខ ដោយហេតុថាបុរស ក ពុំមានប្រាក់គ្រប់ គ្រាន់សម្រាប់ធ្វើការបង់ប្រាក់ឈ្នួលផ្ទះទើបធ្វើឱ្យបុរស ក សម្រេចចិត្តក្នុងការលួចកាបូបលុយរបស់បុរស ខ។ អំពើលួចត្រូវបានកំណត់ថាជាបទល្មើសមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ រាល់អំពើដកហូតទ្រព្យ សម្បត្តិអ្នកដទៃក្នុងគោលបំណងយកមកជាកម្មសិទ្ធិរបស់ខ្លួន ដោយចំពោះក្តី ឬមិនចំពោះក្តីជាអំពើលួច តុលាការអាចប្រកាសទោសពីបទលួចតាមមាត្រាខាងលើ។

គោលការណ៍នីត្យានុកូលភាព ក៏មានចែងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិមាត្រា១៥ នៃកតិកាសញ្ញា ស្តីពីសិទ្ធិប្រជាពលរដ្ឋបានចែងថា៖

១. គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយដែលមិន បានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើ ក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវ ទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។

២. គ្មានបទប្បញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ ចំពោះអំពើ ឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើ ឬការខកខាននោះ ជាបទ ល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ។[2]

[1] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣

[2] សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនៃកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ, មាត្រា១៥

គោលការណ៍នេះក៏មានចែងក្នុងលក្ខន្តិកៈបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ត្រង់មាត្រា២២ កថាខណ្ឌទី១ ដែលបានចែងថា យុត្តាធិការតុលាការត្រូវបានកម្រិតដែនកំណត់ចំពោះបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុតដែលធ្វើឱ្យមានការព្រួយបារម្ភដល់សហគមន៍អន្តរជាតិទាំងមូល។

គោលការណ៍នីត្យានុកូលភាពនេះមានចរិតលក្ខណៈជាបទប្បញ្ញត្តិគ្រឹះនៅក្នុងប្រព័ន្ធ នៃក្រមព្រហ្មទណ្ឌដោយហេតុថា ច្បាប់ព្រហ្មទណ្ឌ គឺបានកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ។ ហើយគោលការណ៍នេះត្រូវបានបែងចែកចេញជា៣ផងដែរគឺ ទោស បទល្មើស និងបច្ច័យ។

**១.១.១. បទល្មើស**

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់នូវគោលការណ៍នីត្យានុកូលភាព។ ដោយបានបញ្ញត្តិថា "មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានតែប៉ុណ្ណោះ ទើបត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌបាន"។[3]

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលើកឡើងថា គ្មានជនណាម្នាក់ត្រូវបានជាប់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយ រាល់អំពើ ឬការធ្វេសប្រហែសណាមួយដែលមិនមែនជាបទល្មើស មាននៅក្រោមច្បាប់ ឬច្បាប់អន្តរជាតិ នៅខណៈពេលដែលអំពើនោះបានប្រព្រឹត្ត។

នីត្យានុកូលភាពនៃបទល្មើសសំដៅទៅលើអំពើណាមួយ ដែលគេអាចចាត់ទុកថាជាបទល្មើសបាន លុះត្រាតែរាល់អំពើនោះមានការចែងទុកជាមុនយ៉ាងច្បាស់លាស់ក្នុងច្បាប់ថាជាបទល្មើស ប្រសិនបើច្បាប់មិនបានចែងទេនោះតុលាការមិនអាចផ្តន្ទាទោសបុគ្គលដែលប្រព្រឹត្តនោះបានឡើយ ហេតុនេះហើយបានជាមានគោលការណ៍មួយកំណត់ថា "គ្មានបទល្មើសណា ដែលច្បាប់មិនបានចែងនោះឡើយ"។[4]

ឧទាហរណ៍៖ បទរំលោភសេពសន្ថវៈ ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ២០០៩ បានបញ្ញត្តិថា ជាការបំពានខាងផ្លូវភេទ គឺជាបទល្មើសរំលោភសេពសន្ថវៈ។

**១.១.២ ទោស**

គោលការណ៍នេះ ជាគោលការណ៍គ្រឹះនៃនីតិព្រហ្មទណ្ឌដើម្បីធានាការអនុវត្តច្បាប់ព្រហ្មទណ្ឌ។ យោងតាមមាត្រា៣ នៃក្រមព្រហ្មទណ្ឌកថាខណ្ឌទី១ នៃក្រមនេះបានចែងថា មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តតែប៉ុណ្ណោះ ទើបអាចត្រូវបានប្រកាសបាន។[5] គោលការណ៍នេះ ទាមទារជាចាំបាច់ក្នុងករណីច្បាប់ពុំមានកំណត់បទល្មើស និងចែងអំពីទោសណាមួយ នៅក្នុង

[3] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥ កថាខណ្ឌទី១

[4] កតិកាសញ្ញាអន្តរជាតិស្តីពីពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា៥ កថាខណ្ឌទី១

[5] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣

ពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត នោះពុំអាចចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយឡើយ។ គោលការណ៍នេះ គឺដើម្បីយកទោសណាមួយទៅផ្តន្ទាទោសទៅលើជនណាមួយបាន លុះត្រាតែទោសនោះមានចែងទុកជាមុននៅក្នុងច្បាប់ព្រហ្មទណ្ឌ បើមិនដូច្នេះទេ គេមិនអាចអនុវត្តទោសទៅលើបុគ្គលណាម្នាក់បានឡើយ។ ដូច្នេះហើយគឺដាច់ខាតត្រូវតែតម្រូវឱ្យមានចែងពីបទប្បញ្ញត្តិនៃទោស បើពុំដូច្នេះទេ ចៅក្រមមិនអាចប្រកាសលើជនណាម្នាក់បានឡើយ គឺមិនអាចបង្កើតទោសទណ្ឌកម្មដោយខ្លួនឯងបានទេ ទោះជាច្បាប់បានកំណត់អំពើនោះជាបទល្មើសក៏ដោយ។

ឧទាហរណ៍៖ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា២៣៩ បានបញ្ញត្តិពីបទរំលោភសេពសន្ថវៈ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ។

**១.១.៣. បច្ច័យ**

បច្ច័យនៃគោលការណ៍នីត្យានុកូលភាព គឺសំដៅទៅដល់គោលគំនិតមួយក្នុងការបង្កើតច្បាប់ដើម្បីធ្វើការគ្រប់គ្រងទៅលើស្ថានភាពមួយចំនួន ដែលបុគ្គលណាមួយធ្វើសកម្មភាពបំពារបំពានទៅលើសិទ្ធិ និងផលប្រយោជន៍អ្នកដទៃ ដោយចេតនាក្តី ឬអចេតនាក្តីនៃការប្រព្រឹត្តរបស់ខ្លួន។

**ក. គោលការណ៍បកស្រាយច្បាប់ព្រហ្មទណ្ឌ**

យោងតាមមាត្រា៥ នៃក្រមព្រហ្មទណ្ឌការបកស្រាយច្បាប់ព្រហ្មទណ្ឌបានចែងថា ក្នុងរឿងព្រហ្មទណ្ឌច្បាប់ត្រូវបានបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ។ គ្មានទោសណាមួយដែលអាចត្រូវបានយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាស។ ក្នុងរឿងព្រហ្មទណ្ឌ ដែនអនុវត្តច្បាប់កម្ពុជាក្នុងលំហត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ។[6]

អវត្តមាននៃនិទណ្ឌភាព[7]ក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាព យុត្តិនិសេធ[8] ចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ។

ម្យ៉ាងវិញទៀតក្នុងគោលបំណងនៃគោលការណ៍នេះ គឺដើម្បីធានាការគោរពនូវគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោសឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ។ ក្រមព្រហ្មទណ្ឌមាត្រា៥ បានចែងអំពីគោលការណ៍ដែលជាបច្ច័យនៃគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស ដែលគេហៅថាជាគោលការណ៍នៃការ

---

[6] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥

[7] និទណ្ឌភាព គឺជាភាពដែលរួចផុតពីសំណាញ់ច្បាប់ដែលមានន័យថា មានច្បាប់ចែងហើយតែតុលាការ ឬមន្ត្រី មានសមត្ថកិច្ច មិនអនុវត្តន៍។

[8] ការប្រកែកមិនព្រមជំនុំជម្រះរកយុត្តិធម៌ឱ្យគូក្តី។

បកស្រាយច្បាប់ព្រហ្មទណ្ឌ ពោលគឺគេមិនអនុញ្ញាតឱ្យចៅក្រមធ្វើការពង្រីកវិសាលភាព ហើយក៏គេមិនអនុញ្ញាតឱ្យចៅក្រមប្រើវិធីសាស្ត្រក្នុងការបកស្រាយច្បាប់ព្រហ្មទណ្ឌក្នុងន័យជាការអនុវត្តបែបសទិសភាពដែរ គឺបានន័យថាចៅក្រមត្រូវធ្វើការបកស្រាយច្បាប់ព្រហ្មទណ្ឌក្នុងន័យយ៉ាងតឹងរ៉ឹង កុំឱ្យឃ្លាតចាកពីគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស។ តឹងរ៉ឹង សំដៅទៅលើះ

១. ស្ថាប័ននីតិប្បញ្ញត្តិ ឬស្ថាប័ននីតិប្រតិបត្តិ កំណត់អំពីស្មារតីក្នុងការចែងផ្តន្ទាទោសអំពើណាខ្លះ ដែលវាបង្កឱ្យមានផលប៉ះពាល់ដល់សង្គម ដូច្នេះចៅក្រមត្រូវអនុវត្តក្នុងស្មារតីដែលច្បាប់ ឬបទប្បញ្ញត្តិបានចែងស្ថានភាពហ្នឹងជាបទល្មើសព្រហ្មទណ្ឌ។

ឧទាហរណ៍ៈ ស្ថានភាពមួយដែលប្រហាក់ប្រហែលនឹងស្ថានភាព ដែលត្រូវបានកំណត់ថាជាបទល្មើសនឹងត្រូវផ្តន្ទាទោស កើតឡើងនោះចៅក្រមយល់ឃើញថាអំពើហ្នឹងប្រហាក់ប្រហែលគ្នា ហើយវាបង្កឱ្យមានផលប៉ះពាល់ខ្លះដែរ អញ្ចឹងចៅក្រមយកមកបកស្រាយ ប៉ុន្តែច្បាប់មិនអនុញ្ញាតឱ្យបកស្រាយតាមសទិសភាពទេ។

ឧទាហរណ៍ៈ ក្នុងករណីនៅប្រទេសបារាំងពីមុន បទល្មើសមួយដែលបុគ្គលម្នាក់ដឹងថាខ្លួនឯងគ្មានប្រាក់ហើយឡើងជិះរថភ្លើង នោះជាបទល្មើស។ ប៉ុន្តែមានករណីមួយទៀតបានកើតឡើង ដែលបុគ្គលម្នាក់បានដឹងខ្លួនឯងគ្មានប្រាក់ហើយចូលទៅភោជនីដ្ឋានដើម្បីឱ្យគេបម្រើសេវា។ នៅក្នុងស្មារតីច្បាប់គឺគេកំណត់តែបទល្មើសទាក់ទងតែនឹងរថភ្លើងតែប៉ុណ្ណោះ។

២. មិនឱ្យបកស្រាយពង្រីកវិសាលភាព។

ឧទាហរណ៍ៈ បុរសម្នាក់ បានស្រលាញ់នារីម្នាក់ ហើយបានសន្យានឹងរៀបការជាមួយនារីម្នាក់នោះ។ គេទាំងពីរបានជ្រុលជ្រួសប្រព្រឹត្តខុសប្រពៃណី ហើយក្រោយមកបុរសនោះដោះដៃ។ អ្នកខ្លះយល់ថាស្ថានភាពបែបនេះជាបទរំលោភលើសេចក្តីទុកចិត្ត ឬបទឆបោក។

**ខ. លក្ខណៈទូទៅ**

ការបកស្រាយច្បាប់ ត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ ឬច្បាប់ដើម្បីបំភ្លឺទៅនឹងភាពស្រពិចស្រពិលលើបញ្ញត្តិច្បាប់ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិបកស្រាយច្បាប់។ ចំណែកឯការផ្សព្វផ្សាយច្បាប់វិញ គឺគ្រាន់តែជាការអប់រំ ឬជូនព័ត៌មាន។ ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលមួយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា១៣៦ថ្មី ចែងអំពីក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារ ការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។[9] យើងឃើញហើយថា ច្បាប់ព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ក៏ត្រូវបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ និងពិនិត្យចប់សព្វគ្រប់ដោយព្រឹទ្ធសភា នាថ្ងៃទី១៧ ខែវិច្ឆកា ឆ្នាំ២០០៩ ហើយត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម

[9] រដ្ឋធម្មនុញ្ញដែលប្រកាសឱ្យប្រើនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ១៩៩៣, មាត្រា១៣៦ ថ្មី

លេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ២០០៩ នេះសបញ្ជាក់ឱ្យយើងឃើញយ៉ាងច្បាស់ថា ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចយ៉ាងពេញលេញ ក្នុងការបកស្រាយច្បាប់មួយនេះដែរ។

ជាគោលការណ៍ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយកបញ្ហាណាមួយមកពិនិត្យដោយខ្លួនឯងបានឡើយ។ មានតែព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន និងតំណាងរាស្ត្រមួយភាគដប់ ឬតុលាការប៉ុណ្ណោះ ដែលអាចសុំទៅក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់បាន។

**គ.អត្ថហេតុ**

ជាទ្រឹស្តីបរិសុទ្ធនៃការគ្រប់គ្រងរដ្ឋ តុលាការ (ទីនេះគឺសំដៅទៅលើចៅក្រម) មិនមានសមត្ថកិច្ចក្នុងការបកស្រាយច្បាប់បាននោះទេ ពោលគឺតុលាការគ្រាន់តែអាចសម្រេចថាត្រូវ ឬខុសច្បាប់តែប៉ុណ្ណោះ។ ប៉ុន្តែ ចំពោះទ្រឹស្តីនេះត្រូវបានវិវត្តដោយចៅក្រមក្នុងការអនុវត្តអាចធ្វើការបកស្រាយច្បាប់បានតែក្នុងរង្វង់អត្ថហេតុតែប៉ុណ្ណោះ ហើយវាក៏បានក្លាយទៅជាទម្លាប់ទៅហើយក្នុងពេលបច្ចុប្បន្ននេះ ដែលយើងពុំឃើញមានអ្នកច្បាប់ធំៗណាធ្វើការប្រឆាំង ឬក៏ជំទាស់អ្វីឡើយ។[10] ផ្ទុយទៅវិញ ការវិវត្តនៃទ្រឹស្តីនេះត្រូវបានបញ្ញតិជាច្បាប់វិជ្ជមានទៅវិញ ដែលត្រូវបានគេទទួលស្គាល់។ សម្រាប់នីតិកម្ពុជា ក្នុងការបកស្រាយច្បាប់ព្រហ្មទណ្ឌមាត្រា៥ បានបញ្ញត្តិថា ក្នុងរឿងក្តីព្រហ្មទណ្ឌ ច្បាប់ត្រូវបានបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ។[11]

តាមន័យខាងលើនេះ ការបកស្រាយនូវច្បាប់ព្រហ្មទណ្ឌ គឺជាការបកស្រាយមួយ ក្នុងការធានានូវការគោរពដល់គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស នេះបានសេចក្តីថា ត្រូវមានបទប្បញ្ញតិច្បាប់ចែងទុកជាមុនថា អំពើនោះគឺជាបទល្មើស ហើយនឹងត្រូវផ្តន្ទាទោស ជាការធានានូវការគោរពឱ្យបានច្បាស់លាស់ត្រឹមត្រូវ។ នៅក្នុងរឿងព្រហ្មទណ្ឌនេះដែរ គឺច្បាប់មិនអនុញ្ញាតឱ្យចៅក្រមប្រើវិធីសាស្ត្រក្នុងការបកស្រាយតាមន័យជាការអនុវត្តបែបសទិសភាពដែរ បានសេចក្តីថាចៅក្រមត្រូវបកស្រាយក្រមព្រហ្មទណ្ឌ ឬក៏ច្បាប់ព្រហ្មទណ្ឌ ដែលជាបទប្បញ្ញត្តិមានចែងអំពីបទល្មើស និងទោសនេះ ក្នុងអត្ថន័យមួយដ៏តឹងរ៉ឹង ដើម្បីកុំឱ្យឃ្លាតចាកពីគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស។ គោលការណ៍នេះតម្រូវឱ្យស្ថាប័ននីតិប្បញ្ញត្តិ ក៏ដូចជាស្ថាប័ននីតិប្រតិបត្តិត្រូវកំណត់អំពីស្មារតីដែលចង់ចែងថាផ្តន្ទាទោសនូវអំពើណាខ្លះ ដែលបង្កឱ្យមានការប៉ះពាល់ទៅដល់សង្គម ដូច្នេះហើយត្រូវតែចែងពីស្ថានភាពបែបនោះថាជាបទល្មើសព្រហ្មទណ្ឌ។ ហេតុនេះហើយចៅក្រមត្រូវអនុវត្តនៅក្នុងស្មារតីដដែលនេះមានន័យថា ត្រូវតែអនុវត្តនូវអ្វីដែលច្បាប់ចែង និងបទប្បញ្ញតិព្រហ្មទណ្ឌដែលបានចែងថា

---

[10] អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី, សាកលវិទ្យាល័យបៀលប្រាយ(២០១១), ហេងវង្សប៊ុនឆាត

[11] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នរស/រកន/១១០៩/០២២, ៣០ វិច្ឆកា ២០០៩, មាត្រា៥

អំពើបែបណា គឺជាបទល្មើសព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ នៅពេលដែលស្ថានភាពមួយប្រហាក់ប្រហែលទៅនឹងស្ថានភាពដែលច្បាប់បានចែងដែលបានកើតឡើង ចៅក្រមមើលទៅឃើញថា វាអាចស្រដៀងគ្នា ហើយគាត់ឃើញថាអំពើបែបនេះអាចប៉ះពាល់ខ្លះៗដែរ ស្រាប់តែគាត់យកស្ថានភាពប្រហាក់ប្រហែលគ្នាមកបកស្រាយ។[12] បើតាមមាត្រា៥ គឺក្រមព្រហ្មទណ្ឌយើង មិនអនុញ្ញាតឱ្យចៅក្រមបកស្រាយតាមន័យសទិសភាពនោះទេ រីឯពាក្យថា ការបកស្រាយតាមសទិសភាព មានន័យថា ជាការបកស្រាយទៅតាមគោលការណ៍ប្រដូច។[13]

ឧទាហរណ៍៖ បុរសម្នាក់បានជិះរថភ្លើងដោយគ្មានប្រាក់សម្រាប់បង់តម្លៃលើមធ្យោបាយធ្វើដំណើររបស់គេដែលជាសេវាកម្មដឹកជញ្ជូន។ ឧបមាថា ករណីមួយនេះជារឿងក្តីព្រហ្មទណ្ឌដែលកំណត់ថាជាបទល្មើស ហើយឧបមាថាមានករណីមួយទៀត ដែលមានលក្ខណៈស្រដៀង ឬប្រហាក់ប្រហែលដូចជាករណីមួយនេះ។ ឧទាហរណ៍៖ នារីម្នាក់បានចូលភោជនីដ្ឋានមួយកន្លែង ដើម្បីទទួលទានអាហារមួយពេលរបស់នាង ក្រោយពេលដែលនាងបានទទួលទានអាហាររួចហើយ ស្របពេលនោះដែលនាងពុំមានប្រាក់សម្រាប់បង់ឱ្យទៅកាន់អ្នកគិតលុយនោះទេ ទាំងដែលនាងបានដឹងច្បាស់ហើយថានាងពុំមានប្រាក់។ ស្របពេលនោះដែលម្ចាស់ភោជនីយដ្ឋានបានធ្វើការដាក់ពាក្យបណ្តឹងទៅកាន់តុលាការ ហើយក្រោយពេលដែលតុលាការបានពិនិត្យសំណុំរឿងនេះ ហើយបានសន្និដ្ឋានថារឿងនេះមានលក្ខណៈស្រដៀងទៅនឹងរឿងបុរសម្នាក់ ដែលបានជិះរថភ្លើងមិនបានបង់ប្រាក់ និងបានឱ្យគេបម្រើសេវាកម្មដល់ខ្លួនដូចគ្នា។ ប៉ុន្តែការយល់ឃើញបែបនេះ គឺខុសស្រឡះអំពីស្មារតីនៃក្រមព្រហ្មទណ្ឌមាត្រា៥ ពីព្រោះថាស្មារតីច្បាប់ចែងពាក់ព័ន្ធតែទៅលើករណីជិះរថភ្លើង តែច្បាប់មិនបានឱ្យធ្វើការបកស្រាយប្រដូចករណីដែលទទួលទានអាហារពុំបានបង់ប្រាក់នោះទេ។ ដោយហេតុថានេះជាករណីបន្លំដូចគ្នាក៏ពិតមែន ប៉ុន្តែច្បាប់កំណត់ថាគោលដៅសំខាន់គឺ ការពារ និងធានាដល់ចីរភាពនៃសេវាកម្មដឹកជញ្ជូន ហេតុនេះហើយបានជាច្បាប់ចែងតែក្នុងករណីនេះតែមួយប៉ុណ្ណោះ។ ចំណែកឯករណីដែលទទួលទានអាហារហើយមិនឱ្យប្រាក់ ថ្វីត្បិតតែមិនមានទោសពិតមែនតែមិនមែនមានន័យថារួចខ្លួននោះទេ គ្រាន់ច្បាប់មិនកំណត់ថាមិនមែនជាបទល្មើសព្រហ្មទណ្ឌដូចជាការដឹកជញ្ជូនខាងលើនោះទេ។ ក៏ប៉ុន្តែម្ចាស់ភោជនីយដ្ឋាន គឺគាត់មានសិទ្ធិតាមនីតិវិធីរដ្ឋប្បវេណី ហើយគាត់មានសិទ្ធិប្តឹងដើម្បីទាមទារសំណងនៃការខូចខាតបាន។

### ១.១.៤.ធាតុផ្សំនៃបទល្មើស

ធាតុផ្សំនៃបទល្មើស គឺជាកត្តាគួបផ្សំទាំងឡាយដែលបានបង្កើតឱ្យមានរូបរាង ជាក់ស្តែងនៃអំពើល្មើសមួយមានចែងជាធរមាននៅក្នុងនីតិព្រហ្មទណ្ឌ។ ធាតុផ្សំនេះស្តែងចេញពីការសំយោគនូវកត្តាសត្យានុម័ត និងកត្តាអត្តនោម័ត ដែលកើតមានឡើងនូវលក្ខណៈរួមនៃអំពើបង្ក។ ដើម្បីកំណត់ថាបទល្មើសណាមួយជាបទល្មើស

[12] កម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា(២០១០), ដោយក្រសួងយុត្តិធម៌, កើត រិទ្ធ

[13] ទីស្តីការគណៈរដ្ឋមន្ត្រី,សទ្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌ, (ភ្នំពេញ៖២០១១), ៦៥ (សទិសភាព គឺជាភាពស្របគ្នា ភាពស្រដៀងគ្នា)

ព្រហ្មទណ្ឌបាន លុះត្រាតែមានធាតុផ្សំនៃបទល្មើសបីជាចាំបាច់៖ ធាតុនីត្យានុកូល ឬធាតុច្បាប់ ធាតុសត្យានុម័ត ឬអំពើប្រព្រឹត្ត និងធាតុអត្តនោម័ត ឬស្ថានភាពផ្លូវចិត្ត។

ជាទូទៅនៅក្នុងអំពើណាមួយជាបទល្មើសព្រហ្មទណ្ឌតែងតែមានធាតុផ្សំទាំងបីខាងលើនេះជាដរាប បើខ្វះធាតុផ្សំណាមួយក្នុងចំណោមធាតុផ្សំទាំងបីនេះ ពុំអាចចាត់ទុកថាអំពើនោះជាបទល្មើសបានទេ។

**ក.ធាតុនីត្យានុកូល ឬធាតុច្បាប់**

ធាតុនីត្យានុកូល ឬធាតុច្បាប់ មានន័យថាអាចចោទប្រកាន់លើជនណាម្នាក់ថាជាជនប្រព្រឹត្តបទល្មើស ឬអាចដាក់ទោសលើជនណាម្នាក់បាន លុះត្រាតែជននោះបានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌដែលកំពុងចូលជាធរមាន។

ឧទាហរណ៍៖ ករណីបុរសម្នាក់បានមានកំហឹង និងសត្វគោដែលបានបំផ្លាញដំណាំរបស់ខ្លួន ហើយក៏បានសម្លាប់សត្វដែលខ្លួនឯងចិញ្ចឹមនេះយ៉ាងសាហាវឃោរឃៅ ដោយបានប្រើប្រាស់កាំបិតទៅចាក់កាប់សម្លាប់សត្វគោជាច្រើនកាំបិតទាំងរស់ដោយសម្លាប់ក្នុងថ្លុកឈាមដាបពេញដី ទោះជាអំពើមួយនេះជាអំពើសាហាវព្រៃផ្សៃក៏ពិតមែន ក៏ជននោះមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ពីព្រោះតែច្បាប់ព្រហ្មទណ្ឌមិនមានចែងហាមពីអំពើនេះទេ។

ដោយយល់ឃើញថា ច្បាប់ព្រហ្មទណ្ឌមានផលប៉ះពាល់ដល់សិទ្ធិ និងសេរីភាព ហើយដើម្បីការពារ ការចោទប្រកាន់ខុសករណីដែលមិនពាក់ព័ន្ធក្នុងរឿងព្រហ្មទណ្ឌពីសំណាក់តុលាការ ទើបមាត្រា៥ ក្នុងច្បាប់នេះចែងថា ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ។

ឧទាហរណ៍៖ ការមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីប្រាក់ គឺជារឿងរដ្ឋប្បវេណី ដែលមិនអាចប្ដឹងទាមទារប្រាក់ពីកូនបំណុលទៅតុលាការព្រហ្មទណ្ឌបានទេ។ ពោលគឺមិនមែនជាបទល្មើសឆបោក ឬរំលោភលើសេចក្ដីទុកចិត្តបាននោះទេ។

ម៉្យាងវិញទៀត កាលណាច្បាប់ចូលជាធរមានហើយ គ្មាននរណាម្នាក់សំអាងថាខ្លួនមិនបានដឹងថាមានច្បាប់ហាមអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។ វាជាគោលការណ៍ដែលនិយាយថា គ្មាននរណាម្នាក់ដែលមិនដឹងច្បាប់នោះទេ។ តែមិនមែនមានន័យថារដ្ឋចង់ដាក់ទោសព្រហ្មទណ្ឌលើប្រជាពលរដ្ឋខ្លាំងនោះទេ ដូចនេះហើយ ដើម្បីអនុវត្តគោលការណ៍ខាងលើនេះ ច្បាប់ក៏បានចែងដែរថារដ្ឋចាំបាច់ត្រូវតែធ្វើការផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌឱ្យបានទូលំទូលាយ។

**ខ.ធាតុសត្យានុម័ត ឬអំពើប្រព្រឹត្ត**

ធាតុសត្យានុម័ត ឬអំពើប្រព្រឹត្ត សំដៅលើអំពើប្រព្រឹត្តទោះដោយសកម្ម ឬជាអំពើអកម្មក្ដី ដែលអំពើនោះបណ្ដាលឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាព បូរណភាពបុគ្គល ទ្រព្យសម្បត្តិសារធារណៈ ឬឯកជនជាដើម។ ចំពោះបទល្មើសសកម្ម គឺថាវាជាបទល្មើសដែលជនល្មើសប្រព្រឹត្តផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌបានហាម។

ឧទាហរណ៍៖ បទឃាតកម្ម គឺជាបទល្មើសសកម្ម ពីព្រោះវាជាបទល្មើសដែលក្រមព្រហ្មទណ្ឌបានហាមជនល្មើសមិនឱ្យប្រព្រឹត្តអំពើនេះ ពោលគឺហាមមិនឱ្យសម្លាប់មនុស្ស។ ចំពោះបទល្មើសអកម្ម គឺថាវាជាបទល្មើសដែលជនល្មើសមិនព្រមបំពេញកាតព្វកិច្ចអ្វីមួយទៅតាមច្បាប់ព្រហ្មទណ្ឌតម្រូវ។ ជាឧទាហរណ៍ បទមិនប្ដឹងបរិហារបទឧក្រិដ្ឋគឺជាបទល្មើសអកម្ម ពីព្រោះថាវាជាបទល្មើសដែលក្រមព្រហ្មទណ្ឌបានដាក់កាតព្វកិច្ចឱ្យជននោះអនុវត្តតាម តែបុគ្គលនោះមិនបានបំពេញតាមការតម្រូវនេះ ពោលគឺ មិនបានប្ដឹងបរិហារបទឧក្រិដ្ឋ។

ទាក់ទងនឹងដំណាក់កាលនៃការប្រព្រឹត្តបទល្មើស គឺមិនមែនគ្រប់ដំណាក់កាលទាំងអស់សុទ្ធតែមានទោសព្រហ្មទណ្ឌនោះទេ តួយ៉ាងដូចជាដំណាក់កាលនៃការគិត និងការរៀបចំមិនមានទោសព្រហ្មទណ្ឌទេ។ តែការចាប់ផ្ដើមប្រព្រឹត្តអាចមានទោស។ អាចមានទោស បើកាលណាចាប់ផ្ដើមនោះមិនបានបញ្ឈប់ទៅវិញដោយស្ម័គ្រចិត្តនោះទេ។ ផ្ទុយទៅវិញ មិនមានទោសទេ បើការចាប់ផ្ដើមនោះបានបញ្ឈប់ទៅវិញដោយស្ម័គ្រចិត្ត។ ដើម្បីយល់កាន់តែច្បាស់ជាងនេះ យើងអាចក្រឡេកមើលមាត្រា២៧ ដែលនិយាយពីការប៉ុនប៉ង។ តើអ្វីជាការប៉ុនប៉ង? តាមអត្ថន័យមាត្រា២៧ ក្នុងក្រមព្រហ្មទណ្ឌ ការប៉ុនប៉ង ជាបទល្មើសដែលជនល្មើសបានប្រព្រឹត្តដោយចេតនាដើម្បីសម្រេចគោលបំណង ប៉ុន្តែក្នុងពេលកំពុងប្រព្រឹត្តត្រូវបានអាក់ខានទៅវិញដោយមានកត្តាផ្សេងៗ មករារាំងមិនឱ្យជនល្មើសបានប្រព្រឹត្តបានសម្រេច។[14] និយាយម៉្យាងទៀត គឺចារីបានចាប់ផ្ដើមប្រព្រឹត្តបទល្មើស ហើយមិនបានបញ្ឈប់អំពើរបស់ខ្លួន។

ឧទាហរណ៍៖ បុរសម្នាក់បានដកកាំបិតមុខស្រួចចាក់ទៅកាន់បំពង់កសត្រូវរបស់ខ្លួន ហើយបានចាក់ថែមមួយកាំបិត រួចបានរត់ទៅបាត់ដោយក្នុងចិត្តរបស់គាត់បានគិតថាសត្រូវរបស់ខ្លួនបានដេកស្លាប់ក្នុងថ្លុកឈាមបាត់ទៅហើយ តែវាផ្ទុយទៅវិញវាខុសពីការគិតរបស់គាត់ទាំងស្រុង គឺថាជនរងគ្រោះម្នាក់នោះមិនបានស្លាប់នោះទេ។ នៅក្នុងករណីនេះដែរ គឺជាការប៉ុនប៉ង ពីព្រោះថាបុរសម្នាក់នោះមិនបានបញ្ឈប់ដោយស្ម័គ្រចិត្តទេ ពោលគឺគាត់បានធ្វើសកម្មភាពចាក់ទៅលើជនរងគ្រោះ ហើយបើទោះបីជាគាត់មិនបាននៅបន្តចាក់ជនរងគ្រោះឱ្យស្លាប់ពិតប្រាកដក៏ដោយ តែការដែលជនរងគ្រោះបានរួចផុតជីវិតពីការសម្លាប់របស់គាត់ គឺមិនមែនបំណងរបស់គាត់នោះទេ តែវាជាការស្មានខុសរបស់គាត់ដែលគិតថាជនរងគ្រោះស្លាប់បាត់ទៅហើយ ហើយចំពោះការមិនស្លាប់នេះដោយសារគាត់ចាក់មិនចំកន្លែងស្លាប់របស់ជនរងគ្រោះ ហើយជនរងគ្រោះត្រូវបានជួយសង្គ្រោះទាន់ពេលវេលាពីសំណាក់គ្រូពេទ្យជាដើម ដែលទាំងអស់នោះជាកត្តាក្រៅឆន្ទៈរបស់បុរសម្នាក់នោះ។ ដូចនេះហើយគាត់ត្រូវមានទោសពីបទប៉ុនប៉ង ឃាតកម្ម (បើសិនជាជនរងគ្រោះបានស្លាប់វិញ គឺត្រូវមានទោសពី បទឃាតកម្ម តែម្ដង)។

ទាក់ទងនឹងការប៉ុនប៉ងនេះដែរ សូមកត់សម្គាល់ផងដែរថា គ្រប់បទល្មើសឧក្រិដ្ឋសុទ្ធតែត្រូវផ្ដន្ទាទោសលើការប៉ុនប៉ង (មាត្រា២៧)។ ចំណែកឯ ក្នុងករណីបទមជ្ឈិមវិញ គឺអាចផ្ដន្ទាទោសលើការប៉ុនប៉ងបានលុះត្រាតែ

[14] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នរស/រកន/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៧

មានការចែងដាក់លាក់ក្នុងច្បាប់។ ចំពោះការផ្តន្ទាទោសលើការប៉ុនប៉ងវិញ គឺត្រូវផ្តន្ទាទោសដូចបទល្មើសបានសម្រេចដែរ។ ចំណុចដែលសំខាន់មួយទៀតនោះ គឺថាការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសព្រហ្មទណ្ឌដាច់ខាត។

**គ.ធាតុអត្តនោម័ត ឬស្ថានភាពផ្លូវចិត្ត**

ធាតុអត្តនោម័ត ឬស្ថានភាពផ្លូវចិត្ត សំដៅលើចេតនា ឬស្ថានភាពផ្លូវចិត្តរបស់ជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ។ ក្រឡេកមើលមាត្រា៤ កថាខណ្ឌទី១ ក្នុងក្រមព្រហ្មទណ្ឌ បានចែងផងដែរថាពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។[15] នេះជាគោលការណ៍សំខាន់បំផុតមួយរបស់បទល្មើសព្រហ្មទណ្ឌដែលថាជនណាម្នាក់ និងអាចផ្តន្ទាទោសព្រហ្មទណ្ឌបាន លុះត្រាតែមានធាតុផ្សំមួយនេះផងដែរ ពោលគឺជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយបើខ្លួនមិនមានចេតនាក្នុងការប្រព្រឹត្ត ឬចេតនាទុច្ចរិត ឬហៅថាពិរុទ្ធារម្មណ៍នោះ។

ឧទាហរណ៍៖ ករណីដែលបុរស ក បានយកកាតាបរបស់មិត្តរួមថ្នាក់របស់ខ្លួនទៅផ្ទះគាត់ ពីព្រោះដោយហេតុថាកាតាបរបស់គេមានលក្ខណៈដូចគ្នាទាំងស្រុង ដែលបានដាក់លើតុជាមួយគ្នា គឺនៅពេលដែលគ្រូបានប្រមូលកាតាបរបស់ពួកគេដាក់លើតុមុនម៉ោងប្រឡង។ ក្នុងករណីនេះដែរបុរស ក មិនមានទោសពីបទលួចដូចដែលបានចែងក្នុងក្រមព្រហ្មទណ្ឌនោះទេ ពីព្រោះថាគាត់គ្មានចេតនាក្នុងការយកកាតាបរបស់មិត្តរួមថ្នាក់របស់គាត់ធ្វើជាកម្មសិទ្ធិរបស់គាត់នោះឡើយ តែវាគ្រាន់តែជាការភាន់ច្រឡំប៉ុណ្ណោះ។

ទោះបីជាយ៉ាងនេះក្តី ក៏មានការលើកលែង ឬហៅម្យ៉ាងទៀតថាអញ្ញត្រកម្ម ដែលផ្ទុយពីគោលការណ៍ទូទៅ។ នេះចង់សំដៅថា ទោះបីជាមិនមានចេតនាក្តី តែបើក្នុងករណីដែលមានច្បាប់ចែងទុកជាមុន បទល្មើសមួយអាចកើតចេញពី ការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ (មាត្រា៥ កថាខណ្ឌទី២)។

ឧទាហរណ៍៖ បទមនុស្សឃាតដោយអចេតនា (មាត្រា២០៧) នៃក្រមព្រហ្មទណ្ឌ។ ចំពោះបទមនុស្សឃាតដោយអចេតនា ឧបមាថាមានសិស្សសាលាមួយក្រុមបានធ្វើដំណើរឆ្លងថ្នល់ ស្របពេលគ្នានោះដែរអ្នកបើកបរម្នាក់កំពុងតែបរិភោគចំណីអាហារបណ្តើរ ស្តាប់ចម្រៀងបណ្តើរ ព្រមជាមួយនឹងការបើកបរល្បឿនលឿនហួសកំណត់ផងទើបធ្វើឱ្យរថយន្តបានបុកក្រុមសិស្សសាលាមួយក្រុមដែលកំពុងឆ្លងថ្នល់នោះ និងបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ជីវិតសិស្សស្រីម្នាក់។ ករណីបែបនេះ ទោះបីជាអ្នកបើកបររថយន្តនោះមិនមានចេតនាសម្លាប់សិស្សស្រីម្នាក់នោះក៏ដោយ ក៏គាត់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌលើបទមនុស្សឃាតដោយអចេតនាដែរ

[15] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នរស/រកន/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤ កថាខណ្ឌទី១

ពីព្រោះថាវាជាការធ្វេសប្រហែស និងបំពានកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ដោយគាត់បានបើកបំពានលើសល្បឿនកំណត់ ដែលបណ្តាលឱ្យជនរងគ្រោះមានគ្រោះថ្នាក់ដល់ជីវិត។

គួរកត់ចំណាំផងដែរថា ដើម្បីកំណត់ស្ថានភាពផ្លូវចិត្ត ឬពិរុទារម្មណ៍ គឺត្រូវផ្អែកលើសកម្មភាពនៃការប្រព្រឹត្តរបស់ជននោះ។[16]

### ១.១.៥.គោលការណ៍មិនប្រតិសកម្ម

គោលការណ៍មិនប្រតិសកម្មច្បាប់ព្រហ្មទណ្ឌ គឺជាគោលការណ៍គ្រឹះនៃនីតិព្រហ្មទណ្ឌ។ សញ្ញាណនៃគោលការណ៍នេះចេញមកពីបារាំងដែលកើតមានតាំងតែពីឆ្នាំ១៧៨៩ នៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីអំពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិមនុស្សរបស់បារាំង ហើយក្លាយជាគោលការណ៍មួយនៅក្នុងរដ្ឋធម្មនុញ្ញបារាំង។ ហើយគោលការណ៍នេះ គឺជាគោលការណ៍គ្រឹះនៃនីតិសិទ្ធិមនុស្ស និងលិទ្ធិប្រជាធិបតេយ្យដើម្បីធានានូវសិទ្ធិសេរីភាព និងសុវត្ថិភាពគតិយុត្តរបស់ប្រជាពលរដ្ឋ។[17] បន្ថែមពីនេះវាគឺជាគោលការណ៍ដែលការពារការសងសឹកគ្នារវាងគណបក្សនយោបាយដែលការពារមិនឱ្យអ្នកឡើងកាន់អំណាចក្រោយ សងសឹកទៅលើអ្នកកាន់អំណាចមុនដែលបាត់បង់អំណាច។

គោលការណ៍នេះគឺជាគោលការណ៍វិបាកកម្ម ដែលវាត្រូវដើរទន្ទឹមគ្នាជាមួយនឹងគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស។ គោលការណ៍នេះមានន័យថា ច្បាប់ព្រហ្មទណ្ឌគឺមានអានុភាពតែទៅអនាគត ហើយមិនមានអានុភាពអនុវត្តទៅអតីតកាលទេ។ មានន័យថា អនុវត្តតែទៅលើបទល្មើសណាដែលកើតឡើងក្រោយច្បាប់ព្រហ្មទណ្ឌចូលជាធរមានតែប៉ុណ្ណោះ។ ដូចនេះច្បាប់ព្រហ្មទណ្ឌ ដែលធ្ងន់ជាងមិនអនុវត្តទៅនឹងបទល្មើសដែលកើតមុនច្បាប់ព្រហ្មទណ្ឌនោះចូលជាធរមាននោះទេ ពោលគឺមិនប្រតិកម្មនោះទេ។

ឧទាហរណ៍៖ ប្រសិនបើច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា អំពើអសីលធម៌ គឺជាបទល្មើសលហុ ហើយពិន័យជាប្រាក់ ១០០០រៀល (មួយពាន់រៀល) ប៉ុន្តែច្បាប់ថ្មីបានចែងថា អំពើអសីលធម៌ គឺជាបទល្មើសមជ្ឈិម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ៣ខែ និងពិន័យជាប្រាក់ ៥លានរៀល (ប្រាំលានរៀល)។ អំពើទាំងឡាយដែលបានប្រព្រឹត្តក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល មិនអាចយកច្បាប់ព្រហ្មទណ្ឌថ្មីទៅអនុវត្តទៅលើបទល្មើសនោះបានទេ ពីព្រោះថាច្បាប់ព្រហ្មទណ្ឌថ្មីមានលក្ខណៈធ្ងន់ជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

### ១.១.៦. ច្បាប់ព្រហ្មទណ្ឌស្រាលជាង

ទន្ទឹមគ្នានេះដែលការអនុវត្តប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ហើយគោលការណ៍ប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាងក៏ត្រូវបានអនុវត្តផងដែរ។ មានន័យថាចៅក្រមត្រូវបានអនុវត្តច្បាប់ព្រហ្មទណ្ឌដែល

[16] នីតិព្រហ្មទណ្ឌទូទៅ, សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

[17] ក្នុងសេចក្តីថ្លែងការណ៍ស្តីពីអំពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិមនុស្សរបស់បារាំង ឆ្នាំ១៧៨៩

ចូលជាធរមានក្រោយបទល្មើសកើតមាន ប្រសិនបើច្បាប់ព្រហ្មទណ្ឌនោះបញ្ញត្តិទោសស្រាល ឬក៏លុបចោលបទល្មើសណាមួយដែលមានក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល។ ហើយការអនុវត្តនេះ គឺជាការអនុវត្តដើម្បីអនុគ្រោះដល់ជនល្មើស។ ក្នុងការអនុវត្តដោយប្រតិសកម្មនោះគឺមានចែងក្នុងបទប្បញ្ញត្តិមួយចំនួនដូចជា ច្បាប់ដែលលុបចោលបទល្មើសដែលមានចែងក្នុងមាត្រា៩ ដល់មាត្រា១១ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ ប្រភេទនៃច្បាប់លុបចោលបទល្មើសដែលស្រាលជាងនេះគឺត្រូវអនុវត្តភ្លាមៗ។ បានន័យថា អំពើប្រព្រឹត្តក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលបានចែងធ្ងន់ (ចែងថាជាបទល្មើស) មិនចាំបាច់ចោទប្រកាន់ទៀតទេ ប្រសិនបើច្បាប់ព្រហ្មទណ្ឌស្រាលជាងបានចូលជាធរមាន ដែលបានលុបចោលនៃអំពើនោះទៀតទេ ពីព្រោះច្បាប់ព្រហ្មទណ្ឌដែលស្រាលជាងបានលុបអំពើនោះថាមិនមែនជាបទល្មើសទេ។ ដូចនេះចៅក្រមមិនចាំបាច់ចោទប្រកាន់ជនប្រព្រឹត្តអំពើនោះថាមិនមែនជាបទល្មើសទៀតទេ។ ប្រសិនបើបទល្មើសនោះកំពុងចោទប្រកាន់ត្រូវលុបចោលការចោទប្រកាន់នោះភ្លាម ហើយប្រសិនបើទោសនោះកំពុងអនុវត្តត្រូវបញ្ឈប់ការអនុវត្តភ្លាម ហើយទោសនោះមិនអនុវត្តទៀតឡើយ។ ពោលគឺមិនមែនជាបទល្មើសទៀតទេ ប្រសិនបើច្បាប់ព្រហ្មទណ្ឌថ្មីបានលុបចោលទៅតែច្បាប់ថ្មីបានលុបចោលថាអំពើលេងល្បែងស៊ីសងមិនមែនជាអំពើខុសច្បាប់ ឬមិនមែនជាបទល្មើសទៀតទេ។ ជនទាំងឡាយដែលកំពុងត្រូវបានចោទប្រកាន់អំពីអំពើនោះ ទោសកំពុងអនុវត្តនៃបទល្មើសនោះ នឹងត្រូវលុបចោល ហើយដោះលែងជនដែលប្រព្រឹត្តនោះភ្លាមឱ្យមានសេរីភាព និងរួចផុតពីការចោទប្រកាន់។

លើសពីនេះទៅទៀត ប្រសិនបើច្បាប់ព្រហ្មទណ្ឌថ្មីកំណត់ទោសស្រាលជាងច្បាប់ព្រហ្មទណ្ឌអន្តរកាលគឺចៅក្រមត្រូវអនុវត្តទោសដែលបានបញ្ញត្តិនៅក្នុងក្រមថ្មីនោះភ្លាមដូចគ្នា។

ឧទាហរណ៍៖ ក្នុងករណីលួច ប្រសិនបើបទល្មើសលួចនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលត្រូវមានទោសពី ៤ឆ្នាំ ទៅ ៥ឆ្នាំ ហើយច្បាប់ព្រហ្មទណ្ឌថ្មីបញ្ញត្តិផ្តន្ទាទោសត្រឹមតែពី ៦ខែ ទៅ ៣ឆ្នាំ នោះគឺចៅក្រមត្រូវអនុវត្តទោសដែលបានបញ្ញត្តិនៅក្នុងច្បាប់ព្រហ្មទណ្ឌថ្មីនោះភ្លាម។

### ១.១.៧. ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺសំដៅទៅដល់ការទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួន។ អំពើផ្ទាល់ខ្លួន មានន័យថាប្រសិនបើបុគ្គលណាម្នាក់ជាអ្នកប្រព្រឹត្តបទល្មើស ដូច្នេះបុគ្គលនោះជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។ ក្នុងករណីបែបនេះ គឺមានលក្ខណៈខុសពីរឿងក្តីរបស់រដ្ឋប្បវេណី បានន័យថាក្នុងរឿងក្តីរដ្ឋប្បវេណី ច្បាប់អនុញ្ញាតឱ្យអ្នកទទួលខុសត្រូវជំនួសបាន។ ប៉ុន្តែនៅក្នុងរឿងព្រហ្មទណ្ឌវិញ បុគ្គលណាជាអ្នកប្រព្រឹត្តបទល្មើសបុគ្គលនោះ គឺជាអ្នកដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ដែលពាក្យពេចន៍ភាសាខ្មែរយើងនិយាយសាមញ្ញថា "អ្នកណាអ្នកធ្វើ អ្នកនោះជាអ្នកទទួល"។ ហេតុនេះមិនអាចឱ្យអ្នកដទៃចូលទៅទទួលទោសជំនួសទេ បើទោះបីជាទោសនោះជាទោសប្រភេទអ្វីក៏ដោយ។

ឧទាហរណ៍៖ មូលទោស គឺជាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ប្រសិនបើជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ គឺច្បាប់មិនអនុញ្ញាតឱ្យអ្នកដទៃចូលខ្លួនទៅទទួលទោសជំនួសទណ្ឌិតបានឡើយ។ សូម្បីតែការបង់ប្រាក់ពិន័យក៏ច្បាប់មិនអនុញ្ញាតឱ្យអ្នកដទៃទៅបង់ប្រាក់ជំនួសដែរ ពីព្រោះគោលបំណងនៃទោសព្រហ្មទណ្ឌដែលមានគោលដៅធ្វើឱ្យជននោះ ខ្លាចរអា និងដើម្បីបង្ការដល់សាធារណជន។ ដូច្នេះការដាក់ទណ្ឌកម្ម គឺធ្វើឱ្យទណ្ឌិតមានអារម្មណ៍ថាអ្វីដែលខ្លួនបានប្រព្រឹត្តគឺខុស ហើយនៅពេលដែលបុគ្គលនោះប្រព្រឹត្តខុស វាបានធ្វើឱ្យមានផលប៉ះពាល់ដល់អ្នកដទៃ និងខ្លួនឯងយ៉ាងណា។

**១.១.៨. ឯកត្តកម្មនៃទោស**

ឯកត្តកម្មនៃទោស សំដៅដល់តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុព្រមទាំងទៅលើកិរិយាមាយាទរបស់ជនជាប់ចោទក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះដោយយោងតាមមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។[18] ជាការពិតណាស់ មុននឹងធ្វើការសម្រេចផ្តន្ទាទោសលើបទល្មើសនីមួយៗ តុលាការត្រូវតែមានការសិក្សាស្វែងយល់អំពីមូលហេតុ និងការដែលជំរុញឱ្យមានបទល្មើស ឬកិរិយាមាយាទក្រោយការប្រព្រឹត្តបទល្មើស ដោយគោរពនឹងភាពមិនរើសអើង និងស្មើភាពគ្នា ភាពសមាមាត្រនៃទោស និងគោលការណ៍ដោយឡែកដោយផ្អែកទៅលើស្ថានភាពប្រែប្រួលរបស់ជនល្មើសនីមួយៗ។ ផ្ទុយទៅវិញ បើការប្រកាសទោសពុំបានឆ្លងកាត់ការវិនិច្ឆ័យដោយគោរពតាមគោលការណ៍ឯកត្តកម្មនៃទោសទេ ការជំនុំជម្រះលើទោស និងនាំឱ្យមានភាពលម្អៀង និងអយុត្តិធម៌។ លើសពីនេះទៅទៀតគោលការណ៍នេះក៏ជាមូលដ្ឋានសំខាន់ពាក់ព័ន្ធនឹងរបបទូទៅនៃការប្រកាសទោសរបស់តុលាការ ពោលគឺត្រូវប្រកាសទោសដោយគោរពគោលការណ៍ឯកត្តកម្មនៃទោសដែលអាចឱ្យចៅក្រមធ្វើការពិចារណាក្នុងការសម្រេច ការប្រកាសមូលទោស ការប្រកាសទោសជំនួស ការប្រកាសទោសបន្ថែមលើមូលទោស ការប្រកាសទោសការងារសហគមន៍ ការព្យួរទោសធម្មតា ការព្យួរទោសសាកល្បង របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគជាអាទិ៍។

សរុបមក ឯកត្តកម្មនៃទោសព្រហ្មទណ្ឌ គឺជាគោលការណ៍ពិសេសមួយដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កើតឡើងដើម្បីកំណត់ជាមូលដ្ឋានគ្រឹះមួយសម្រាប់ចៅក្រមជំនុំជម្រះដើម្បីថ្លឹងថ្លែងពិចារណា និងប្រើប្រាស់អំណាចឆន្ទានុសិទ្ធិដោយគោរពតាមគោលការណ៍នេះ ក្នុងការប្រកាសទោសព្រហ្មទណ្ឌទៅតាមកម្រិតនៃអំពើដែលជនជាប់ចោទបានប្រព្រឹត្ត និងទំហំព្យសនកម្មដែលបានបង្កដល់ជនរងគ្រោះ និងសង្គមជាតិ ដើម្បីផ្តល់ភាពត្រឹមត្រូវ និងយុត្តិធម៌។ គោលការណ៍នេះ គឺជាគោលការណ៍មូលដ្ឋានដែល

[18] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៩៦

មានបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ សម្រាប់ចៅក្រមយកមកពិចារណាអំពីស្ថានភាពរបស់ជនល្មើសក្នុងពេលប្រព្រឹត្តបទល្មើស ក្រោយពេលប្រព្រឹត្តបទល្មើសពិចារណាអំពីចរិតលក្ខណៈ ឬសភាពផ្លូវចិត្តរបស់ជនជាប់ចោទ និងទំហំព្យសនកម្មបង្កដល់ជនរងគ្រោះ និងសង្គមជាតិជាដើម មុននឹងធ្វើការប្រកាសទោសព្រហ្មទណ្ឌ។

### ១.១.៩. ការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ យោងតាមមាត្រា៦ នៃក្រមព្រហ្មទណ្ឌ។[19] ការប្រកាសទោស ជាដំណាក់កាលដ៏សំខាន់មួយដែលតម្រូវឱ្យចៅក្រមធ្វើការពិចារណាយ៉ាងល្អិតល្អន់ មុននិងធ្វើការប្រកាសដាក់ទណ្ឌកម្មទៅលើបុគ្គល ដើម្បីធ្វើឱ្យសមស្របទៅនឹងទង្វើក៏ដូចជាស្ថានភាពនៃបទល្មើសដែលបានកើតឡើង។ ការប្រកាសនេះទៀតសោតអាចអនុវត្តទៅបានលុះត្រាតែទោសនោះត្រូវបានប្រកាសដោយចៅក្រម ដែលមានសមត្ថកិច្ចផ្ដាច់មុខដែលបានផ្ដល់ទៅឱ្យយុត្តាធិការក្នុងការសម្រេចអំពីទោស។

## ផ្នែកទី២៖ លក្ខខណ្ឌការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាការទទួលខុសត្រូវផ្ទាល់ខ្លួនដូចដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌមាត្រា២៤ បានចែងថា បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។[20] ការចាប់បង្ខំឱ្យជនណាមួយដែលបានប្រព្រឹត្តនូវអំពើបង្កគ្រោះថ្នាក់ដល់ទំនាក់ទំនងសង្គម ដែលច្បាប់ក្នុងសង្គមនោះ ចាត់ទុកថាជាបទល្មើសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាវិធានការតឹងតែងបំផុតរបស់រដ្ឋ។[21] វិធានការតឹងតែងបំផុតរបស់រដ្ឋ គឺជាការដកហូតនៅសិទ្ធិសេរីភាពរបស់ពលរដ្ឋ ក្នុងនោះរួមមានការដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ជាដើម ទាំងនេះគឺជាទោសព្រហ្មទណ្ឌដែលជនល្មើសទទួលតាមរយៈអំពើរបស់ខ្លួន ដោយសេចក្ដីសម្រេចជាស្ថាពររបស់តុលាការ។

### ២.១. ប្រភេទរូបវន្តបុគ្គល

រូបវន្តបុគ្គល សំដៅលើបុគ្គលមានសមត្ថភាពតាមផ្លូវច្បាប់ ដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ឬជាមនុស្សដែលមានជីវិតពិតពីធម្មជាតិដែលផ្ទុយនឹងនីតិបុគ្គល។ ហើយប្រធាននៃសិទ្ធិ និងកាតព្វកិច្ច កើតឡើងនៅពេលដែលបុគ្គលនោះបានចាប់កំណើត និងរលត់ទៅវិញនៅពេលដែលបុគ្គលនោះស្លាប់។ យោងតាមក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាបានបែងចែករូបវន្តបុគ្គលជាពីរគឺ នីតិជន និងអនីតិជន។

[19] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៦

[20] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៤

[21] ហ៊ី សោភា,នីតិព្រហ្មទណ្ឌ,ទំព័រ២៧

### ២.១.១. នីតិជន

ជាគោលការណ៍ "នីតិភាព" នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។[22] នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺនាំឱ្យបុគ្គលដែលបានប្រព្រឹត្តបទល្មើសទទួលខុសត្រូវរាល់អំពើរបស់ខ្លួននៅចំពោះមុខច្បាប់ ដោយជាក់ស្តែងប្រជាពលរដ្ឋគ្រប់រូប មានការយល់ដឹងច្រើនអំពីច្បាប់ថាអំពើដែលខ្លួនបានធ្វើនោះខុសច្បាប់ ឬមិនខុសច្បាប់។ នេះបញ្ជាក់ថាបទដ្ឋានអន្តរជាតិ ដែលមានលក្ខណៈជាសកលបានទទួលស្គាល់យ៉ាងច្បាស់ថា បុគ្គលដែលអាចមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវមានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅដែលជានីតិជន។ តាមន័យទូទៅ នីតិជនសំដៅដល់បុគ្គលអាយុគ្រប់តាមច្បាប់កំណត់ ហើយមានសមត្ថភាពឯករាជ្យខាងអំពើ ហើយមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគិតពិចារណានូវអំពើដែលខ្លួនបានប្រព្រឹត្ត រួមទាំងមានសមត្ថភាពខាងផ្លូវច្បាប់គ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌជាការប្រកាន់យក និងទទួលស្គាល់ជាលក្ខណៈគតិយុត្តពីរដ្ឋថា មនុស្សម្នាក់មានលទ្ធភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។ ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌជាការប្រកាន់យក និងទទួលស្គាល់ជាលក្ខណៈគតិយុត្ត ពីរដ្ឋថាមនុស្សម្នាក់មានលទ្ធភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌបាន នៅពេលឈានទៅដល់អាយុកំណត់ដោយជននោះពុំស្ថិតនៅក្នុងករណី គ្មានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវបានស្តែងឡើងតាមទោសព្រហ្មទណ្ឌ ឬទណ្ឌកម្មព្រហ្មទណ្ឌដែលត្រូវប្រកាសដោយតុលាការព្រហ្មទណ្ឌ។

#### ក. ការទទួលខុសត្រូវព្រហ្មទណ្ឌ

តាមក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ថា រាល់បុគ្គលទាំងអស់ដែលចាត់ទុកជានីតិជន គឺចាប់ពីអាយុ ១៨ឆ្នាំ ឡើងទៅ។ ដោយយោងទៅតាម មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌបានបង្ហាញអំពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី ១៨ឆ្នាំ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។[23]

ឧទាហរណ៍៖ លោក ក ជានីតិជនដែលមានអាយុ១៨ឆ្នាំ បានប្រើប្រាស់អំពើហិង្សាដោយចេតនាទៅលើលោក ខ ដែលបង្កឱ្យលោក ខ រងរបួសជាទម្ងន់ហើយលោក ក ត្រូវបានសមត្ថកិច្ចចាប់ខ្លួនទៅកាន់តុលាការ។ ដូច្នេះហើយដោយយោងទៅតាមក្រមព្រហ្មទណ្ឌ មាត្រា២១៧ បទហិង្សាដោយចេតនា បានចែងថា៖ អំពើហិង្សាប្រព្រឹត្តដោយចេតនាលើអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល។

[22] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៨

[23] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៨

យោងតាមមាត្រា និងអង្គហេតុខាងលើឃើញថាអំពើខាងលើរបស់លោក ក គឺបានប្រព្រឹត្តអំពើល្មើសទៅលើលោក ខ ដោយចេតនាក្នុងគោលបំណងឱ្យជនរងគ្រោះមានរបួសស្នាម។ ដូច្នេះហើយលោក ក គឺត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនូវអំពើដែលខ្លួនបានប្រព្រឹត្ត គឺបទហិង្សាដោយចេតនា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌចូលជាធរមាន។

**ខ. អានុភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ**

បុគ្គលគ្រប់រូបដែលបានប្រព្រឹត្តបទល្មើស គឺត្រូវតែទទួលខុសត្រូវទៅតាមអ្វីដែលខ្លួនបានធ្វើ ដោយពុំមានអ្នកណាអាចទទួលទោសជំនួសបាននោះឡើយ។ ប្រសិនបើមានបទល្មើសបានទៅដល់គោលដៅហើយ គេនិយាយថាបទល្មើសនេះបានសម្រេច ហើយការចាប់ជនល្មើសដែលបានប្រព្រឹត្តបទល្មើសបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ឬបង្កភាពអសន្តិសុខដល់សណ្តាប់ធ្នាប់សង្គមត្រូវតែមកទទួលទោសព្រហ្មទណ្ឌ ដែលជាវិធានការតឹងតែងបំផុតមួយរបស់រដ្ឋ។ ហើយចរិតលក្ខណៈនៃការទទួលទោសព្រហ្មទណ្ឌ ជាសញ្ញាមួយនៃបទល្មើសឱ្យឃើញនូវភាពជាក់ស្តែងថា ទោសព្រហ្មទណ្ឌ គឺតែងតែមានការផ្សាភ្ជាប់ជាមួយបទល្មើសដែលជាប្រភេទ អំពើរំលោភបំពានច្បាប់ បង្កអន្តរាយ គ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គមជាតិ។ ប៉ុន្តែពុំមែនបានន័យថា រាល់គ្រប់ជនដែលបានប្រព្រឹត្តបទល្មើសទាំងអស់សុទ្ធសឹងតែត្រូវបានទទួលនូវទោសព្រហ្មទណ្ឌនោះឡើយ គឺបានន័យថានៅក្នុងករណីមួយចំនួនដែលជនល្មើសបានប្រព្រឹត្ត ហើយពុំអាចចាប់បង្ខំឱ្យទទួលរងនូវទោសព្រហ្មទណ្ឌនាពេលអាជ្ញាយុកាលនៃទោសត្រូវបានរលត់។

ឧទាហរណ៍៖ ក្នុងករណីមួយបុរសម្នាក់បានប្រព្រឹត្តអំពើរំលោភទៅកាន់នារីម្នាក់បានសម្រេច។ បើយោងតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ បទល្មើសនេះ គឺត្រូវទោសដាក់ពន្ធនាគារដែលមានអាជ្ញាយុកាលពី ៥ (ប្រាំ) ឆ្នាំទៅ ១០ (ដប់) ឆ្នាំ ប៉ុន្តែក្នុងករណីដែលជនបង្កបានធ្វើការរត់គេចខ្លួនបាត់ ហើយសម្របពេលនោះដែលមន្ត្រីនគរបាលយុត្តិធម៌មិនអាចចាប់ជនល្មើសដែលបង្កហេតុបានក្នុងរយៈពេលដែលច្បាប់បានកំណត់នោះមានន័យថាជនល្មើសនោះ គឺត្រូវរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនូវចំពោះមុខច្បាប់នូវអំពើ ដែលខ្លួនបានប្រព្រឹត្ត។

**២.១.២. អនីតិជន**

អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬ ជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។ ម្យ៉ាងវិញទៀត អនីតិជន ដែលលើកឡើងក្នុងចំណុចនេះសំដៅទៅលើ អនីតិជនដែលអាចមានលទ្ធភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ពោលគឺអនីតិជនលើសពី ១៤ (ដប់បួន) ឆ្នាំ និងក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំជាគោលការណ៍។ ចំពោះបទល្មើសដែលកើតឡើងមិនសុទ្ធតែជាអំពើរបស់រូបវន្តបុគ្គលដែលជានីតិជនទេ តែយើងក៏ឃើញថារូបវន្តបុគ្គលមួយចំនួន ដែលពុំទាន់ដល់នីតិភាពនៅឡើយនោះបានប្រព្រឹត្តបទល្មើស។ រូបវន្តបុគ្គលដែលមិនទាន់ដល់នីតិភាពនេះត្រូវបានចាត់ទុកថាជា អនីតិជន។

តាមន័យទូទៅ អនីតិជន ជាជនដែលស្ថិតនៅក្រោមមើលថែរបស់អាណាព្យាបាល ដោយជននោះមិនទាន់យល់ដឹង និងវិនិច្ឆ័យពីអំពើរបស់ខ្លួនបានពេញលេញតាមផ្លូវច្បាប់បាននោះទេ ព្រមទាំងមិនដឹងខុសត្រូវនៅអំពើដែលកំណត់ថាជាបទល្មើសនៅឡើយ។ ជាទូទៅ អនីតិជន ឬកុមារតែងទទួលបានសិទ្ធិជាមូលដ្ឋាន តាំងចាប់កំណើតមកម្ល៉េះ ដែលឪពុកម្ដាយ មានភារកិច្ចចិញ្ចឹមកូន ផ្ដល់កន្លែងស្នាក់នៅ ការអប់រំ ផ្ដល់អាហារ និងទំនុកបម្រុងកូនសព្វបែបយ៉ាង។[24]

**គ. ការទទួលខុសត្រូវព្រហ្មទណ្ឌ**

យោងតាមមាត្រា៣៨ នៃក្រមព្រហ្មទណ្ឌបានចែងថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។[25] ដូច្នេះទាល់តែជនល្មើសមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ទើបតុលាការអាចផ្ដន្ទាទោសផ្នែកព្រហ្មទណ្ឌបាន។ ទោសព្រហ្មទណ្ឌ គឺសំដៅទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ជនល្មើស ដែលជាអនីតិជនក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ ប៉ុន្តែតុលាការអាចចាត់វិធានការមួយចំនួនដើម្បីអប់រំកែប្រែជនល្មើស។

វិធានការទាំងនេះមានដូចជា៖

- ការប្រគល់អនីតិជនទៅឱ្យឪពុកម្ដាយ ឬអាណាព្យាបាលដើម្បីអប់រំ
- ការហាមឃាត់មិនឱ្យទៅកន្លែងណាមួយ ឬជួបបុគ្គលណាមួយ ដូចជាមិនឱ្យជួបជនរងគ្រោះនៃបទល្មើស ឬក៏មិនឱ្យជួបអ្នកសមគំនិតផ្សេងទៀត
- ការបញ្ជូនអនីតិជនទៅដាក់មណ្ឌលកែប្រែ។

ទោះជាយ៉ាងណាវិធានការទាំងនេះមិនមែនជាទណ្ឌកម្មព្រហ្មទណ្ឌនោះទេ ពីព្រោះថាជាគោលការណ៍អនីតិជនមិនមានការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ក៏ប៉ុន្តែមាត្រា៣៩ នៃក្រមព្រហ្មទណ្ឌបានចែងថាតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។[26] នេះមានន័យថាច្បាប់ទុកលទ្ធភាពឱ្យចៅក្រមជាអ្នកពិនិត្យ និងវាយតម្លៃលើករណីជាក់ស្ដែងថា តើបទល្មើសត្រូវបានប្រព្រឹត្តក្នុងកាលៈទេសៈបែបណា? តើជនល្មើសជាអនីតិជននោះ (អនីតិជនអាយុចន្លោះពី ១៤ ទៅ ១៨ ឆ្នាំ) មានបុគ្គលិកលក្ខណៈបែបណា ដែលចាំបាច់ត្រូវតែប្រកាសទោសព្រហ្មទណ្ឌដែរឬទេ? ក៏ប៉ុន្តែក្នុងករណីចៅក្រមសម្រេចដាក់ទោសព្រហ្មទណ្ឌ ដែលក្រមព្រហ្មទណ្ឌបានកំណត់ថា ទោសនោះត្រូវតែកាត់បន្ថយពាក់កណ្ដាលពីទោសធម្មតា (មាត្រា១៦០)។

[24] សន្ធានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧, លេខរៀង ១៨៧

[25] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៨

[26] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩

ឧទាហរណ៍៖ ក្នុងករណីបទឃាតកម្មធម្មតាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ។ ក៏ប៉ុន្តែ ចំពោះជនល្មើសជាអនីតិជន អាយុចន្លោះពី ១៤ឆ្នាំ ទៅ ១៨ឆ្នាំ ទោសគឺត្រូវកាត់បន្ថយពាក់កណ្តាល គឺមកត្រឹម ពី ៥ឆ្នាំ ទៅដល់ ៧ឆ្នាំកន្លះវិញ។ ក្នុងករណីបទល្មើស ដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត គឺត្រូវកាត់បន្ថយមក ត្រឹម ២០ឆ្នាំវិញ ។ ទោសពិន័យជាប្រាក់ក៏ត្រូវកាត់បន្ថយពាក់កណ្តាលដូចគ្នាដែរ។[27]

**ក.១. អនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ**

ចំពោះអនីតិជនមានអាយុ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ នៅពេលដែលអនីតិជនប្រភេទនេះបានប្រព្រឹត្ត បទល្មើស គឺត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តនោះ។ ហើយបានប្រព្រឹត្តបទលហុ ពុំមានការទទួល ខុសត្រូវព្រហ្មទណ្ឌផងដែរ ដោយមន្រ្តីនគរបាលមានសមត្ថកិច្ចគ្រាន់តែយកអនីតិជននោះធ្វើការអប់រំណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរបន្ទាប់មកប្រគល់អនីតិជននោះឱ្យអ្នកតំណាងដែលច្បាប់បាន កំណត់ ឬអ្នកទំនុកបម្រុង។ ក្នុងករណីដែលអនីតិជនសារភាពនូវកំហុសរបស់ខ្លួន គេអាចអនុវត្តវិធានការ សម្រុះសម្រួលគ្នារវាងភាគីដើម្បីបញ្ចប់វិវាទ។

ក្នុងករណីដែលយល់ឃើញថា អនីតិជនបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ និងមានសមត្ថភាពនៃការទទួល ខុសត្រូវ ក៏ដូចជាមានលទ្ធភាពយល់ដឹងពីចរិតលក្ខណៈគ្រោះថ្នាក់នៃអំពើដែលខ្លួន និងអាចបញ្ជានូវរាល់អំពើ ទាំងនោះ។ បានន័យថា អនីតិជនដែលប្រព្រឹត្តអំពើល្មើសនោះ គឺត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបាន ប្រព្រឹត្ត។ ក្នុងករណីនេះដែរ បើតុលាការសម្រេចឱ្យអនីតិជនដែលប្រព្រឹត្តអំពើល្មើសនោះមកទទួលខុសត្រូវចំពោះ អំពើល្មើសរបស់ខ្លួន ក៏ការទទួលខុសត្រូវនេះមិនមានលក្ខណៈពេញលេញដូចទៅនឹងនីតិជនឡើយ ពោលគឺ ស្ថានភាពដែលអនីតិជនត្រូវទទួលរងគឺ មានកម្រិតស្រាលជាងនីតិជន ហើយដើម្បីអាចផ្តន្ទាទោសលើអនីតិជន បានលុះតែត្រាតែតុលាការធ្វើការត្រួតពិនិត្យពិចារណា ក៏ដូចជាថ្លឹងថ្លែងជាមុនពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃ បទល្មើសដែលអនីតិជននោះបានប្រព្រឹត្ត ក៏ដូចជាពិនិត្យទៅលើបុគ្គលិកលក្ខណៈរបស់អនិតិជននោះផងដែរ ហើយកម្រិតនៃទោសដែលទទួលរង គឺត្រូវបន្ធូរបន្ថយមកត្រឹមកពាក់កណ្តាលនៃទោសពីទោសធម្មតាមាន ន័យថាបើទោសធម្មតា ១០ឆ្នាំ នោះអនីតិជននឹងត្រូវទទួលទោសតែ ៥ឆ្នាំប៉ុណ្ណោះ។

ឧទាហរណ៍៖ មានក្មេងប្រុសម្នាក់មានអាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំបានសកម្មភាពរំលោភសេពសន្ថវៈទៅ លើក្មេងស្រីម្នាក់ដែលមានអាយុ ១៤ (ដប់បួន) ឆ្នាំដែលសកម្មភាពដែលក្មេងប្រុសនោះបានប្រព្រឹត្តជាទង្វើមួយ ដែលមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយបានអះអាងថាខ្លួនគ្មានចេតនាប្រព្រឹត្ត និងមិនដឹងពីអ្វី ដែលខ្លួនបានប្រព្រឹត្តនោះទេ។ បើយោងតាមមាត្រា២៣៩ បទរំលោភសេពសន្ថវៈ នៃក្រមព្រហ្មទណ្ឌបានចែងថា គ្រប់អំពើបញ្ចូលអង្គជាតិ តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតិ ដែលប្រព្រឹត្ត

[27] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៦០

ទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយប្រើប្រាស់ហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្លក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ។ បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ទោសពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ។ នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ។[28] ដូចនេះហើយចំពោះអំពើល្មើសដែលអនីតិជនបាននោះបានប្រព្រឹត្ត គឺត្រូវទទួលទោសតាមការកំណត់របស់ច្បាប់ដែលមានចែងជាធរមាន ហើយចំពោះដែលត្រូវអនុវត្តលើអនីតិជនគឺត្រូវបន្ថយមកត្រឹមពាក់កណ្ដាល បើធៀបទៅនឹងការអនុវត្តទោសចំពោះនីតិជន។

**ក.២. អនីតិជនអាយុក្រោម១៤ឆ្នាំ**

អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំមិនអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះទៅឱ្យឪពុកម្ដាយ អាណាព្យាបាល ឬក្នុងករណីគ្មានអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំមើលថែរក្សាបណ្ដោះអាសន្ន រងចាំសេចក្ដីសម្រេចរបស់តុលាការ។ បើយោងតាមមាត្រា១៤ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន បានចែងថា អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់។[29] ជាមួយគ្នានេះ មាត្រា២៧ កថាខណ្ឌទី១ នៃច្បាប់ដដែល ក៏បានចែងដែរថា ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំគិតមកត្រឹមថ្ងៃសង្ស័យថាបានប្រព្រឹត្តបទល្មើសនោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឱ្យអ្នកតំណាងដែលច្បាប់វិញភ្លាម។[30] សូមបញ្ជាក់ផងដែរថា អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គឺមិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នឡើយ។

ដូចនេះហើយ តាមខ្លឹមសារខាងលើយើងអាចសន្និដ្ឋានបានថាអនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំ ជាកម្រិតអាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គឺមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។

ឧទាហរណ៍៖ មានក្មេងៗមួយក្រុមដែលមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំមានផ្ទះរស់នៅក្បែរគ្នា ជាធម្មតារៀងរាល់ថ្ងៃពួកគេលេងជាមួយគ្នា។ ប៉ុន្តែថ្ងៃមួយនៅពេលដែលពួកគេលេងជាមួយគ្នាសុខៗស្រាប់តែមានក្មេងប្រុសម្នាក់ដែលមានអាយុ ១២ (ដប់ពីរ) ឆ្នាំបានក្រវីដំបងលេងធ្វើឱ្យប៉ះក្បាលក្មេងប្រុសម្នាក់រហូតបែកក្បាលងងឹតមុខដួល។ ក្នុងករណីនេះដែរ ក្មេងប្រុសដែលបានប្រព្រឹត្តខុសធ្វើឱ្យមិត្តភក្តិមានរបួសនោះ គឺមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ដោយហេតុថាក្មេងប្រុសម្នាក់បង្កហេតុទើបតែមានអាយុ ១២ (ដប់ពីរ) ឆ្នាំ

[28] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៣៩

[29] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, មាត្រា១៤ កថាខណ្ឌទី១

[30] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, មាត្រា២៧ កថាខណ្ឌទី១

ប៉ុណ្ណោះដែលជាហេតុមួយដែលធ្វើឱ្យគេពុំទាន់មានការយល់ដឹងច្បាស់លាស់នូវទង្វើអចេតនារបស់គេដែលបានប្រព្រឹត្តទៅកាន់មិត្តភក្តិ។

គួរបញ្ជាក់បានផងដែរថាអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ សច្ចធារណ៍មិនអាចប្រកែកនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលរារាំងមិនឱ្យតុលាការធ្វើការប្រកាសទោសទៅលើអនីតិជនបាននោះទេ។ ប៉ុន្តែមិនមែនបានន័យថា បានរារាំងដល់ការចូលខ្លួនមកកាន់តុលាការ និងការប្រកាសសេចក្តីសម្រេចនោះទេ។ ក្នុងខ្លឹមសារនេះបានន័យថាតុលាការក៏នៅតែអាចធ្វើការកោះហៅអនីតិជននោះ ឱ្យចូលខ្លួនមកកាន់តុលាការបានផងដែរ តែក្នុងគោលបំណងដើម្បីប្រកាសសេចក្តីសម្រេចដាក់ឱ្យអនុវត្តនូវវិធានការណាមួយដែលតុលាការបានធ្វើការសម្រេចមកលើអនីតិជនរូបនោះ ហើយវិធានការទាំងនោះមាន វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ឬក៏ប្រគល់អនីតិជននោះទៅឱ្យសាច់ញាតិ សេវាសាធារណៈ អង្គការឯកជនដែលមាននីតិសម្បទា មន្ទីរពេទ្យ ឬស្ថាប័នឯកទេស និងដាក់អនីតិជននោះឱ្យស្ថិតក្រោមការការពាររបស់តុលាការបានផងដែរ។

### ខ.ប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

ព្រហ្មទណ្ឌ គឺជាគោលការណ៍មួយប្រភេទដែលចែងមកសម្រាប់ដាក់ទោសដល់រាល់បុគ្គលទាំងឡាយដែលបានប្រព្រឹត្តផ្ទុយពីបទប្បញ្ញត្តិច្បាប់ ជាពិសេសនោះគឺក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះហើយ នៅពេលមានបទល្មើសមួយកើតឡើង គឺត្រូវតែមានអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។

ជាគោលការណ៍ គេមិនអាចឱ្យជនដែលមិនដឹងខុសត្រូវពី ភាពធ្ងន់នៃអំពើរបស់ខ្លួនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ ព្រោះថាការយល់ដឹងខុសត្រូវពីអំពើរបស់ខ្លួន គឺជាកត្តាមួយដែលនាំឱ្យបុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ហេតុនេះហើយបានជាក្រមព្រហ្មទណ្ឌកម្ពុជាចែងយ៉ាងច្បាស់ ដែលក្នុងនោះ មាត្រា៣៨ បានចែងថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។[31]

យើងបានដឹងហើយថាច្បាប់បាន កំណត់ពីការទទួលខុសត្រូវព្រហ្មទណ្ឌថា ទាល់តែអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅទើបទទួលខុសត្រូវ ដោយហេតុថាអាយុក្រោម ១៨(ដប់ប្រាំបី) ឆ្នាំ គឺជាអនីតិជន ដែលការយល់ដឹងរបស់ពួកគាត់នៅខ្វះខាតនៅឡើយ។ ប៉ុន្តែចំណុចនេះអាចពិបាកដោយហេតុថាក្នុងករណីដែលមានអនីតិជនអាយុក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរណាមួយ។ ហេតុនេះហើយទើបមាត្រា៣៩ នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តិបន្ថែមទៀតថា តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។

[31] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៨

មានន័យថា អនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំដល់ ១៨ (ដប់ប្រាំបី) ឆ្នាំអាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើរបស់ខ្លួនប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់ឱ្យបានច្បាស់លាស់ឡើយ អំពីពាក្យថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនឡើយ ហេតុដូចនេះហើយនៅពេលជួបប្រទះនូវករណីណាមួយ ច្បាប់បានផ្តល់សិទ្ធិពិសេសដល់តុលាការ (ឆន្ទានុសិទ្ធិ) ក្នុងការពិចារណាថា អនីតិជននោះត្រូវទទួលខុសត្រូវ ឬក៏អត់ចំពោះទង្វើល្មើសច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន។ ប៉ុន្តែតាមខ្លឹមសារមាត្រា៣៩ ដដែលមានន័យថាសម្រាប់អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវបាន តុលាការព្រហ្មទណ្ឌប្រកាសឱ្យទទួលទោសបានឡើយ។[32]

ជាទូទៅរាល់អនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលប្រព្រឹត្តបទល្មើសទាំងអស់ តុលាការអាចសម្រេចដាក់គាត់ក្នុងវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដែលមានដូចជា៖

១. ការប្រគល់អនីតិជនទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សា អនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះស័ក្តិសមនឹងទំនុកចិត្ត។

២. ការប្រគល់អនីតិជនឱ្យទៅសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។

៣. ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។

៤. ការប្រគល់អនីតិជនឱ្យទៅមន្ទីពេទ្យ ឬស្ថាប័នឯកទេស។

៥. ការដាក់អនីតិជនឱ្យនៅក្រោមការការពាររបស់តុលាការ ដែលក្នុងករណីនេះ តុលាការនឹងចាត់តាំងបុគ្គលមួយរូបដែលត្រូវទទួលភារៈធ្វើការតាមដានអនីតិជន។[33]

បុគ្គលនេះផ្ញើរបាយការណ៍ស្តីពីកិរិយាមាយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជាអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំឱ្យមានការកែប្រែនូវវិធាននេះ។ ផ្ទុយទៅវិញ ប្រសិនបើតុលាការយល់ឃើញថា កាលៈទេសៈរបស់បទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវនោះបានន័យថាអនីតិជននោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ដែលតុលាការត្រូវប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជននោះ។ ក្នុងករណីនេះក្រមព្រហ្មទណ្ឌបានកំណត់យ៉ាងជាក់លាក់នូវទោសដែលអាចអនុវត្តចំពោះអនីតិជនបាន កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនដែលមានបញ្ញត្តិនៅក្នុងមាត្រា១៦០

[32] រៀបរៀងដោយ ៖ លោកមេធាវី សេង ឈុនលី និងលោក ឡេង ពុទ្ធិតារា ជាសមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយ

[33] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤០

ថាកាលណាតុលាការសម្រេចផ្ដន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ។ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបន្ថយក្នុងលក្ខខណ្ឌដូចខាងក្រោម៖

១. អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្ដាល។

២.ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ។

៣. អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ។

៤. អប្បបរមា និងអតិបរមា នៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល។

ក្នុងករណីការចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទបញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយ អតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំនោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។ ក្រៅពីមូលទោសតុលាការក៏អាចប្រកាសទោសបន្ថែម និងទោសការងារសហគមន៍បានផងដែរ ដែលចំណុចនេះមានបទប្បញ្ញត្តិក្នុងមាត្រា១៦១ និង១៦២ នៃក្រមព្រហ្មទណ្ឌ។

សរុបមកឱ្យតែមានការប្រព្រឹត្តបទល្មើសមួយឡើង ពិតណាស់វាតែងតែបង្កឱ្យមានព្យសនកម្ម ឬការខូចខាតផ្សេងៗ ដែលជាមូលហេតុមួយតម្រូវឱ្យមានការទទួលខុសត្រូវពីអ្នកដែលប្រព្រឹត្តឡើងនោះ ចំពោះអំពើរបស់ខ្លួន។ ប៉ុន្តែជាបទប្បញ្ញត្តិដោយឡែក ច្បាប់ក៏បានកំណត់នូវគោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌដាច់ដោយឡែកសម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើសជៀសវាងប៉ះពាល់ដល់សិទ្ធិ ក៏ដូចជាបង្កនូវការលំបាកដល់អនីតិជន ដែលជាគោលការណ៍អនីតិជនត្រូវបានគាំពារយ៉ាងខ្លាំងដោយច្បាប់ជាពិសេសនោះ គឺច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។[34]

**គ. ការអនុវត្តទោស**

ចំពោះការអនុវត្តទោសនៃក្រមព្រហ្មទណ្ឌនេះផងដែរត្រូវបានបែងចែកជាបីប្រភេទគឺ មូលទោស ទោសបន្ថែម និងទោសជំនួស។

**គ.១. មូលទោស**

មូលទោស គឺជាទោសដែលចៅក្រមអាចយកទៅសម្រេចដាច់តែឯង ដោយមិនចាំបាច់បញ្ជូននូវទោសបន្ថែម ឬទោសជំនួសក៏បានដែរ ពោលគឺជាទោសដែលសំខាន់ជាងគេ។ គ្រប់បទល្មើសទាំងអស់សុទ្ធតែត្រូវផ្ដន្ទាទោស យ៉ាងហោចណាស់ដោយមូលទោសមួយ។ ទោសភ្ជាប់ចាំបាច់ទៅនឹងបទល្មើសមួយ។ នៅក្នុងក្រមព្រហ្មទណ្ឌ មូលទោសចែកចេញជាពីរប្រភេទគឺ៖

[34] រៀបរៀងដោយ ៖ លោកមេធាវី សេង ឈុនលី និងលោក ឡេង ពុទ្ធិតារា ជាសមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយ

- ទោសដាក់ពន្ធនាគារ
- ទោសពិន័យជាប្រាក់។[35]

ទោសដាក់ពន្ធនាគារ គឺជាទោសដាក់គុកដែលដកសិទ្ធិសេរីភាព មានកំណត់កាលដែលត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារ។ កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ។

ទោសពិន័យជាប្រាក់ គឺជាទោសដែលចៅក្រមជំនុំជម្រះប្រកាសឱ្យជនជាប់ចោទបង់ប្រាក់ចូលរដ្ឋតាមការកំណត់ឱ្យបង់ ហើយការពិន័យត្រូវគិតជាប្រាក់រៀល។ កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល។ ឧទាហរណ៍៖ ការប្រើប្រាស់អំពើហិង្សាទៅលើអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។ ការពិន័យបែបនេះហៅថាមូលទោស។

**គ.២. ទោសបន្ថែម**

ទោសបន្ថែម ឬអនុទោស គឺជាទោសដែលតុលាការប្រកាសបន្ថែមទៅលើមូលទោស។[36] ទោសបន្ថែមអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់។ ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន។ ទោសបន្ថែមត្រូវជាកាតព្វកិច្ចប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់។

ឧទាហរណ៍៖ លោក ក ជាគ្រូពេទ្យ ហើយលោក ក បានប្រព្រឹត្តខុសទៅនឹងវិជ្ជាជីវៈរបស់ខ្លួន ដែលបណ្តាលឱ្យអ្នកជំងឺរងគ្រោះកាន់តែធ្ងន់ធ្ងរ។ ដូចនេះយោងតាមមាត្រា៥៣ តុលាការអាចប្រកាសទោសបន្ថែមដោយហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ដែលបានប្រព្រឹត្តក្នុងពេលប្រកបវិជ្ជាជីវៈ ឬព្យួរអាជ្ញាប័ណ្ណរបស់គាត់ជាដើម។

ទោសបន្ថែម ឬអនុទោសដូចជា៖

១.ការដកសិទ្ធិខ្លះជាពលរដ្ឋ។

២.ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ។

៣.ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ។

---

[35] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៣

[36] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥៣

៤.ការព្យួរលិខិតបើកបរ។

៥.ការហាមឃាត់ចំពោះការស្នាក់នៅ។

៦.ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

៧.ការហាមឃាត់ចំពោះការចូល និងស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស។

៨.ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។

៩.ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។

១០.ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។

១១.ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលប្រព្រឹត្តបទល្មើស។

១២.ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត។

១៣.ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤.ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

១៥.ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស។

១៦.ការឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន។

១៧.ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។

១៨.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១៩.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយ ទូរគមនាគមន៍ សោតទស្សន៍។

ក្រៅពីទោសបន្ថែមដែលបានរៀបរាប់ខាងលើក៏មានទោសបន្ថែមដែលមានចែងក្នុងច្បាប់ដោយឡែកដែរ។ ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១,២,៣,៤,៥,៦ និង ៧ ខាងលើនេះ ត្រូវអនុវត្តនៅពេលផុតទោសពន្ធនាគារ លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់តុលាការ។

**គ.៣. ទោសជំនួស**

ទោសជំនួស សំដៅលើទោសជាការងារសហគមន៍ ឬការស្តីបន្ទោសដែលជំនួសឱ្យមូលទោស។[37] តុលាការ ដែលប្រកាសទោសជាការងារសហគមន៍ ឬការស្តីបន្ទោស ពុំអាចប្រកាសទោសដាក់ពន្ធនាគារ ឬ

[37] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៧២

ទោសពិន័យជាប្រាក់បានទេ។ តុលាការពុំអាចប្រកាសទោសជំនួសទាំងពីរនេះត្រួតគ្នាបានឡើយ។ មូលហេតុដែលសម្រេចអំពីទោសជំនួស ដោយឡែកផ្អែកទៅលើគោលការណ៍មនុស្សធម៌ គេអាចពិនិត្យទៅលើស្ថានភាពកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ដើម្បីមិនអនុវត្តទោសជាមូលដ្ឋាន ដោយយកទោសជំនួសមកអនុវត្តវិញ។ នៅពេលចៅក្រមយល់ឃើញថា ទោសដាក់ពន្ធនាគារពុំត្រូវបានបង្ហាញទេ (ដោយមានមូលហេតុមកពីយុវភាពនៃជនជាប់ចោទ) ហើយទោសពិន័យក៏ពុំអាចអនុវត្តបានដែរ (ដោយប្រៀបធៀបទៅនឹងធនធានរបស់ជនជាប់ចោទ) ចៅក្រមអាចប្រកាសទោសជំនួសវិញ។ ចៅក្រមអាចប្រកាសទោសសហគមន៍ តែក្នុងករណីដែលជនជាប់ចោទមានវត្តមាននៅក្នុងសវនាការ ហើយព្រមបំពេញការងារនោះប៉ុណ្ណោះ។ នៅមុនពេលប្រកាសសេចក្ដីសម្រេចរបស់ខ្លួន ចៅក្រមត្រូវដាស់តឿនដល់ជនជាប់ចោទថា ខ្លួនអាចបដិសេធមិនធ្វើការងារនេះ ហើយចម្លើយរបស់ជនជាប់ចោទត្រូវតែចុះក្នុងសេចក្ដីសម្រេចរបស់តុលាការ។ គួរគូសបញ្ជាក់ផងដែលថាតុលាការដែលប្រកាសទោសការងារសហគមន៍ត្រូវតែកំណត់ចិរវេលានៃការងារនេះ និងរយៈពេលត្រូវបំពេញ ហើយរយៈពេលនេះមិនអាចលើសពី ០១ (មួយ) ឆ្នាំឡើយ។ បែបបទនៃការអនុវត្តទោសការងារសហគមន៍ ស្ថិតនៅក្នុងសមត្ថកិច្ចរបស់ស្ថាប័នអយ្យការ មានន័យថាព្រះរាជអាជ្ញាមានសមត្ថកិច្ចចង្អុលប្រាប់ឈ្មោះបុគ្គលដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ និងការត្រួតពិនិត្យលើការអនុវត្តការងារនេះ។ រីឯការស្ដីបន្ទោសវិញ លុះត្រាតែជនជាប់ចោទរងទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្ដីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ៖

- ភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈដែលបណ្ដាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលរួមរស់នៅក្នុងសង្គមវិញ។

ឧទាហរណ៍ ៖ លោក ក បានប្រព្រឹត្តអំពើលួចរបស់អ្នកដទៃ។ យោងតាមមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ អំពើលួចត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។ ក៏ប៉ុន្តែដើម្បីជាការជំនួសនូវមូលទោស គឺទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ខាងលើ តុលាការអាចឱ្យលោក ក ធ្វើការងារសហគមន៍ចំនួន ១០០ (មួយរយ) ម៉ោង ដោយមិនទទួលបានប្រាក់កម្រៃមកវិញទេ។ ក្នុងករណីនេះដែលលោក ក នឹងមិនត្រូវទទួលរងទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់នោះទេ គឺលោក ក គ្រាន់តែធ្វើការងារសហគមន៍ជំនួសតែប៉ុណ្ណោះ។

សរុបមកវិញយោងតាមស្មារតីរបស់ក្រមព្រហ្មទណ្ឌ ដែលបានបែងចែកប្រភេទនៃការអនុវត្តទោសគឺ មានគោលដៅច្បាស់លាស់ដើម្បីកំណត់ និងគិតគូរយ៉ាងល្អិតល្អន់អំពីព្យសនកម្ម ឬភាពធ្ងន់ធ្ងរដែលបណ្ដាលឱ្យប៉ះពាល់ ឬខូចប្រយោជន៍ដល់បុគ្គល និងសង្គមជាតិជាដើម។ លើសពីនេះទៅទៀតទោសនីមួយៗបង្កើតឡើងដើម្បី

ធានាដល់ការដាក់ទណ្ឌកម្មទៅលើជនល្មើសឱ្យបានសមស្របទៅតាមបទល្មើសដែលបុគ្គលបានប្រព្រឹត្ត។ ប៉ុន្តែការប្រកាសទោសសទៅបានលុះត្រាតែ ជននោះបានប្រព្រឹត្តខុសទៅនឹងច្បាប់ដែលមានចែងជាធរមាន។

## ២.២. បុគ្គលដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ

### ២.២.១ ចារី

និយមន័យនៃចារី យោងតាមមាត្រា២៥ នៃក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ថា ត្រូវចាត់ទុកជាចារីចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។[38] ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម។

ចារីនៃបទល្មើស គឺជាជនដែលប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ ឬជនដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ (តាមន័យសាមញ្ញ)។ ចារីត្រូវបានច្បាប់ចាត់ទុកជាបុគ្គលដែលសំខាន់នៅក្នុងការប្រព្រឹត្តបទល្មើសពីព្រោះថាបើសិនជាគ្មានចារីទេ នោះក៏គ្មានបទល្មើសកើតឡើងនោះដែរ។

ឧទាហរណ៍៖ បុរស ក បានប្រព្រឹត្តបទល្មើសមួយដោយបានប្រើប្រាស់ដំបងវាយទៅកាន់បុរស ខ ដែលបណ្តាលឱ្យបុរស ខ បែកក្បាល ។ ដូចនេះហើយបុរស ក ជាចារី។

### ២.២.២. សហចារី

និយមន័យនៃសហចារី យោងតាមមាត្រ២៦ នៃក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ថា ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។[39] ត្រូវបានចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក។ សហចារីនៃបទល្មើស គឺជាជនដែលបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់ជាមួយចារី ហើយស្ថិតក្នុងកាលៈទេសៈ និងទីកន្លែងតែមួយជាមួយចារី (តាមន័យសាមញ្ញ)។

សហចារីនៃបទល្មើស គឺជាជនដែលបានចូលរួម និងមានសកម្មភាពប្រព្រឹត្តអំពើល្មើសដោយផ្ទាល់ជាមួយចារី ហើយស្ថិតក្នុងកាលៈទេសៈ និងទីកន្លែងតែមួយជាមួយចារី។

ឧទាហរណ៍៖ ក្រុមក្មេងស្ទាវបីនាក់ ក,ខ,គ បានសម្រេចចិត្តព្រមព្រៀងគ្នាក្នុងការធ្វើសកម្មភាពប្រើប្រាស់អំពើហិង្សាទៅលើបុរសម្នាក់ ដើម្បីប្លន់ម៉ូតូបានសម្រេច។ នៅក្នុងករណីនេះដែលក្រុមក្មេងស្ទាវទាំងបីនាក់ ក,ខ,គ ត្រូវបានសន្មតថាជាសហចារីក្នុងការប្រព្រឹត្តអំពើល្មើសប្លន់ទៅលើបុរសម្នាក់នោះ។

[38] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៥

[39] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៦

### ២.២.៣. អ្នកផ្តើមគំនិត

និយមន័យនៃអ្នកផ្តើមគំនិត ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនៃមាត្រា២៨ បានចែងថា ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែល៖

១. ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះតាមការណែនាំ ឬការបញ្ជា។

២. បង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។[40] អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកផ្តើមគំនិតនៃគំនិត ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ ។ អ្នកផ្តើមគំនិត គឺជាអ្នកដែលចាប់ផ្តើមគំនិត ការគិតទុច្ចរិតណែនាំ បញ្ជា ញុះញង់ និងគំរាមកំហែង ឬជាការលួងលោមឱ្យប្រព្រឹត្តបទល្មើសជាដើម។ រាល់អំពើទាំងអស់របស់អ្នកផ្តើមគំនិត ទោះបីជាការប្រព្រឹត្តនោះជាការធ្វើដោយផ្ទាល់ក្តី ឬតាមរយៈការប្រើប្រាស់សម្ភារៈអេឡិចត្រូនិចក្តី ឬតាមរយៈឱ្យអ្នកដទៃប្រព្រឹត្តអំពើជំនួសក្តី ក៏ត្រូវចាត់ទុកជាអ្នកផ្តើមគំនិត ហើយត្រូវទទួលទោសដូចគ្នាទៅនឹងចារីផងដែរ។

ឧទាហរណ៍៖ បុរស ក មានគំនុំជាមួយ បុរស ខ ដែលបានប្រើប្រាស់ពាក្យសម្តីមិនសមរម្យមួយចំនួនមកកាន់ខ្លួន ដោយកំហឹងមួយឆាវបុរស ក បានជួលបុរស គ ដើម្បីធ្វើការសម្លាប់ទៅកាន់បុរស ខ ហើយប្រសិនបើការងារជោគជ័យបុរស ក និងឱ្យប្រាក់មួយចំនួនទៅកាន់បុរស គ។ នៅក្នុងករណីនេះ បុរស ក ជាអ្នកផ្តើមគំនិតត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចចារីដែរ។

### ២.២.៤. អ្នកសមគំនិត

និយមន័យអ្នកសមគំនិត នៃក្រមព្រហ្មទណ្ឌត្រង់មាត្រា២៩ បានចែងថា ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួល ដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។[41] អ្នកសមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចចារីដែរ។ អ្នកសមគំនិត គឺជាអ្នកដែលជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសឱ្យកើតមានឡើងតាមរយៈនៃការផ្តល់ជាជំនួយ ការឧបត្ថម្ភជាសម្ភារៈ ឬមធ្យោបាយផ្សេងៗ បានន័យថាអ្នកសមគំនិត គឺមិនបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់ទេ តែជាអ្នកដែលបានដឹងឮ និងចំណែកមួយដើម្បីសម្រួលឱ្យមានភាពងាយស្រួលដល់ការប្រព្រឹត្តនូវបទល្មើស។ ទោះបីអ្នកសមគំនិតមិនបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់ ក៏ច្បាប់បានកំណត់ផ្តន្ទាទោសចារីដែរ។

[40] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៨

[41] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៩

ឧទាហរណ៍៖ បុរស ក បានដឹងឮថាបុរស ខ មានបំណងក្នុងការសម្លាប់ទៅកាន់បុរស គ ដោយហេតុថាបុរស ក ដឹងឮពីគោលបំណងរបស់បុរស ខ រួចហើយ ប៉ុន្តែនៅតែបានឱ្យបុរស ខ ខ្ចីកាំបិតទៀត។ នៅក្នុងករណីមួយនេះដែលបុរស ក គឺមានឋានៈជាអ្នកសមគំនិត។

# ជំពូកទី២

# ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ
# របស់រូបវន្តបុគ្គល

# ជំពូកទី២

# ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

## ផ្នែកទី១៖ មូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

នៅពេលដែលបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើស នោះត្រូវទទួលខុសត្រូវនូវអំពើរបស់ខ្លួន។ ប៉ុន្តែ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីស្ថានភាពមួយចំនួនដែលបុគ្គលនោះ បានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពទាំងនោះ នឹងអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន ដែលស្ថានភាពទាំងនោះ អាចបណ្តាលមកពីបញ្ញាស្មារតីរបស់ជនល្មើស ឬអំពើដែលច្បាប់ កំណត់ថាសមហេតុផល។

ក្នុងករណីបុគ្គលម្នាក់បានប្រព្រឹត្តនូវអំពើឈ្លានពាន ប៉ះពាល់ទៅនឹងបុគ្គលម្នាក់ទៀត ដែលច្បាប់បាន បញ្ញត្តិថាអំពើនោះជាបទល្មើសព្រហ្មទណ្ឌ នោះជនបង្កនឹងត្រូវទទួលទោសទៅតាមអំពើដែលខ្លួនបានប្រព្រឹត្ត ប៉ុន្តែក៏នៅមានមូលហេតុមួយចំនួនដែលក្រមព្រហ្មទណ្ឌមិនតម្រូវឱ្យមានការទទួលខុសត្រូវឡើយ។ មូលហេតុទាំងឡាយនៃការមិនទទួលខុសត្រូវទាំងស្រុង មានលក្ខណៈរួមមួយ។ ប្រាកដណាស់ អំពើទាំងឡាយដែលត្រូវបានប្រព្រឹត្តជាលក្ខណៈសំភារៈ បង្កើតបានជាបទល្មើស ទោះជា បទល្មើសឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុក៏ដោយ។ ប៉ុន្តែ ចារីនៃអំពើទាំងនេះ ពុំស្ថិតនៅក្រោមអំណាចនៃច្បាប់ព្រហ្មទណ្ឌឡើយ ចំពោះបុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ។[42]

### ១.១. មូលហេតុអត្តនោម័ត

ការមិនទទួលខុសត្រូវដោយមូលហេតុអត្តនោម័តរួមមាន ជនវិបល្លាសស្មារតី និងអានុភាពនៃកម្លាំងបង្ខំ ឬការបង្ខំ (ការបង្ខំលើផ្លូវចិត្ត និងបង្ខំលើរូបរាងកាយ)។ ធាតុអត្តនោម័ត គឺជាផ្នែកខាងក្នុងនៃបទល្មើស ដែលផ្ទុយទៅនឹងធាតុសត្យានុម័តដែលជាផ្នែកខាងក្រៅនៃបទល្មើស។ ធាតុអត្តនោម័ត ជាកិរិយាផ្លូវចិត្តរបស់ជនល្មើស ចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ។

ធាតុអត្តនោម័ត មានកត្តារួមផ្សំចំនួន ៣ (បី) គឺ កំហុសចេតនា ឬអចេតនា គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស និងគោលដៅនៃការប្រព្រឹត្តបទល្មើស។[43]

បើយើងក្រឡេកមើលក្នុងក្រមព្រហ្មទណ្ឌ បានចែង ផងដែរថា ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ [44] នេះជាគោលការណ៍សំខាន់បំផុតមួយរបស់បទល្មើសព្រហ្មទណ្ឌ ដែលថាជនណាម្នាក់នឹងអាចត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌបាន លុះត្រាតែមានធាតុផ្សំមួយនេះដែរ ពោលគឺជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌ

[42] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៧

[43] សំណួរ-ចម្លើយសម្រាប់ការត្រៀមប្រឡងផ្សេងៗរៀបចំដោយបណ្ណាគារភក្តីឡុង

[44] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤ កថាខណ្ឌទី១

ឡើយ បើខ្លួនមិនមានចេតនាក្នុងការប្រព្រឹត្ត ឬចេតនាទុច្ចរិត ឬហៅថាពិរុទ្ធារម្មណ៍នោះ។ ជាឧទាហរណ៍៖ តារា បានច្រឡំយកទូរស័ព្ទ របស់មិត្តរួមថ្នាក់ទៅផ្ទះគាត់ ពីព្រោះម៉ាកទូរស័ព្ទរបស់ពួកគេដូចគ្នា និងដាក់លើតុគ្រូជៀក គ្នាទៀត ដោយសារវាជាពេលប្រលងទៀតផង។ ក្នុងករណីនេះ តារាមិនមានទោសពីបទលួចដូចមានចែងក្នុង ក្រមព្រហ្មទណ្ឌទេ ពីព្រោះគាត់គ្មានចេតនា យកទូរស័ព្ទគេមកធ្វើជាកម្មសិទ្ធិរបស់គាត់ឡើយ តែវាជាការភាន់ ច្រឡំប៉ុណ្ណោះ។ ទោះបីជាយ៉ាងនេះក្តី ក៏មានការលើកលែង ឬហៅម្យ៉ាងទៀតថាអញ្ញត្រកម្ម ដែលផ្ទុយពី គោលការណ៍ទូទៅ។ នេះចង់សំដៅថា ទោះបីជាមិនមានចេតនាក៏ដោយ តែបើក្នុងករណីដែលមានច្បាប់ចែង ទុកជាមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរព កាតព្វកិច្ចដោយឡែកណាមួយ។[45]

ឧទាហរណ៍៖ មានបុរសពិការភ្នែកម្នាក់បានដើរឆ្លងថ្នល់ ស្របពេលដែលអ្នកបើកបរកំពុងតែនិយាយ ទូរស័ព្ទ ព្រមជាមួយនឹងការបើកល្បឿនហួសកំណត់ផង ទើបរថយន្តបានបុកបុរសពិការដែលកំពុងឆ្លងថ្នល់នោះ និងបណ្តាលឱ្យបាត់បង់ជីវិត។ ក្នុងករណីបែបនេះ ទោះបីជាអ្នកបើកបររថយន្តនោះមិនមានចេតនាសម្លាប់បុរស ពិការនោះក៏ដោយ ក៏គាត់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទមនុស្សឃាតដោយអចេតនាដែរ ព្រោះគាត់មានការ ធ្វេសប្រហែស និងបំពានកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ដោយបើកគាត់លើសល្បឿនកំណត់ ដែលបណ្តាល ឱ្យជនរងគ្រោះមានគ្រោះថ្នាក់ដល់ជីវិត។ បទមនុស្សឃាតដោយអចេតនា (មាត្រា២០៧)។

### ១.១.១. ជនវិបល្លាសស្មារតី

វិបល្លាសស្មារតី សំដៅដល់ស្ថានភាពមួយធ្វើឱ្យបាត់បង់ ឬប៉ះពាល់ដល់ការដឹងខុសត្រូវ ការបន្ថយសមត្ថភាព យល់ដឹងរបស់អ្នកប្រព្រឹត្ត។ នៅក្នុងច្បាប់វិបល្លាសស្មារតីក្នុងក្រមព្រហ្មទណ្ឌញែកស្ថានភាពជាពីរគឺ វិបល្លាស ស្មារតីប៉ះពាល់ទាំងស្រុងដល់ការយល់ដឹង និងវិបល្លាសស្មារតីមិនប៉ះពាល់ទាំងស្រុងទេតែបន្ថយការយល់ដឹង។ ជាការកត់សម្គាល់ នៅក្នុងការសិក្សាមុខវិជ្ជានីតិព្រហ្មទណ្ឌ គេមិនឃើញមានការកំណត់ឱ្យច្បាស់ពីប្រភេទនៃ មនុស្សវិកលចរិតឡើយ។ ទោះជាយ៉ាងនេះក្តី គេឃើញនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា កំណត់ថាជនវិបល្លាសស្មារតី ត្រូវបានចែកចេញជាពីរ គឺជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ ជននៅក្រោម អាណាព្យាបាលទូទៅ ជនស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង នៃសកម្មភាព របស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។ ជាមួយគ្នានេះ ជននៅក្រោមហិតូបត្ថម្ភ មានន័យថា ជនដែល មានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិ ផ្នែកបញ្ញាស្មារតី។ ភស្តុតាងដែលសំខាន់បំផុតក្នុងការវិនិច្ឆ័យទៅលើវិបល្លាសស្មារតីនេះ ពឹងផ្អែកលើរបាយការណ៍

[45] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤ កថាខណ្ឌទី២

វេជ្ជសាស្ត្រ។ ក្រៅពីរបាយការណ៍វេជ្ជសាស្ត្រយើងក៏អាចពិនិត្យផងដែរទៅលើអង្គហេតុផ្សេងដែលពាក់ព័ន្ធនឹងសកម្មភាពរស់នៅប្រចាំថ្ងៃរបស់បុគ្គលនោះមុនពេលកើតហេតុ។

**ក. វិបល្លាសស្មារតីដែលបាត់បង់ការយល់ដឹងទាំងស្រុង**

ជាគោលការណ៍បុគ្គលត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនបានប្រព្រឹត្តហើយអំពើ ដែលខ្លួនបានប្រព្រឹត្តនោះមានចែងក្នុងបញ្ញត្តិព្រហ្មទណ្ឌជាធរមាន។ ការកើតមានវិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់ការយល់ដឹង យោងតាមក្រមព្រហ្មទណ្ឌបានចែងអំពីការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី៖ "កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ"។[46] ក្នុងករណីខាងលើនេះ បុគ្គលម្នាក់ដែលវិកលចរិតបានប្រើអំពើហិង្សាលើអ្នកដទៃ ដែលជាការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

ឧទាហរណ៍៖ លោក ក ដែលជាមនុស្សវិកលចរិតអចិន្ត្រៃយ៍បានវាយ លោក ខ ឱ្យមានរបួស។ ដូច្នេះនៅពេលដែលជនណាម្នាក់បានប្រព្រឹត្តបទល្មើស ហើយតុលាការវិនិច្ឆ័យថាបាត់បង់ការយល់ដឹងទាំងស្រុង ឬវិកលចរិតទាំងស្រុង។ ករណីនេះ ជនវិកលចរិតនោះ នឹងមិនត្រូវបានផ្តន្ទាទោសពីច្បាប់ព្រហ្មទណ្ឌឡើយ បើសិនជាមានភស្តុតាងបញ្ជាក់ថាគាត់ពិតជាគ្មានសមត្ថភាពដឹងខុសត្រូវពិតប្រាកដមែន។

**ខ. វិបល្លាសស្មារតីដែលបន្ថយការនូវការយល់ដឹង**

វិបល្លាសស្មារតី ដែលជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវតែជាវិបល្លាសដែលបានបំផ្លាញចោលទាំងស្រុងនូវសមត្ថភាពក្នុងការយល់ដឹងរបស់ចារី (លទ្ធភាពក្នុងការយល់ន័យនៃអំពើរបស់ខ្លួន ឬការយល់ដឹងខុសត្រូវក្នុងការប្រព្រឹត្តអំពើ) ឬបំផ្លាញចោលទាំងស្រុងនូវសមត្ថភាពក្នុងការត្រួតពិនិត្យសកម្មភាពរបស់ខ្លួន។ ប្រសិនបើចារីមានវិបល្លាសស្មារតី ដែលត្រឹមតែបន្ថយនូវការដឹងខុសត្រូវរបស់គាត់តែប៉ុណ្ណោះ ក៏ប៉ុន្តែស្ថានភាពនេះគាត់នៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែលអាចក្លាយជាស្ថានភាពសម្រាលទោសសម្រាប់ចារីបាន។

វិបល្លាសស្មារតីដែលបន្ថយការនូវការយល់ដឹង សំដៅទៅលើជនទាំងឡាយណាដែលកើតមានវិបល្លាសស្មារតីម្តងម្កាលតាមស្ថានភាពជាក់ស្តែង មិនមែនមានវិបល្លាសស្មារតីជាប្រចាំថ្ងៃនោះឡើយ។ ក្នុងក្រមព្រហ្មទណ្ឌបានចែងអំពីការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតីដែលបន្ថយការយល់ដឹង៖ "ការបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលបន្ថយការយល់ដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ប៉ុន្តែតុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស"។[47]

[46] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣១ កថាខណ្ឌទី១

[47] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣១ កថាខណ្ឌទី២

ឧទាហរណ៍៖ លោក ក ជាមនុស្សវិកលចរិត ប៉ុន្តែមានពេលខ្លះលោក ក គាត់ជាមនុស្សធម្មតា ដែលអាចយល់ដឹងខុសត្រូវ ដូច្នេះប្រសិនបើ លោក ក គាត់ប្រព្រឹត្តបទល្មើសក្នុងពេលដែលគាត់អាចយល់ដឹងខុសត្រូវនោះ លោក ក មិនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានទេ។ ដូច្នេះដើម្បីកំណត់ធ្ងន់ ឬស្រាលនៃទោសទៅលើចារីនៃអំពើនោះឱ្យកាន់តែច្បាស់ ចៅក្រមត្រូវគិតពិចារណាថ្លឹងថ្លែងអំពីកម្រិតនៃការយល់ដឹងជាមុនសិន។ ប្រសិនបើជននោះកើតវិបល្លាសស្មារតីដែលបន្ថយការយល់ដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តដដែល។

**គ. វិបល្លាសស្មារតីដោយការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន**

បុគ្គលម្នាក់ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ស្របពេលដែលខ្លួនស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន ឬគ្រឿងស្រវឹង ទោះប្រព្រឹត្តអំពើក្នុងស្ថានភាពគ្រប់គ្រងខ្លួនឯងមិនបានក៏ដោយ គេមិនអាចចាត់ទុកថាបុគ្គលនោះជាជនមានវិបល្លាសស្មារតីនោះទេ ពោលគឺជននោះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌជាធរមាន។

វិបល្លាសស្មារតីដែលកើតចេញពីការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង និងថ្នាំដែលច្បាប់ហាមឃាត់ ច្រើនតែកើតចេញពីឆន្ទៈផ្ទាល់របស់ចារីតែម្តង។

លើសពីនេះទៅទៀត សៀវភៅរបស់លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ បង្ហាញដែរថា បញ្ហាចោទឡើងចំពោះការប្រើប្រាស់ថ្នាំផ្សេងៗ ដែលមានឥទ្ធិពលប៉ះពាល់ដល់ប្រព័ន្ធប្រសាទដូចជា គ្រឿងញៀន សុរា ឬថ្នាំផ្សេងៗទៀតជាដើម។ ការប្រើប្រាស់ថ្នាំទាំងអស់នោះច្រើនពេកអាចធ្វើឱ្យខូចខាតដល់ប្រព័ន្ធសរសៃប្រសាទគ្រប់គ្រងខ្លួនមនុស្សមួយរយៈពេលបាន។ ប៉ុន្តែការកំណត់ថាការប្រើប្រាស់គ្រឿងបំពុលនេះជាមូលហេតុនៃការមិនទទួលខុសត្រូវ បានបង្កជាចំណោទមួយដ៏លំបាកស្មុគស្មាញពីព្រោះថា ការប្រើប្រាស់គ្រឿងបំពុលច្រើនតែកើតចេញពីឆន្ទៈរបស់អ្នកប្រើប្រាស់តែម្តង។[48]

នៅពេលដែលជនមានវិបល្លាសស្មារតីដោយការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនបានប្រព្រឹត្តបទល្មើសដោយចេតនាក្តី ឬអចេតនាក្តី ច្បាប់ព្រហ្មទណ្ឌពុំអាចលើកលែងការទទួលខុសត្រូវរបស់អំពើដែលជននោះបានប្រព្រឹត្តនោះបានឡើយ ពីព្រោះបទល្មើសទាំងនេះកើតឡើងដោយសារការធ្វេសប្រហែសរបស់ចារីនៃអំពើ។ យោងតាមក្រមព្រហ្មទណ្ឌមាត្រា៣១ កថាខណ្ឌទី៣ បានចែងអំពីការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតីដោយការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន៖ "កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដោយការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ"។[49]

---

[48] ដកស្រង់ចេញពីសៀវភៅរបស់លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ

[49] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣១ កថាខណ្ឌទី៣

ឧទាហរណ៍៖ បុរសម្នាក់បានសេពគ្រឿងស្រវឹងបណ្តាលឱ្យបាត់បង់សតិអារម្មណ៍គ្រប់គ្រងខ្លួនឯងមិនបាន បុរសម្នាក់នោះក៏បានចាប់រំលោភសេពសន្ថវៈលើនារីម្នាក់។ ជាលទ្ធផលបុរសនោះ មិនអាចរកលេសថាមូលហេតុនោះកើតចេញមកពីការស្រវឹង ពោលគឺបុរសម្នាក់នោះ ត្រូវតែទទួលខុសត្រូវនូវអំពើរបស់ខ្លួនដដែល។

### ១.១.២. អានុភាពនៃកម្លាំង ឬការបង្ខំ

យោងតាមក្រមព្រហ្មទណ្ឌមាត្រា៣៦ ចែងថា៖ បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។[50] កម្លាំង ឬការបង្ខំ អាចចេញមកពីព្រឹត្តការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំង ឬការបង្ខំនេះ ត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន។[51]

អានុភាពនៃកម្លាំង ឬការបង្ខំ គឺសំដៅដល់ជនម្នាក់ណាដែលកំពុងស្ថិតនៅក្នុងស្ថានភាពបង្ខំពីជនណាម្នាក់ក្នុងការធ្វើអ្វីមួយ ដោយពុំអាចជៀសវាងបាន ហើយបុគ្គលនោះពុំអាចទប់ស្កាត់នឹងកម្លាំងនោះបានក៏ប្រព្រឹត្តបទល្មើសនោះទៅ។ ឧទាហរណ៍៖ បុរស ក បានបើកបរដឹកអ្នកដំណើរពីភ្នំពេញទៅកំពត ស្រាប់តែក្នុងអំឡុងពេលបើកបរមាន ភ្លៀងធ្លាក់ ខ្យល់ព្យុះ បណ្តាលឱ្យដើមឈើដួលរលំលើឡាន បណ្តាលឱ្យអ្នកដំណើររងរបួសស្រាល និងធ្ងន់ធ្ងរជាច្រើននាក់។ ក្នុងករណីនេះដែលអ្នកបើកបរមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ដោយហេតុស្តែងចេញពីឆន្ទៈខាងក្រៅរបស់អ្នកបើកបរនោះតែប៉ុណ្ណោះ។

ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ មិនបានឱ្យនិយមន័យលើពាក្យ អានុភាពនៃកម្លាំង ឬការបង្ខំឡើយ។ ចំណែកឯក្រមព្រហ្មទណ្ឌចាស់កម្ពុជា ឆ្នាំ១៩៦៧ វិញ ក៏មិនបានប្រើពាក្យអានុភាពនៃកម្លាំង ឬការបង្ខំទេ។ ប៉ុន្តែបានឱ្យនិយមន័យ នៃពាក្យនេះនៅមាត្រា៩៦ កាលបើមានភស្តុតាងយ៉ាងដូច្នេះថាមានកម្លាំងអ្វីមួយបានបង្ខំជនណាម្នាក់ឱ្យប្រព្រឹត្តបទល្មើសអ្វីមួយហើយជននោះកាលមិនអាចទប់ទល់នឹងកម្លាំងនោះបានទេ ក៏ប្រព្រឹត្តបទល្មើសនោះទៅ។ ជនប្រព្រឹត្តបទល្មើសនេះមិនត្រូវឱ្យទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តឡើយ។[52]

បើយើងក្រឡេកមើលស្ថានភាពជាក់ស្តែង ត្រង់មាត្រា៩៧ នៃក្រមព្រហ្មទណ្ឌចាស់ ចែងថា៖ គ្រោះថ្នាក់ដែលកើតឡើងដែលត្រូវធ្លាក់មកលើខ្លួនក្នុងអំឡុងពេលមិនអាចជៀសផុតពីគ្រោះថ្នាក់បាន តែជននោះមិនបានប្រព្រឹត្តបទល្មើសនោះទេ ដោយម្យ៉ាងទៀតគ្រោះថ្នាក់នោះកើតឡើងដោយមិនមែនកើតចេញពីឆន្ទៈផ្ទាល់របស់ចារីនៃបទល្មើស វាកើតចេញដោយឆន្ទៈក្រៅខ្លួនរបស់ចារី ដូច្នេះចារីរួចផុតពីការទទួលខុសត្រូវនោះបាន។[53]

---

[50] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៦ កថាខណ្ឌទី១

[51] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៦ កថាខណ្ឌទី២

[52] ក្រមព្រហ្មទណ្ឌចាស់ ឆ្នាំ១៩៦៧, មាត្រា៩៦

[53] ក្រមព្រហ្មទណ្ឌចាស់ ឆ្នាំ១៩៦៧, មាត្រា៩៧

**ក. លក្ខខណ្ឌនៃកម្លាំង ឬការបង្ខំ**

កម្លាំង ឬការបង្ខំ អាចកើតចេញតែពីហេតុការណ៍ខាងក្រៅឆន្ទៈរបស់មនុស្សប៉ុណ្ណោះ ហើយការបង្ខំ ឬកម្លាំងនេះ ត្រូវតែមិនអាចប៉ាន់ស្មានទុកជាមុន និងមិនអាចទប់ទល់បាន។ ការបង្ខំ បង្កើតបានជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដោយហេតុថាការបង្ខំនេះលុបចោលនូវឆន្ទៈ ពីព្រោះចារីត្រូវស្ថិតនៅក្នុងស្ថានភាពមួយដែលពុំមានជម្រើសផ្សេងក្រៅពីប្រព្រឹត្តនូវអ្វីដែលខ្លួនបានប្រព្រឹត្ត។

តាមការពិត ការបង្ខំនេះ បង្កើតបានជាករណីប្រធានសក្តិមួយសម្រាប់ចារី ក្នុងការទទួលបាននូវសេរីភាព។

**ខ. ប្រភេទនៃកម្លាំង ឬការបង្ខំ**

ជាទូទៅ គេចាត់ទុកថា កម្លាំង ឬការបង្ខំ មានពីរប្រភេទ គឺការបង្ខំលើរូបកាយ និងការបង្ខំលើផ្លូវចិត្ត ដើម្បីឱ្យក្លាយជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។

ការបង្ខំលើរូបកាយ អាចនៅខាងក្នុង ឬនៅខាងក្រៅ។ តាមពិតអាចមានករណីដែលគេពុំអាចប្រព្រឹត្តអ្វីផ្សេងបាន ដោយហេតុថាមានកាលៈទេសៈខាងក្រៅដែរដាច់ខាតពុំអាចជំនះបាន។ ឧទាហរណ៍៖ អំពើហឹង្សារបស់ជនដទៃ។

**ខ.១. កម្លាំងបង្ខំលើរូបកាយ**

កម្លាំងបង្ខំលើរូបកាយ សំដៅលើកម្លាំងណាមួយលើរូបកាយចារី ដែលជាហេតុនាំឱ្យចារីត្រូវតែប្រព្រឹត្តអំពើដោយខ្លួនពុំអាចឃាត់ឃាំងអំពើនោះបានឡើយ។[54]

ការបង្ខំមកពីកម្លាំងពីខាងក្រៅ ដូចជា កម្លាំងមកពីព្រឹត្តិការណ៍ធម្មជាតិ មកពីសត្វ ឬមកពីតតិយជនណាមួយ ដែលពុំអាចឃាត់ឃាំងអំពើនោះបាន។

ឧទាហរណ៍៖ ខ្យល់ព្យុះ ឬរន្ទះបាញ់ ជាដើម។ ពេលខ្លះ កាលៈទេសៈខាងក្រៅមានប្រភពចេញមកពីធម្មជាតិ។

ឧទាហរណ៍៖ យោធិនម្នាក់ បានបើកបរធ្វើដំណើរទៅកាន់បន្ទាយវិញ ស្រាប់តែអំឡុងពេលបើកបរមានខ្យល់ព្យុះ ភ្លៀងបក់បោកយ៉ាងខ្លាំង ធ្វើឱ្យគាត់គ្រប់គ្រងការបើកបររបស់គាត់មិនបាន ក៏បានបុកបុរសម្នាក់ស្លាប់។ ជនបង្កមិនត្រូវដាក់ទោសបានឡើយ ដោយសារមូលហេតុនៃអំពើគ្រោះថ្នាក់ មិនបានកើតពីឆន្ទៈខ្លួន ពោលគឺការដែលបណ្តាលឱ្យរថយន្តជ្រុលចង្កូតទៅបុកអ្នកដទៃវាកើតឡើងពីកម្លាំងធម្មជាតិនោះទេ។

ក្រៅពីនេះការបង្ខំក៏អាចមានប្រភពមកពីខាងក្នុងសុទ្ធសាធផងដែរ។

ឧទាហរណ៍៖ បុរសម្នាក់គាត់បានបើកបរទៅភ្នំពេញ ក្នុងអំឡុងពេលបើកបរគាត់ខ្យល់គរ ពេលនោះគាត់រកកន្លែងឈប់សិន ប៉ុន្តែគាត់ងងឹតមុខមើលផ្លូវមិនច្បាស់ ហើយពេលនោះគាត់មិនអាចគ្រប់គ្រងការបើកបរគាត់

[54] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៣

បានក៏បានបុកស្ត្រីម្នាក់បណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ។ ស្ថានភាពនេះ កើតចេញពីស្ថានភាពខាងក្នុងផ្ទាល់របស់ចារីនៃអំពើផ្ទាល់តែម្តង ដែលចារីនោះមិនត្រូវផ្តន្ទាទោសព្រហ្មទណ្ឌឡើយ។ ហេតុនេះគេមិនអាចសន្និដ្ឋានបានថាជំងឺរបស់ចារីនៃអំពើនោះ គឺជាព្រឹត្តការណ៍កើតចេញពីឆន្ទៈរបស់ចារីនោះទេ។ នៅក្នុងគ្រប់ករណីទាំងនេះ មានកម្លាំងដែលចារីពុំអាចទប់ទល់បាន ដោយចារីមិនអាចគ្រប់គ្រងលើវាសនារបស់ខ្លួនបានឡើយ។

**ខ.២. កម្លាំងបង្ខំលើផ្លូវចិត្ត**

កម្លាំងបង្ខំលើផ្លូវចិត្ត សំដៅទៅដល់កម្លាំងដែលបង្ខំឆន្ទៈរបស់ចារីឱ្យប្រព្រឹត្តបទល្មើស។[55] ហើយព្រឹត្តការណ៍ក្រៅឆន្ទៈនេះដែរ ចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ដោយសារតែការប្រព្រឹត្តរបស់ចារីមិនអាចជៀសវាងបានឡើយ។[56]

ការបង្ខំខាងផ្លូវចិត្តវិញ ការបង្ខំនេះអាចលើកលែងចារីនៅពេលដែលការបង្ខំនេះមានប្រភពមកពីខាងក្រៅ។ ដូច្នេះនៅក្នុងករណីដែលចារីបានប្រព្រឹត្ត ដោយមានការគំរាមកំហែងដ៏ច្បាស់លាស់ ប្រឆាំងនឹងខ្លួនរបស់ចារី ឬប្រឆាំងនឹងតតិយជន ជននោះអាចមិនទទួលខុសត្រូវព្រហ្មទណ្ឌ។[57] ប៉ុន្តែត្រូវមានភស្តុតាងបញ្ជាក់ថា ការគំរាមកំហែងនេះពិតមានលក្ខណៈផ្ទុយច្បាប់ប្រាកដមែន។

ឧទាហរណ៍៖ អ្នកដឹកជញ្ជូនប្រាក់ត្រូវគំរាមកំហែងដោយជនប្រដាប់អាវុធ ហើយជននេះបង្ខំឱ្យអ្នកដឹកជញ្ជូនប្រាក់ប្រគល់នូវប្រាក់ទាំងអស់ដែលកំពុងដឹកនោះ ជាក់ស្តែងអ្នកដឹកជញ្ជូនពុំទទួលខុសត្រូវពីបទព្រហ្មទណ្ឌចំពោះអំពើនៃការជំរិតទារប្រាក់នេះឡើយ ពីព្រោះថាខ្លួនបានប្រគល់ប្រាក់ទាំងនោះ ក្រោមការគំរាមកំហែងរបស់តតិយជន។

ផ្ទុយទៅវិញ ចំពោះការបង្ខំខាងផ្លូវចិត្តខាងក្នុង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌពុំត្រូវបានគេទទួលស្គាល់ទេ។[58] ជាញឹកញាប់បំផុត ការបង្ខំខាងផ្លូវចិត្តនេះទាក់ទងនឹងសភាពជំងឺផ្នែកតណ្ហា ដែលកំណត់ការប្រព្រឹត្តរបស់ចារី ចំពោះ តណ្ហា កំហឹង ការស្អប់ខ្ពើម ការគុំគួន។ ការបង្ខំខាងផ្លូវចិត្តខាងក្នុងនេះ ពុំមែនជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ លើកលែងករណីជ្រុល ឬសភាពជំងឺដែលឈានទៅរកការបាត់បង់នូវការដឹងខុសត្រូវ ដោយសារតែវិបល្លាសស្មារតី។

ឧទាហរណ៍៖ ដោយសារតែ ការស្អប់ខ្ពើម ការខឹង ការគុំគួន ជំនឿផ្នែកមនោគមវិជ្ជា ឬសាសនាណាមួយបានបង្ខំឱ្យចារីត្រូវតែប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះដែរ ចារីនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ព្រោះថា

[55] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៥

[56] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៥

[57] សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ, មេរៀននីតិព្រហ្មទណ្ឌខ្មែរ (២០០៨), ទំព័រ៤២

[58] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៥

ការប្រព្រឹត្តបទល្មើសនេះ ដោយសារតែការបង្ខំនេះមានប្រភពមកពីព្រឹត្តិការណ៍ក្នុងឆន្ទៈរបស់ចារីនៃអំពើផ្ទាល់តែម្តង។[59]

## ផ្នែកទី២៖ មូលហេតុសត្យានុម័ត

ដើម្បីកំណត់ថាជាបទល្មើសផងដែរ នោះគឺធាតុសត្យានុម័ត ឬហៅថាធាតុសម្ភារៈ គឺសំដៅទៅលើអំពើដែលជនល្មើសបានប្រព្រឹត្តបទល្មើសជាក់ស្តែងដែលចេញមកខាងក្រៅតាមរយៈអំពើ ដែលបង្កជាគ្រោះថ្នាក់ទៅដល់សង្គម។ អំពើដែលបង្កជាគ្រោះថ្នាក់ទៅដល់សង្គម គឺជាអំពើជាក់ស្តែង ឬកាយវិការជាក់ស្តែងរបស់មនុស្សដែលបានស្តែងចេញមកបង្កអន្តរាយមកដល់សង្គម ឬក៏គំរាមបង្កឱ្យមានអន្តរាយដោយទំនាក់ទំនងសង្គមដែលច្បាប់ព្រហ្មទណ្ឌបានការពារ។ ដើម្បីរកឱ្យឃើញអំពីធាតុសត្យានុម័ត តុលាការត្រូវធ្វើការស្រាវជ្រាវ ចាប់យកនៅភស្តុតាងនានា រួចស៊ើបអង្កេតឱ្យដឹងថា សកម្មភាពរបស់ជនល្មើសបានប្រព្រឹត្តបែបណា។ នៅពេលដែលរកឃើញធាតុសត្យានុម័ត ឬហៅថាធាតុសម្ភារៈដែលមានដូចជា ភស្តុតាង អាវុធ និងវត្ថុនានាសម្រាប់ការប្រើប្រាស់ប្រព្រឹត្តបទល្មើស ដែលជនល្មើសបានប្រព្រឹត្តបង្កទៅជាបទល្មើស។ មូលហេតុអត្តនោម័ត នៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌរួមមានដូចជា ជនវិបល្លាសស្មារតី និងអានុភាពកម្លាំងបង្ខំ ហើយអានុភាពនៃកម្លាំងបង្ខំមានដូចជាកម្លាំងបង្ខំលើផ្លូវកាយ និងកម្លាំងបង្ខំលើផ្លូវចិត្ត ទាំងអស់នេះហើយ គឺជាមូលហេតុអត្តនោម័ត ពីព្រោះថាធាតុអត្តនោម័តមានន័យថាជាកិរិយាផ្លូវចិត្តរបស់ជនល្មើស ចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ៉។[60] តុលាការអាចដាក់ទោសបាន លុះត្រាតែមានការពិនិត្យទៅលើធាតុអត្តនោម័ត គឺសំដៅទៅលើសកម្មភាពខាងក្នុងនៃជនល្មើស ដូចជាការប្រព្រឹត្តរបស់ជនល្មើសនោះដោយចេតនា ឬអចេតនា ជនល្មើសនោះមានវិបល្លាសស្មារតីបែបណា ទើបតុលាការវិនិច្ឆ័យថាក្នុងការឱ្យជននោះទទួលខុសត្រូវ ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌនូវអំពើរបស់ជនល្មើសនោះ។

### ២.១. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

យោងតាមមាត្រា៣២ បានចែងថា៖ បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះ មិនប្រព្រឹត្តបទល្មើសទេ។ បុគ្គលណាដែលប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។[61] តាមអត្ថន័យខាងលើនេះ ក្រមព្រហ្មទណ្ឌថ្មីបានបង្ហាញពីអំពើដែលត្រូវបានបញ្ញត្តិថាជាបទល្មើស តែបែរជាមិនមែនបទល្មើសទៅវិញ ដោយមូលហេតុថាអំពើនោះត្រូវបានអនុញ្ញាតដោយច្បាប់ និងមានការអនុញ្ញាតពីអាជ្ញាធរ។ ប៉ុន្តែ ចារី សហចារី អ្នកផ្តើម គំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាម

[59] វុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២), ២៤៦

[60] សៀវភៅស្តីពីការអនុវត្តសម្រាប់សិក្ខាកាមនីតិសាស្ត្រ

[61] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣២ កថាខណ្ឌទី១ និងទី២

មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ៖

១. ជនល្មើសដែលបានប្រព្រឹត្តអំពើដែលបញ្ញត្តិអនុញ្ញាត ឬមិនហាមឃាត់ជនល្មើសនោះដោយច្បាប់ជាធរមាន។

២. បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់។[62]

មាត្រា៩៩ នៃក្រមព្រហ្មទណ្ឌចាស់បានចែងថា៖ មិនទុកជាអំពើល្មើសក្នុងបទព្រហ្មទណ្ឌទេ កាលណាបើអំពើទាំងឡាយនោះធ្វើតាមបង្គាប់ ច្បាប់ ហើយអ្នកបញ្ជាឱ្យធ្វើក៏ជាអាជ្ញាធរជម្មានុរូបដែរ។[63] ក្នុងមាត្រា១០០ នៃក្រមព្រហ្មទណ្ឌចាស់ដដែលបានបញ្ជាក់បន្ថែមថា៖ ក្នុងករណីដែលមានសេចក្ដីបង្គាប់ជាអនីត្យានុកូល ហើយអ្នកបញ្ជាជាអាជ្ញាធរជម្មានុរូបនោះ ចៅក្រមត្រូវថ្លឹងមើលតាមការគួរនូវ ភាពនៃការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌរបស់ភ្នាក់ងារអ្នកសម្រេចការនោះផង។[64]នៅពេលដែលបទល្មើសណាមួយបានកើតឡើង ច្បាប់តែងតែស្វែងរកនូវមូលហេតុ ក៏ដូចជាភស្តុតាងនៃអង្គហេតុឱ្យបានត្រឹមត្រូវ ហើយពេញលេញជាមុនសិនទើបបន្តនីតិវិធីវិនិច្ឆ័យទៅលើអង្គហេតុដែលបានកើតឡើងនោះរហូតឈានដល់ការសម្រេចសេចក្ដីថាបទល្មើស ដែលបុគ្គលនោះបានប្រព្រឹត្តចាត់ទុកជាអំពើល្មើស ឬឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។

### **២.១.១. ច្បាប់**

ការអនុញ្ញាតដោយច្បាប់ គឺជាការផ្ដល់នូវសិទ្ធិក្នុងការធ្វើអ្វីមួយដែលតាមរយៈ ការកំណត់ដោយច្បាប់នេះ បុគ្គលដែលអនុញ្ញាតដោយច្បាប់មិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

ក្នុងករណីនេះច្បាប់បញ្ញត្តិ ឬអនុញ្ញាតឱ្យប្រព្រឹត្តអំពើណាមួយ ហើយច្បាប់មិនអនុញ្ញាតឱ្យផ្ដន្ទាទោសលើអំពើដែលកើតចេញពីការបំពេញកាតព្វកិច្ចតម្រូវដោយច្បាប់។

### **២.១.២. អាជ្ញាធរ**

អាជ្ញាធរ ជាសិទ្ធិស្របច្បាប់ ឬសមត្ថភាពក្នុងការគ្រប់គ្រង ឬជាមនុស្សមួយក្រុមមានការទទួលខុសត្រូវជាផ្លូវការសម្រាប់វិស័យណាមួយ។ អាជ្ញាធរស្របច្បាប់ដែលខ្លួនទទួលបានពេញលេញ។ ក្នុងន័យនេះ គេអាចឱ្យនិយមន័យអាជ្ញាធរស្របច្បាប់ថា សំដៅលើអាជ្ញាធរសាធារណៈ ដែលអាចជា អាជ្ញាធររដ្ឋបាល អាជ្ញាធរតុលាការ ឬអាជ្ញាធរយោធា ដែលមានអំណាចតាមផ្លូវច្បាប់ក្នុងការបញ្ជាឱ្យអនុវត្តច្បាប់ និងលិខិតបទដ្ឋានផ្សេងៗទៀត។ ហេតុនេះមិនត្រូវចាត់ទុកជាអាជ្ញាធរស្របច្បាប់ តាមន័យនៃមាត្រា៣២ នៃក្រមព្រហ្មទណ្ឌកម្ពុជាឡើយ

---

[62] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣២ កថាខណ្ឌទី៣

[63] ក្រមព្រហ្មទណ្ឌចាស់ ឆ្នាំ១៩៦៧, មាត្រា៩៩

[64] ក្រមព្រហ្មទណ្ឌចាស់ ឆ្នាំ១៩៦៧, មាត្រា១០០

ចំពោះ៖ និយោជកនៃក្រុមហ៊ុនមួយ (បញ្ជាឱ្យនិយោជិតធ្វើអ្វីមួយដែលខុសត្រូវច្បាប់) (បញ្ជាឱ្យកូនធ្វើអ្វីមួយដែលផ្ទុយនឹងច្បាប់)។

**ក.អាជ្ញាធរស្របច្បាប់**

អាជ្ញាធរស្របច្បាប់ គឺជាអ្នកទ្រទ្រង់នូវអាជ្ញាធរ អ្នកកាន់អំណាចតាមសិទ្ធិដែលខ្លួនទទួលបានពេញលេញ។ ក្នុងន័យនេះ គេអាចឱ្យនិយមន័យអាជ្ញាធរស្របច្បាប់ថា គឺសំដៅលើអាជ្ញាធរសាធារណៈ ដែលអាចជាអាជ្ញាធររដ្ឋបាល អាជ្ញាធរតុលាការ ឬអាជ្ញាធរយោធា ដែលមានអំណាចតាមផ្លូវច្បាប់ក្នុងការបញ្ជាឱ្យអនុវត្តច្បាប់ និងលិខិតបទដ្ឋានផ្សេងៗទៀត។

អាជ្ញាធរស្របច្បាប់ សំដៅលើអាជ្ញាធរដែលទទួលសិទ្ធិ និងអំណាចតាមការកំណត់ផ្តល់របស់ច្បាប់ អាជ្ញាធរស្របច្បាប់ ក្នុងន័យនេះគឺផ្អែកតាមយុត្តិសាស្ត្រប្រទេសបារាំងដែលបំពេញបន្ថែមសមត្ថកិច្ច។

មាត្រា៣២ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌចែងថា បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជា អំពើខុសច្បាប់យ៉ាងជាក់ច្បាស់។[65]

**ខ. បញ្ជាស្របច្បាប់**

ក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឱ្យជនដែលប្រព្រឹត្តបទល្មើស តាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប្រសិនបើអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។ ឧទាហរណ៍៖ បុរសម្នាក់ត្រូវបានមន្ត្រីសាធារណៈ បញ្ជាឱ្យលើកម៉ូតូ ដែលចតមិនត្រឹមត្រូវតាមទីសាធារណៈ ដោយដាក់រ៉ម៉កដឹកអីវ៉ាន់របស់គាត់យកទៅទីស្នាក់ការ។ នោះម្ចាស់រ៉ម៉កមិនត្រូវបានចោទប្រកាន់ពីបទលួចមានស្ថានទម្ងន់បានឡើយ ពីព្រោះគាត់ទទួលបញ្ជាស្របច្បាប់ពីអាជ្ញាធរដែនដីតែប៉ុណ្ណោះ។ អ្នកទទួលបញ្ជាអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន។[66]

ដោយផ្អែកលើមាត្រា៣២ កថាខណ្ឌទី៣ នៃក្រមព្រហ្មទណ្ឌ៖ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ៖

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្តិ អនុញ្ញាត ឬមិនហាមឃាត់ ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះ បានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់។[67]

[65] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣២

[66] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣២ កថាខណ្ឌទី២

[67] សារណាបញ្ចប់ការសិក្សារបស់ ម៉ាង ណុល និង គង់ សុខហេង (ឆ្នាំ២០១២)

គេឃើញថាបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាបទឧក្រិដ្ឋដែលមានសភាពធ្ងន់ធ្ងរណាស់ ឬបទឧក្រិដ្ឋកម្មសង្គ្រាម ហើយជាឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាល។[68] ទាំងនេះជាអញ្ញត្រកម្ម នៃការបង្ហាញខាងលើ ហើយដែលអ្នកប្រព្រឹត្តបទល្មើសនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។[69]

### ២.១.៣. ការការពារស្របច្បាប់

ការការពារស្របច្បាប់ គឺជាវិធានការមួយ ឬយុត្តិការមួយដែលច្បាប់បានផ្តល់បុព្វសិទ្ធិពិសេសឱ្យទៅបុគ្គលទូទៅនៅក្នុងការការពារខ្លួន ការពារទេព្យសម្បត្តិ និងការពារអ្នកដទៃប្រឆាំងនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។ ក្នុងស្ថានភាពនោះ ទោះបីជាច្បាប់បានប្រគល់បុព្វសិទ្ធិពិសេសនោះក៏ដោយ ប៉ុន្តែច្បាប់កំណត់នូវលក្ខខណ្ឌយ៉ាងតឹងរ៉ឹងក្នុងការអនុវត្តនូវបុព្វសិទ្ធិពិសេសនោះ ដើម្បីអាចឱ្យស្ថានភាពនៃការការពារខ្លួនរួចផុតពីការទទួលខុសត្រូវ ហើយស្ថានភាពនោះស្ថិតនៅក្នុងគ្រោះថ្នាក់មិនអាចគេចបាន។ បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ បទល្មើសក្នុងសភាពការពារស្របច្បាប់នោះ មិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ៖

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

- បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

- គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។[70]

លក្ខខណ្ឌនៃការការពារស្របច្បាប់ទាំងបីខាងលើនេះគឺត្រូវតែផ្គុំ ឬក៏ត្រូវតែបំពេញឱ្យគ្រប់ទាំងអស់។ ទីមួយត្រូវតែមានការឈ្លានពានជាមុន ហើយបទល្មើសដែលប្រព្រឹត្ត ដើម្បីទប់ទល់ទៅនឹងការឈ្លានពាននោះត្រូវចាំបាច់ បានន័យថា បើសិនជាគេអាចជៀសវាងតាមមធ្យោបាយផ្សេង គឺគេចាត់ទុកថាមិនចាំបាច់ឡើយ។ ដូច្នេះគឺគេមានតែផ្លូវមួយគត់ ដើម្បីប្រព្រឹត្តបទល្មើសតទល់ជាមួយនឹងការឈ្លានពានដែលបានកើតឡើងនោះ ឬក៏អាចនិយាយម៉្យាងទៀតបានថាគ្មានជម្រើសចុងក្រោយ ឬជម្រើសណាមួយទេក្រៅពីការតបតទៅវិញនេះ។ ទីពីរត្រូវតែកើតឡើងក្នុងពេលជាមួយគ្នារវាងបទល្មើស និងការឈ្លានពានមានន័យថាត្រូវតែតបតមកវិញភ្លាមៗតែម្តង។ និងទីបីការដែលប្រើប្រាស់នូវមធ្យោបាយការពារនោះ គឺត្រូវសមាមាត្រទៅតាមទំហំគ្រោះថ្នាក់នៃការឈ្លានពានខ្លួននៅពេលអ្នកឈ្លានពាននោះបានវាយមកលើខ្លួន ហើយអ្នកនោះបានរត់ដោយបែរខ្នងទៅ ហើយស្រាប់តែអ្នកត្រូវគេវាយនោះក៏ដកកាំភ្លើងបាញ់ទៀត។ នេះគឺមិនមែនស្ថិតនៅក្នុងការពារស្របច្បាប់ទេ ពីព្រោះថាអ្នកដែលបង្កការឈ្លានពាននោះបានបាត់អស់ទៅហើយ ពិសេសទម្ងន់នៃការឈ្លានពាននោះ គឺមានលក្ខណៈស្រាលទេ ហេតុនេះ

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៩

[69] សារណាបញ្ចប់ការសិក្សារបស់ ម៉ាង ណុល និង គង់ សុខហេង (ឆ្នាំ២០១២)

[70] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៣

វាខុសគ្នាទៅនឹងទ្រឹស្តីនៃការពារទាំងស្រុងតែម្តង។ [71] ជាក់ស្តែងនៅក្នុងស្ថានភាពពេលដែលមានការឈ្លានពានមួយដែលមិនត្រឹមត្រូវបុគ្គល ដែលត្រូវបានគេឈ្លានពានដែលយើងអាចកំណត់បានថាជាអ្នកការពារនោះអាចប្រើប្រាស់នូវសិទ្ធិរបស់ខ្លួន ហើយការប្រើប្រាស់សិទ្ធិរបស់ខ្លួននោះ អាចប្រើប្រាស់នៅគ្រប់មធ្យោបាយទាំងឡាយដើម្បីការពារខ្លួន។

ឧទាហរណ៍៖ នៅពេលដែលមានបុរសម្នាក់បានលួចចូលមកក្នុងផ្ទះនារីម្នាក់ដើម្បីប្លន់ទ្រព្យសម្បត្តិរបស់នារីរងគ្រោះ ដោយបុរសនោះបានគំរាមសម្លាប់បើនារីនោះស្រែក ក្នុងអំឡុងពេលនោះ បុរសនោះកំពុងតែរើសអីវ៉ាន់រកមើលរបស់មានតម្លៃ នារីនោះភ័យពេកក៏ទាញថូផ្កាឈើវាយពីក្រោយជាខ្លាំង បុគ្គលម្នាក់នោះក៏បែកក្បាលដួលសន្លប់។ នេះជាមធ្យោបាយមួយដែលនារីនោះពុំអាចស្រែកឱ្យអ្នកដទៃជួយបាន អាចប្រើមធ្យោបាយនេះដើម្បីយករួចខ្លួន។

**ក. លក្ខខណ្ឌ**

ដោយអនុលោមតាមមាត្រា៣៣ នៃក្រមព្រហ្មទណ្ឌ ច្បាប់មិនបានអនុញ្ញាតឱ្យបុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ ប៉ុន្តែការការពារស្របច្បាប់ នោះត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិដែលប្រឈមមុខនឹងការឈ្លានពានមួយមិនត្រឹមត្រូវ បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និងគ្មានវិសមាមាត្ររវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។

ឧទាហរណ៍៖ នៅពេលដែលមានបុរស ក បានប្រកែកគ្នាជាមួយបុរស ខ យ៉ាងខ្លាំង។ ពេលនោះបុរស គ ក៏បានដើរឆ្លងកាត់ ហើយក៏បានចូលទៅឃាត់ ស្រាប់តែ បុរស ក បានជះកំហឹងដោយបានលោតធាក់ បុរស គ មួយជើង រកវាយមួយដៃទៀត ប៉ុន្តែ បុរស គ បានតបតទៅវិញដោយវាយ បុរស ក ពីរដៃបែកមាត់ និងឈាមច្រមុះផងដែរ។ ករណីខាងលើនេះ បុរស គ គ្រាន់តែការពារខ្លួនពីការឈ្លានពានពីបុរស ក តែប៉ុណ្ណោះ គាត់មិនបានប្រើប្រាស់មធ្យោបាយលើសទម្ងន់នៃការឈ្លានពានពីលោក ក នោះទេ។

**ខ. ការឈ្លានពាន**

កថាខណ្ឌទី២ ត្រង់ចំណុចទី១ មាត្រា៣៣ នៃក្រមព្រហ្មទណ្ឌ ការឈ្លានពានត្រូវកើតឡើងមុនពេលមានការការពារ ពីព្រោះថាអំពើការពារធ្វើឡើងដោយការចាំបាច់ដើម្បីការពារ ប្រឈមមុខនឹង ការឈ្លានពានណាមួយ។

[71] កៅ សីហា នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ អង្គរ ២០១៣), ទំព័រ២៤៨

ការឈ្លានពានជាមុន គឺជាធាតុផ្សំចាំបាច់នៃការការពារស្របច្បាប់។ ការឈ្លានពាននេះអាចធ្វើទៅលើទ្រព្យសម្បត្តិ ឬ រូបកាយរបស់អ្នកការពារផ្ទាល់ ឬទៅលើតតិយជនក៏បានដែរ។[72]

**គ. ការការពារការឈ្លានពាន**

ការការពារទៅនឹងអំពើឈ្លានពានណាមួយ ស្តែងឡើងតាមរយៈការតបតពីសំណាក់ជនដែលទទួលរងនូវការឈ្លានពាននោះ។ អំពើការពារអាចជារូបភាព ប្លែកៗពីគ្នាដូចជា ការសម្លាប់ ការប្រើហិង្សា ការប៉ះពាល់បណ្តាលឱ្យខូចខាតផលប្រយោជន៍អ្នកដទៃជាដើម។ ការប្រព្រឹត្តអំពើខ្លះ មិនត្រូវបានចាត់ទុកថា ជាអំពើការពារនៃការការពារស្របច្បាប់នោះទេឡើយ ដូចជាការរំលោភសេពសន្ថវៈ ឬការធ្វើទារុណកម្មជាដើម។

- ការការពារត្រូវតែកើតឡើងក្នុងពេលជាមួយគ្នានឹងការឈ្លានពាន

ការការពារត្រូវតែកើតឡើងក្នុងពេលជាមួយគ្នានឹងការឈ្លានពាន មានន័យថា ការការពារត្រូវតែធ្វើឡើងភ្លាមៗ ក្នុងខណៈដែលការឈ្លានពានបានកើតឡើង ហើយការតបតទៅនឹងការឈ្លានពាន ក៏ត្រូវតបតភ្លាមៗក្នុងខណៈពេលមានការឈ្លានពានកើតឡើងផងដែរ។

- ការការពារត្រូវតែចាំបាច់

ការការពារត្រូវតែជាការចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ។ ប្រតិកម្មតបតរបស់អ្នកការពារ គឺជាមធ្យោបាយតែមួយគត់ដើម្បីបញ្ចៀសការឈ្លានពាន។

- មធ្យោបាយការពារដែលប្រើប្រាស់ត្រូវតែគ្មានវិសមាមាត្រជាមួយនឹងទម្ងន់នៃការឈ្លានពាន

មធ្យោបាយការការពារដែលបានប្រើប្រាស់ត្រូវតែឆ្លើយតបទៅនឹងភាពធ្ងន់ធ្ងរ នៃការឈ្លានពានមិនត្រឹមត្រូវ។ (មាត្រា៧៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) កាលបើអំពើមួយត្រូវបានចាត់ទុកថាជាការការពារស្របច្បាប់ហើយ ចារីមិនត្រឹមតែមិនទទួលខុសត្រូវព្រហ្មទណ្ឌប៉ុណ្ណោះទេ គឺថែមទាំងត្រូវទទួលខុសត្រូវរដ្ឋប្បវេណីទៀតផង។[73]

**២.១.៤. សច្ចធារណ៍**

សច្ចធារណ៍ គឺជាការសរុបសេចក្តីមួយ ឬជាការធ្វើសេចក្តីសន្និដ្ឋានមួយដែលទាញពីការដឹង ការសង្កេតការពិចារណាអំពីអង្គហេតុ ឬព័ត៌មានខ្លះ។ ដោយយោងតាមអនុលោមមាត្រា៣៤ នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តិថាជាការការពារ ស្របច្បាប់នៅក្នុងករណីដូចតទៅៈ

១. បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។

---

[72] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៣ កថាខណ្ឌទី២

[73] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៧៥៥ កថាខណ្ឌទី១

២. បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ។ សច្ចធារណ៍នេះអាចត្រូវរំលាយដោយភស្តុតាងផ្ទុយ។[74]

ឧទាហរណ៍៖ ម្ចាស់ហាងលក់មាសមួយកន្លែងត្រូវបានចោរ ចូលភ្លន់យកមាសនៅពេកយប់ជ្រៅ ព្រោះចោរមានកាំបិតបានគំរាមសម្លាប់បើតែហៅប៉ូលីស ម្ចាស់ហាងដែលនៅក្នុងបន្ទប់គេងបានភ័យយកកាំភ្លើងបានបាញ់ចោរនោះស្លាប់នៅកន្លែងតែម្តង ករណីនេះប្រសិន បើតុលាការរកឃើញភស្តុតាងដោយផ្អែកលើមាត្រា៣៣ នៃក្រមព្រហ្មទណ្ឌ ថាជាការការពារស្របច្បាប់នោះ ម្ចាស់ហាងអាចរួចផុតពីការទទួលខុសត្រូវ។

គោលការណ៍នៃសច្ចធារណ៍មានដូចជា៖

- សច្ចធារណ៍នៃច្បាប់
- សច្ចធារណ៍មិនអាចបដិសេធបាន
- សច្ចធារណ៍អាចជំទាស់បាន
- សច្ចធារណ៍នៃអង្គហេតុ
- សច្ចធារណ៍ដាច់ស្រេច
- សច្ចធារណ៍នៃនិរទោស
- សច្ចធារណ៍មិនដាច់ស្រេច។

### ២.១.៥. ស្ថានភាពចាំបាច់

ស្ថានភាពចាំបាច់ ករណីដែលមនុស្សម្នាក់ចង់គេចផុតពីគ្រោះអាសន្នជាក់ស្តែងមួយដែលកំពុងគំរាមកំហែងផលប្រយោជន៍របស់រដ្ឋ ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ឬរបស់អ្នកដទៃក្នុងកាលៈទេសៈដែលពុំមានវិធីណាផ្សេងក្រៅពីការធ្វើសកម្មភាពដែលបង្កឱ្យមានការអន្តរាយមួយមានទំហំតូចជាងការអន្តរាយដែលត្រូវបានទប់ស្កាត់។ [75] ការបង្កឱ្យមានការអន្តរាយក្នុងស្ថានភាពនេះពុំមែនជាបទល្មើសឡើយ។ នៅចំពោះមុខស្ថានភាពមួយដែលទាមទារឱ្យមនុស្សត្រូវជំនះឱ្យបាននូវគ្រោះអាសន្នដែលកំពុងគំរាមកំហែងដល់បណ្តាផលប្រយោជន៍ស្របច្បាប់ មានវិធីតែមួយគត់ គឺការបង្កឱ្យមានការអន្តរាយដល់ផលប្រយោជន៍ផ្សេងទៀតដែលក្រមព្រហ្មទណ្ឌបានការពារ ហើយទំហំនៃការអន្តរាយត្រូវតែតូចជាងការអន្តរាយដែលគេបានទប់ស្កាត់។[76] ជារួម ស្ថានភាពចាំបាច់គឺជាស្ថានភាពពិសេសដែលមិនអាចខកខានបានដោយជៀសមិនផុតពីការប្រព្រឹត្តអ្វីមួយ។ បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

[74] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៤

[75] សារណាបញ្ចប់ការសិក្សារបស់ លោក សុធា រស្មី និង លោក ឆៀង វណ្ណៈ (ឆ្នាំ២០១៦)

[76] ជួន ប៊ុនធី , នីតិព្រហ្មទណ្ឌទូទៅ

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

-បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។[77]

បើគេប្រៀបធៀបកម្មវត្ថុ នៃការការពារនៅក្នុងស្ថានភាពចាំបាច់ គឺដូចគ្នាទៅនឹងករណីនៃការការពារស្របច្បាប់បានន័យថា ដូចទាំងការពារខ្លួនដូចទាំងការពារអ្នកដទៃ និងដូចទាំងការពារទ្រព្យសម្បត្តិផងដែរ។

ស្ថានភាពចាំបាច់ គឺជាស្ថានភាពរបស់បុគ្គលម្នាក់ដែលឈានទៅដល់ការប្រព្រឹត្តបទល្មើសណាមួយដោយសារតែមានបំណងចង់ជួយស្តារនូវផលប្រយោជន៍ មួយផ្សេងទៀតដែលត្រូវបានគំរាមកំហែងដោយគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។ ស្ថានភាពចាំបាច់ត្រូវចាត់ទុកជាយុត្តិកម្មនៃបទល្មើសយោងក្រមព្រហ្មទណ្ឌ មាត្រា៣៥ ស្ថានភាពចាំបាច់បានចែងថា បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ចំពោះស្ថានភាពចាំភាពចាំបាច់ចារីមានជម្រើស ពីរយ៉ាងគឺ ៖

-ទទួលយកការខូចខាត ដែលនឹងត្រូវបានកើតមានឡើង ដោយសុខចិត្តបដិសេធមិនព្រមប្រព្រឹត្តបទល្មើស។

-ត្រូវតែប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសការខូចខាត។[78]

ឧទាហរណ៍៖ ចោរមួយក្រុមបានវាយបំបែកសោរផ្ទះរបស់ ពូសៅ ដើម្បីធ្វើការចូលប្លន់ទ្រព្យសម្បត្តិរបស់គាត់ ដែលពូសៅកំពុងសម្រាកជាមួយក្រុមគ្រួសាររបស់គាត់ ដោយភ្លាមនោះដែរពូសៅបានដឹងខ្លួនទាន់ពេលដែលចោរមួយក្រុមនោះបានរៀបនឹងចាប់ប្រពន្ធកូនរបស់គាត់ ដើម្បីធ្វើការគំរាមយកលុយពីគាត់ ប៉ុន្តែដោយហេតុថាជាការស៊ យរបស់ចោរពូសៅបានទាញកាំបិតកាប់ទៅលើចោរនោះ ក្នុងបំណងដើម្បីការពារទៅលើអាយុជីវិតក្រុមគ្រួសារ និងទ្រព្យសម្បត្តិរបស់គាត់ពីការឈ្លានពានពីសំណាក់ក្រុមចោរមួយក្រុមនោះ ដូចនេះពូសៅមិនត្រូវបានទទួលទោសព្រហ្មទណ្ឌនោះទេ ដោយគាត់ធ្វើនេះគឺគាត់ធ្វើក្នុងស្ថានភាពចាំបាច់ដើម្បីការពារខ្លួនក្រុមគ្រួសារ និងទ្រព្យសម្បត្តិតែប៉ុណ្ណោះ។

**ក. ភាពអាសន្នគ្រោះថ្នាក់**

គ្រោះថ្នាក់ត្រូវតែមានជាក់លាក់ មានន័យថាជាគ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមានយ៉ាងពិតប្រាកដមិនមែនគ្រោះថ្នាក់ជាយថាហេតុតាមការរើយរវាយ ឬតាមការប៉ាន់ស្មានជាអត្តនោម័តរបស់ចារីឡើយ។ ហេតុដូច្នេះ

[77] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៥

[78] សៀវភៅនីតិព្រហ្មទណ្ឌទូទៅលោកគ្រូ ហ៊ាង ឡេង

ការវាយតម្លៃអំពីគ្រោះថ្នាក់ដែលនឹងកើតមានត្រូវធ្វើឡើងដោយលក្ខណៈសត្យានុម័ត មិនអាចទាញចេញពីការភ័យព្រួយបារម្ភរបស់ចារីតែម្នាក់ឯងបានឡើយ។

ជនដែលប្រព្រឹត្តបទល្មើសដោយសារតែស្ថានភាពចាំបាច់ ត្រូវតែរកភស្តុតាងអំពីគ្រោះថ្នាក់ ដែលជំរុញឱ្យមានការប្រព្រឹត្តបទល្មើស។ ដោយចារីប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសនូវរាល់គ្រោះថ្នាក់ដែលអាចកើតមានឡើងក្នុងស្ថានភាពចាំបាច់ណាមួយ។

ឧទាហរណ៍៖ ស្ត្រីម្នាក់ និងកូនប្រុសអាយុ៥ (ប្រាំ) ឆ្នាំមានស្ថានភាពក្រលំបាកដោយគ្មានអាហារឱ្យកូនបរិភោគជាច្រើនថ្ងៃ ដោយហេតុថានាងមានការបារម្ភថាខ្លាចកូនរបស់នាងប្រឈមនឹងការអត់ចំណីអាហារស្លាប់ នាងបានសម្រេចចិត្តទៅលួចអាហារពីអ្នកដទៃ ដើម្បីឱ្យកូនរបស់នាងបានហូបរួចផុតពីការអត់អាហារស្លាប់។ ក្នុងករណីនេះ គឺថាស្ត្រីដែលជាម្តាយរបស់ក្មេងប្រុសប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសគ្រោះថ្នាក់ដល់កូនរបស់នាងដែលអាចមានគ្រោះថ្នាក់ដល់ជីវិតដោយការអត់អាហារ ទើបនាងជាម្តាយប្រព្រឹត្តបទលួច។

ឧទាហរណ៍៖ មានបុរស ក ដែលត្រូវជាអ្នកជិតខាងរបស់ស្ត្រី ខ ដែលរស់នៅជាប់របងផ្ទះគ្នា ដែលស្ត្រី ខ មានមុខរបរចិញ្ចឹមឃ្មុំជាច្រើនសំបុក ហើយត្រូវបានអ្នកជិតខាងដែលជាបុរស ក បានធ្វើការដុតសំបុកឃ្មុំនោះដោយថាឃ្មុំបានទិចខ្លួន តែតាមការពិតឃ្មុំមិនបានទិចបុរស ក នោះទេ គឺជាគ្រោះថ្នាក់ជាយថាហេតុពុំមានស្ថានភាពចាំបាច់ទេ។ ដូចនេះក្នុងករណីដែលបុរស ក បានធ្វើការដុតសំបុកឃ្មុំរបស់ស្ត្រី ខ គឺត្រូវផ្តន្ទាទោសពុំមែនជាស្ថានភាពចាំបាច់ទេ។

**ខ. ការការពារជាការចាំបាច់**

ដើម្បីឱ្យមានយុត្តិកម្ម បទល្មើសដែលប្រព្រឹត្តដោយចារី ត្រូវតែជាអំពើចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ។ ត្រង់ចំណុចនេះដែលមានន័យថាការប្រព្រឹត្តបទល្មើសជាជម្រើសដ៏ប្រសើរបំផុត និងជាជម្រើសតែមួយគត់ដើម្បីបញ្ចៀសគ្រោះថ្នាក់បាន។ ស្ថិតនៅក្នុងស្ថានភាពនេះ ភាពបន្ទាន់នៃគ្រោះថ្នាក់ ជាឧបសគ្គមួយដែលធ្វើឱ្យជនរងគ្រោះអាចប្រើប្រាស់មធ្យោបាយផ្សេងៗ ក្រៅពីប្រព្រឹត្តបទល្មើសតបតទៅអ្នកឈ្លានពាន ដូចជាការប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ឬក៏រត់គេចខ្លួនជាដើម។ ឧទាហរណ៍៖ លោក ក មានទំនាស់ជាមួយលោក ខ ហើយលោក ក បានវាយលោក ខ ពីរដៃ លោក ខ ខឹងយ៉ាងខ្លាំង ក៏បានរត់ទៅយកកាំបិតនៅផ្ទះ ហើយដើររកលោក ក មួយសន្ទុះក្រោយមកលោក ខ ក៏បានចាក់លោក ក មួយកាំបិត បណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ បញ្ជូនទៅមន្ទីរពេទ្យជាបន្ទាន់ ក្នុងហេតុការណ៍ លោក ខ មិនមែនជាការចាំបាច់សម្រាប់ការពារខ្លួនដោយការការពារខ្លួនស្របច្បាប់នោះទេ។

ឧទាហរណ៍ ៖ ស្ត្រី ក ម្នាក់ចង់ឱ្យកូនរបស់ខ្លួនបានហូបនូវម្ហូបដែលមានរសជាតិឆ្ងាញ់ជាងការបរិភោគធម្មតារាល់ថ្ងៃរបស់នាង និងកូន នាងក៏បានសម្រេចចិត្តលួចសាច់គោរបស់ស្ត្រី ខ ដែលនាងបានហាលនៅក្រោយផ្ទះ

បាយរបស់នាង។ ដោយយោងតាមមាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌបានចែងថា អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ ហើយបើយោងតាមមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ បានចែងពីទោសដែលត្រូវអនុវត្តថា អំពើលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល។ ក្នុងស្ថានភាពនេះដែលស្ត្រី ក មិនអាចសំអាងថាជាភាពចាំបាច់ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ ព្រោះនេះជាការយករបស់អ្នកដទៃដោយគ្មានការអនុញ្ញាត។

**គ. វិសមាមាត្រ**

ចារីត្រូវរកភស្តុតាងមកបង្ហាញឱ្យឃើញច្បាស់ថា បទល្មើសដែលខ្លួនបានប្រព្រឹត្តមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃគ្រោះថ្នាក់។ ផលវិបាកនៃបទល្មើសត្រូវតែមានតម្លៃតិចជាង ឬស្មើនឹងតម្លៃដែលចារីមានបំណងចង់ជួយស្រោចស្រង់សង្គ្រោះ។ មធ្យោបាយសម្រាប់ប្រើប្រាស់ឆ្លើយតបទៅនឹងការការពារខ្លួនពីការឈ្លានពានដែលមិនត្រឹមត្រូវ។ ការវាយតម្លៃអំពីវិសមាមាត្រនៃមធ្យោបាយការពារ និងទម្ងន់នៃការឈ្លានពាន គឺអាស្រ័យទៅតាមករណីនីមួយៗ ដូចជាកាលៈទេសៈបុគ្គលិកលក្ខណៈរបស់អ្នកទទួលរងនូវការឈ្លានពានជាដើម។ ការការពារត្រូវតែធ្វើឡើងឱ្យ មានលក្ខណៈស្របគ្នាទៅនឹងច្បាប់បានកំណត់ គឺមានន័យថាការឈ្លានពានគឺត្រូវតែសមាមាត្រជាមួយនឹងអំពើ ដែលគេបានឈ្លានពានដោយត្រូវពិនិត្យលើទំហំគ្រោះថ្នាក់ និងចរិតលក្ខណៈនៃការឈ្លានពាននោះ។ តែប្រសិនបើមានភាពវិសមាមាត្ររវាងទម្ងន់នៃការឈ្លានពាន និងមធ្យោបាយនៃការការពារនោះគឺវាមិនមែនជាមូលហេតុដែលចៅក្រមផ្តល់នូវស្ថានសម្រាលទោសឱ្យជនល្មើសបាន។[79]

ឧទាហរណ៍៖ អំពើរបស់បើកបររថយន្តម្នាក់ដែលបានសម្រេចចិត្តបើករថយន្តរបស់គាត់ទៅប៉ះរបងរបស់ផ្ទះរបស់តតិយជន ក្នុងគោលបំណងដើម្បីធ្វើការបញ្ចៀសការប៉ះទង្គិចដល់អ្នកដំណើរថ្មើរជើងម្នាក់។ យោងតាមមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌបានចែងថា អំពើប្រព្រឹត្តដោយចេតនា ដោយបំផ្លិចបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោម ឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់អ្នកដទៃនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល លើកលែងតែការខូចខាតមានលក្ខណៈស្រាល។ ប៉ុន្តែក្នុងករណីខាងនេះដែរ គួរតែចាត់ទុកជាករណីចាំបាច់ដែលមានលក្ខណៈសមាមាត្រពីព្រោះថាអ្នកបើកបររថយន្តមិនត្រូវទទួលខុសត្រូវពីបទធ្វើឱ្យខូចខាតដោយចេតនាឡើយ ដោយគាត់គ្មានចេតនាក្នុងការបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃឡើយ គឺគាត់មានបំណងក្នុងគេចពីអ្នកដំណើរថ្មើរជើងនោះទេ។ ជាក់ស្តែងជីវិតមនុស្សថ្លៃជាងអ្វីៗទាំងអស់ ហេតុនេះគាត់ត្រូវតែរួចផុតពីការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន

[79] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៩៣

យ៉ាងពិតប្រាកដ។ គួរកត់សម្គាល់ជាចុងក្រោយថា ក្រមរដ្ឋប្បវេណីបានចែងពីស្ថានភាពផងដែរ។ កថាខណ្ឌទី២ យោងតាមមាត្រា៧៥៥ នៃក្រមរដ្ឋប្បវេណីបានកំណត់អំពីនិយមន័យ នៃពាក្យស្ថានភាពចាំបាច់ សំដៅទៅលើអំពើរំលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬអច្ចាសន្ន ហើយដែលស្ថិតក្នុងតុល្យភាពរវាងវិធីការពារ និងកម្រិតគ្រោះថ្នាក់នោះ។[80] យោងតាមខ្លឹមសារនៃបញ្ញត្តិនេះ ស្ថានភាពចាំបាច់តាមក្រមរដ្ឋប្បវេណីមិនខុសពីស្ថានភាពចាំបាច់តាមក្រមព្រហ្មទណ្ឌឡើយ។

## ២.២. កត្តាផ្សេងៗ

បន្ទាប់ពីបានពន្យល់បង្ហាញអំពីមូលហេតុ នៃការមិនទទួលខុសព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ដោយមានមូលហេតុអត្តនោម័ត និងមូលហេតុសត្យានុម័តខាងលើរួចមក។ យើងក៏បានសិក្សាស្រាវជ្រាវនឹងរកឃើញនៅចំណុចមួយចំនួននៃការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ គឺកត្តាអាយុ អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលដោយផ្អែកទៅលើបទដ្ឋានគតិយុត្តផងដែរ។

### ២.២.១. ជនមានអាយុក្រោម ១៤ ឆ្នាំ

បើយោងតាមមាត្រា៤ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន បានឱ្យនិយមន័យ អនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស។[81] នៅក្នុងក្រមព្រហ្មទណ្ឌ បានបញ្ញត្តិឱ្យតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជន ចាប់ពីអាយុ១៤ (ដប់បួន) ឆ្នាំឡើងទៅបានដែរ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ ប៉ុន្តែចំពោះជនក្រោមអាយុ១៤ (ដប់បួន) ឆ្នាំ ជាជនដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ព្រោះពួកគេមិនបានដឹងច្បាស់ថាអំពើណាខ្លះជាបទល្មើសនោះទេ។ ឪពុក ម្ដាយមិនអាចទទួលទោសជំនួសកូនបានទេនៅក្នុងរឿងព្រហ្មទណ្ឌ គឺអ្នកណាប្រព្រឹត្តអ្នកនោះជាអ្នកទទួល តែពួកគាត់នឹងចេញសំណងរដ្ឋប្បវេណីជំនួសឱ្យកូនដែលបង្កបទល្មើសនោះ។ ការយល់ដឹងគឺជាកត្តាមួយ ដ៏សំខាន់ដែលច្បាប់អាចកំណត់ពីការទទួលខុសត្រូវរបស់បុគ្គលម្នាក់ ដូច្នេះអនីតិជនដែលមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។[82] ឧទាហរណ៍៖ តារាមានអាយុ ១៣ (ដប់បី) ឆ្នាំ ជាមិត្តភក្តិរបស់ សុខា ថ្ងៃមួយពួកគេបានឈ្លោះគ្នា តារាខឹងក៏បានយកថ្មគប់ សុខា បណ្ដាលឱ្យបែកក្បាល ករណីនេះរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែឪពុក ម្ដាយត្រូវចេញមុខបកដោះស្រាយ រួមទាំងសងថ្លៃជំងឺចិត្ត និងថ្លៃព្យាបាលជំនួសកូនរបស់ខ្លួន។

[80] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា៧៥៥ កថាខណ្ឌទី២

[81] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា៤

[82] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩ កថាខណ្ឌទី២

អនីតិជនមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់ជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់។[83] ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា។ ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។

**២.២.២. បទដ្ឋានគតិយុត្ត**

ចំពោះការមិនទទួលខុសត្រូវព្រហ្មទណ្ឌ គឺដោយផ្អែកទៅលើបទដ្ឋានគតិយុត្តដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិអំពើមាត្រាមួយចំនួនដែលទាក់ទងនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌដូចជា៖

មាត្រា៥២៩-រាល់បុគ្គលណាដែលបានដឹងពីបទឧក្រិដ្ឋ ដែលអាចនឹងបង្ការ ឬបន្ថយអានុភាពរបស់បទល្មើសបាន ហើយមិនប្ដឹងបរិហារដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមាន សមត្ថកិច្ចផ្សេងទៀត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល។ ប៉ុន្តែ ត្រូវបានលើកលែងឱ្យរួចផុតពីទោស៖

១-បុព្វញាតិ និងបច្ឆាញាតិ បងប្អូនប្រុសស្រីរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតនៃបទឧក្រិដ្ឋ។

២-សហព័ន្ធរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតនៃបទឧក្រិដ្ឋ។

៣-បុគ្គលដែលច្បាប់តម្រូវឱ្យរក្សាអាថ៌កំបាំងនៃវិជ្ជាជីវៈ។

មាត្រា៥៧៤- រាល់បុគ្គលណា ក្នុងឋានៈជាចារី សហចារី អ្នកផ្ដើមគំនិត ឬជាអ្នកសមគំនិត ដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយដែលកំណត់នៅក្នុងមាត្រា៥៦១ (ទោសដែលត្រូវអនុវត្ត) និងពីមាត្រា៥៦៣ (បទគំរាមកំហែងដោយអាវុធ ឬដោយ សកម្មភាពដែលមានការព្រមព្រៀង) ដល់មាត្រា៥៧០ (ស្ថានទម្ងន់ទោស នៃអំពើជួយសម្រួលការលួចរត់ប្រព្រឹត្តដោយបុគ្គលទទួលនីតិសម្បទាឱ្យ ចូលទៅក្នុងពន្ធនាគារ) នៃក្រមនេះ នឹងត្រូវ

[83] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា១៤

លើកលែងឱ្យរួចផុតពីទោស ប្រសិនបើបុគ្គលនេះ បានឱ្យ ដំណឹង ដល់អាជ្ញាធរតុលាការ ឬអាជ្ញាធររដ្ឋបាល ដើម្បីកុំឱ្យការលួចរត់នេះបានសម្រេចលទ្ធផល។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ប្រធានបទមួយនេះ ដែលមានការទទួលខុសត្រូវជារូបវន្តបុគ្គល ហើយរូបវន្តបុគ្គលចែកចេញជាពីរ នីតិជន និងអនីតិជន។ ការសិក្សាស្រាវជ្រាវអស់រយៈពេលជាច្រើនសប្តាហ៍ រួចយើងសង្កេតឃើញថានៅពេលជនណាប្រព្រឹត្តបទល្មើស គឺមិនអាចរួចផុតពីកាទទួលខុសត្រូវព្រហ្មទណ្ឌនូវរាល់អំពើរបស់ខ្លួននៅចំពោះមុខច្បាប់នោះទេ។ ដោយការដាក់ទោស ឬមិនដាក់ទោសតាមក្រមព្រហ្មទណ្ឌបានចែង អាស្រ័យទៅលើកត្តាមួយចំនួនរបស់បុគ្គលដែលបានប្រព្រឹត្តអំពើនោះ។ ការទទួលខុសត្រូវព្រហ្មទណ្ឌមានលក្ខណៈ និងកម្រិតខុសគ្នា។ ចំពោះនីតិជនត្រូវទទួលខុសត្រូវមានលក្ខណៈធម្មតាទៅតាមច្បាប់បានកំណត់ ហើយពេលខ្លះ ការទទួលខុសត្រូវក៏មានលក្ខណៈបន្ធូរបន្ថយតាមស្ថានភាពនៃជនល្មើស ដោយការបន្ធូរបន្ថយទោសនេះដែរ ប្រសិនបើជនល្មើសមានវិបល្លាសស្មារតី ឬទទួលរងអានុភាពនៃកម្លាំង ឬការបង្ខំពីបុគ្គលណាម្នាក់ឱ្យប្រព្រឹត្តបទល្មើស។ ប្រសិនបើចារីនោះបានប្រព្រឹត្តបទល្មើសពេលដែលខ្លួនស្ថិតក្នុងភាពវិបល្លាសស្មារតីដែលសំដៅលើវិបត្តិផ្លូវចិត្តខុសប្រក្រតី ដែលធ្វើឱ្យមានភាពរឹករវដល់សកម្មភាពសរសៃប្រសាទខួរក្បាលរបស់មនុស្ស។ ចំពោះបុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលបុគ្គលនោះមិនអាចទប់ទល់បាន បុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ប៉ុន្តែការទទួលខុសត្រូវរបស់អនីតិជនវិញមានលក្ខណៈស្មុគស្មាញ ពីព្រោះថាអនីតិជន គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាណាព្យាបាលផងដែរ ពួកគេស្ថិតក្នុងវ័យកំពុងលូតលាស់ខាងបញ្ញាស្មារតី និងការគិតពិចារណា ហើយអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនទាន់ដឹងច្បាស់ថាអំពើណាខ្លះជាបទល្មើសផង។

ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាការដាក់ទោសទៅលើបុគ្គលដែលបានប្រព្រឹត្តបទល្មើស ហើយវាក៏ជាផ្នែកមួយយ៉ាងសំខាន់សម្រាប់រៀបចំនូវសណ្តាប់ធ្នាប់សង្គមឱ្យមានរបៀបរៀបរយផងដែរ។ កាលណាដែលដាក់ទណ្ឌកម្មទៅលើជនល្មើសធ្វើឱ្យជននោះមានភាពខ្លាចរអានូវទង្វើរបស់ខ្លួនបានប្រព្រឹត្ត។ ហេតុដូច្នេះហើយទើបបានជាគេបង្កើតឡើងនូវក្រមព្រហ្មទណ្ឌ ដើម្បីរក្សានូវសិទ្ធិសេរីភាពរបស់បុគ្គលដែលត្រូវបានគេរំលោភបំពានមកលើខ្លួន ដើម្បីការពារទប់ស្កាត់រាល់អំពើណាដែលមានលក្ខណៈឈ្លានពានអំពើដែលមិនត្រឹមត្រូវប៉ះពាល់ដល់អ្នកដទៃ ក៏ដូចជាផលប្រយោជន៍សង្គមជាតិផងដែរ។

សរុបមកជារួម ក្នុងអត្ថបទសារណានេះ បានផ្តោតសំខាន់លើមូលហេតុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល យើងអាចបញ្ជាក់ឃើញថារាល់អំពើដែលមិនគប្បីទាំងអស់គឺមិនមែនសុទ្ធតែទទួលខុសត្រូវព្រហ្មទណ្ឌទាំងអស់រាល់អំពើរបស់ខ្លួនបានប្រព្រឹត្តនោះឡើយ។ មានករណីលើកលែងមួយចំនួនដែលច្បាប់បានកំណត់ពាក់ព័ន្ធទៅនឹង បុគ្គលនោះមានវិបល្លាសស្មារតីពិតប្រាកដ និងជនដែលមានអាយុក្រោម១៤ឆ្នាំដែលស្ថិតក្រោមការមើលថែរបស់ឪពុកម្តាយ។ ហើយអំពើខ្លះបុគ្គលបានប្រព្រឹត្ត

ដោយមិនបានយល់ដឹងច្បាស់ថាជាអំពើល្មើសខុសច្បាប់នោះទេ អំពើខ្លះទៀតបានប្រព្រឹត្តឡើងក្នុងគោលបំណងការពារ ទប់ស្កាត់ នូវគ្រោះថ្នាក់ទាំងឡាយណាដែលបម្រុងនឹងកើតឡើងលើខ្លួនដែលពុំអាចជៀសវាងបាន ដែលគ្រោះថ្នាក់ទាំងនោះអាចប៉ះពាល់ធ្ងន់ធ្ងរដល់រូបរាងកាយ ឬអាចប៉ះពាល់ដល់អាយុជីវិតថែមទៀតផង។ ការដាក់ទណ្ឌកម្មនេះផងដែរ តុលាការប្រកាសឱ្យទណ្ឌិតទទួលខុសត្រូវនេះ គឺក្នុងគោលបំណងចង់ឱ្យបុគ្គលនោះចេះកែប្រែកំហុសដែលបានប្រព្រឹត្តល្មើសច្បាប់ និងរាងចាលដឹងពីអំពើណាខុសច្បាប់ អំពើណាស្របច្បាប់ ដើម្បីធ្វើខ្លួនចូលមករស់នៅជាពលរដ្ឋល្អក្នុងសង្គមសារជាថ្មី និងមានអនាគតល្អប្រសើរ។

# អនុសាសន៍

# អនុសាសន៍

ក្នុងនាមខ្ញុំជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែងក្នុងការរៀបចំ ចងក្រងនៅសារណាចេញជាសមិទ្ធផលដ៏ធំមួយនេះ លេចជារូបរាងយ៉ាងមានប្រយោជន៍ សម្រាប់ឱ្យនិស្សិតជំនាន់ក្រោយៗ បានស្វែងយល់បន្ថែម ដែលប្រធានបទមួយនិយាយអំពី ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល។ ចំពោះបញ្ហាគតិយុត្តនីមួយៗ ក្នុងការទាញយកហេតុផលសមស្របក្នុងការឱ្យចារីនៃអំពើ ទទួលខុសត្រូវព្រហ្មទណ្ឌ ឬរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយអាស្រ័យតាមស្ថានភាពជាក់ស្តែងរបស់ចារី ហើយច្បាប់ពិតជាបានអនុញ្ញាតឱ្យបុគ្គល ដែលបានប្រព្រឹត្តបទល្មើសណាមួយដែលតុលាការបានវិនិច្ឆ័យថាបទល្មើសនោះមានហេតុផលសមស្រប ដែលអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌក៏ពិតមែន ប៉ុន្តែរាជរដ្ឋាភិបាល គួរតែត្រួតពិនិត្យ និងចាត់វិធានការតាមដានបន្ថែមលើបញ្ហាគតិយុត្តខាងលើនេះ ដើម្បីទប់ស្កាត់រាល់បទល្មើស ដែលបម្រុងកើតឡើងជារៀងរាល់ថ្ងៃ។ តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើកន្លងមក បានទទួលនូវការយល់ដឹងពីប្រធានបទនេះកាន់តែច្បាស់ថែមមួយកម្រិតទៀត។

ជាចុងក្រោយយើងខ្ញុំសំណូមពរទៅដល់អ្នកសិក្សា និស្សិត ទាំងអស់ គួរតែខំខិតសិក្សាឱ្យបានច្បាស់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ឱ្យបានច្បាស់ជាមុនសិនមុននឹងសម្រេចចិត្តប្រព្រឹត្តអំពើអ្វីមួយ មុននឹងប្រព្រឹត្តត្រូវដឹងថាអំពើណាត្រឹមត្រូវ អំពើណាមិនត្រឹមត្រូវដែលក្រមព្រហ្មទណ្ឌបានហាមឃាត់ ព្រោះវាបានជួយទប់ស្កាត់ និងកាត់បន្ថយនូវរាល់បទល្មើសទាំងឡាយដែលធ្វើឱ្យសង្គមជាតិមានភាពអសន្តិភាព ប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ និងប៉ះពាល់ផលប្រយោជន៍អ្នកដទៃ។ សំណូមពរដល់បណ្តាប្រជាពលរដ្ឋទាំងអស់ មេត្តាព្យាយាមសិក្សាស្វែងយល់ អំពីច្បាប់ដែលរាជរដ្ឋាភិបាល បានដាក់ចេញ និងត្រូវតែទទួលយក និងជួយគ្នាអនុវត្តទាំងអស់គ្នាដើម្បីធានាឱ្យច្បាប់មួយមាននិរន្តរភាព និងជួយឱ្យប្រទេសកម្ពុជាក្លាយទៅជានីតិរដ្ឋយ៉ាងពិតប្រាកដ។ ដូច្នេះក្នុងនាមយើងជានិស្សិតផ្នែកច្បាប់ យើងគួរគប្បីចែករំលែកនូវចំណេះដឹងដែលយើងបានសិក្សាកន្លងតាមរយៈការចងក្រងជាសារណាដល់សិស្សប្អូនបានសិក្សាបន្ត និងចូលរួមការផ្សព្វផ្សាយអំពីក្រមព្រហ្មទណ្ឌ និងប្រធានបទអំពីសារណាដែលបានស្រាវជ្រាវនេះ ចែករំលែកឱ្យបានទូលំទូលាយទៅដល់សាធារណជនដើម្បីឱ្យយល់ដឹងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌ របស់រូបវន្តបុគ្គលឱ្យកាន់តែច្បាស់លាស់ ព្រោះភាពរីកចម្រើននិងសន្តិភាពកើតឡើងដោយសារគ្មានបទល្មើសក្នុងសង្គមជាតិផងដែរ។

# ឯកសារយោង

# ឯកសារយោង

## ១.ច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមរដ្ឋប្បវេណី ប្រកាសឱ្យនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៦
- ច្បាប់ស្តីពីពន្ធនាគារ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១។

## ២.សៀវភៅ

- នីតិព្រហ្មទណ្ឌទូទៅ, ជួន ប៊ុនធី (ឆ្នាំ ២០១០)
- នីតិព្រហ្មទណ្ឌទូទៅ, ហ៊ាង ឡេង (ឆ្នាំ ២០១០)
- នីតិព្រហ្មទណ្ឌទូទៅ, ហ៊ី សោភា
- នីតិព្រហ្មទណ្ឌទូទៅ, កៅ សីហា (ភ្នំពេញ៖ អង្គរ, ២០១៣)
- នីតិព្រហ្មទណ្ឌទូទៅ, រុន ពណ្ណារិទ្ធ, កែសម្រួលដោយ លោកស្រី ចាំង ស៊ីណាត (ភ្នំពេញ៖ ២០១២)
- សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនៃកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ
- កតិកាសញ្ញាអន្តរជាតិស្តីពីពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦
- សេចក្តីថ្លែងការណ៍ស្តីពីអំពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិមនុស្សរបស់បារាំង ឆ្នាំ១៧៨៩
- សំណួរ-ចម្លើយសម្រាប់ការត្រៀមប្រឡងផ្សេងៗរៀបចំដោយបណ្ណាគារភក្តីឡដ៏។
- សៀវភៅស្តីពីការអនុវត្តសម្រាប់សិក្ខាកាមនីតិសាស្ត្រ

## វចនានុក្រម និងសទ្ទានុក្រម

១. វចនានុក្រមខ្មែរសម្តេចសង្ឃរាជ ជួន ណាត ចេញផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត ឆ្នាំ ១៩៦៧

២. សទ្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ ចេញផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១

# ឧបសម្ព័ន្ធ

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា

# ជំពូកទី ១២ ថ្មី
# អំពីក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ១៣៦.- ថ្មី**

*ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារ ការគោរពរដ្ឋ-ធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។*

*ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យនិងសម្រេចអំពីករណីវិវាទ-កម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។*

**មាត្រា ១៣៧.- ថ្មី (មាត្រា ១១៨ ចាស់)**

*ក្រុមប្រឹក្សាធម្មនុញ្ញ មានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ប្តូរក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង ។ សមាជិកបីរូប ត្រូវតែងតាំងដោយ*

# ក្រមព្រហ្មទណ្ឌ

# ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# គន្ថីទី ១
# បទប្បញ្ញត្តិទូទៅ
# មាតិកាទី ១
# ច្បាប់ព្រហ្មទណ្ឌ
# ជំពូកទី ១
# គោលការណ៍ទូទៅ

**មាត្រា ១.-** ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ

ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថា ជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ ។

នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។

**មាត្រា ២.-** និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស

ច្បាប់បញ្ញត្តថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស ។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ ។

**មាត្រា ៣.-** គោលការណ៍នីត្យានុកូលភាព

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។

មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន ។

**មាត្រា ៤.-** ចេតនាប្រព្រឹត្តបទល្មើស

ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។

ប៉ុន្តែ ក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពី ការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែក ណាមួយ ។

**មាត្រា ៥.–** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីក វិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ ។

**មាត្រា ៦.–** ការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះ មិនត្រូវបានប្រកាសដោយតុលាការទេ ។

**មាត្រា ៧.–** លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ដែនអនុវត្តច្បាប់កម្ពុជាក្នុងលំហ ត្រូវបានកំណត់ដោយ បទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៨.–** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ

បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធ ចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទង ដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ ។

## ជំពូកទី ២

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

**មាត្រា ៩.–** ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស

បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។ អំពើ ដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀត ឡើយ ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ ត្រូវបញ្ចប់ ។

ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះ មិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត ។

**មាត្រា ១០.–** ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬធ្ងន់ជាង

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម ។ ប៉ុន្តែ ការផ្តន្ទាទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ។

**មាត្រា ១១.–** សុពលភាពនៃកិច្ចនីតិវិធី

ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធីដែលបានបំពេញស្របតាមបទប្បញ្ញត្តិចាស់ឡើយ ។

## ជំពូកទី ៣
## ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ
### ផ្នែកទី ១
### បទល្មើសដែលបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១២.–** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៣.–** ទីកន្លែងប្រព្រឹត្តបទល្មើស

បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅ

## មាតិកាទី ២
## ការទទួលខុសត្រូវព្រហ្មទណ្ឌ
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៤.–** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។



**មាត្រា ២៥.–** និយមន័យនៃចារី

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។

ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ។

**មាត្រា ២៦.–** និយមន័យនៃសហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ។

ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ។

**មាត្រា ២៧.–** និយមន័យនៃការប៉ុនប៉ង

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង

-ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស មិនមែនជាការចាប់ផ្តើមអនុវត្តទេ ។

ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ ។

**មាត្រា ២៨.–** និយមន័យនៃអ្នកផ្តើមគំនិត

ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែល :

១-ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ តាមការណែនាំ ឬការបញ្ជា។

២-បង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន ។

អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវ បានសម្រេច ឬបានប៉ុនប៉ង ។

អ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ ។

**មាត្រា ២៩.-** និយមន័យនៃអ្នកសមគំនិត

ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណា ដែលជួយសម្រួល ដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន ។

អ្នកសមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវ បានសម្រេច ឬបានប៉ុនប៉ង ។

អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ ។

**មាត្រា ៣០.-** និយមន័យនៃអ្នករាជការសាធារណៈ ពលរដ្ឋទទួលអាណត្តិ សាធារណៈដោយការបោះឆ្នោត

១-អ្នករាជការសាធារណៈ មានន័យថា :

ក/ បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជា អចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពី ឋានៈ អាយុរបស់បុគ្គលនោះឡើយ ។

ខ/ បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារ សាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែល មានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

២-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថា ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

## ជំពូកទី ២
## មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

**មាត្រា ៣១.-** ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**មាត្រា ៣២.-** ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះ មិនប្រព្រឹត្តបទល្មើសទេ ។

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

**មាត្រា ៣៣.-** ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

**មាត្រា ៣៤.-** សច្ចធារណីនៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណីនៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណីនេះ អាចត្រូវរំលាយដោយភស្តុតាងផ្ទុយ ។

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

**មាត្រា ៣៩.-** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។

**មាត្រា ៤០.-** ប្រភេទនៃវិធានការ

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មាន ដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

# ផ្នែកទី ២
## ទោសបន្ថែម

**មាត្រា ៥៣.-** ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបាន ប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការព្យួរលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។



៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្ត បទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែល បទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហ សម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត ។

**មាត្រា ៩៥.-** ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស

កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារ ក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ ។

## ជំពូកទី ៣
## របបនៃការប្រកាសទោស
### ផ្នែកទី ១
### របបទូទៅ

**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស

តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ ។

**មាត្រា ៩៧.-** ការប្រកាសមូលទោស

នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស :

-ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ

-ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

-ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

**មាត្រា ៩៨.-** ការប្រកាសទោសជំនួស

ទោសការងារសហគមន៍ជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

ការស្តីបន្ទោសជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសការស្តីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស

កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះ ចេញ ។

**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម

តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោម :

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ ។

**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ ។ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា ។

**មាត្រា ១០២.-** ចិរវេលា និងអំឡុងពេលនៃការងារសហគមន៍

តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីចិរវេលានៃ

# ជំពូកទី ៦
# ទោសដែលអាចអនុវត្តចំពោះអនីតិជន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបាន បន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើ អប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមាន អានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែ ថិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល

បទប្បញ្ញត្តិស្តីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោស លើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

# គន្ថីទី ២
# បទល្មើសប្រឆាំងនឹងបុគ្គល
## មាតិកាទី ១
## បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម
### ជំពូកទី ១
### បទឧក្រិដ្ឋប្រល័យពូជសាសន៍

**មាត្រា ១៨៣.-** បទឧក្រិដ្ឋប្រល័យពូជសាសន៍

បទឧក្រិដ្ឋប្រល័យពូជសាសន៍ គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា :

១-ឃាតកម្មលើសមាជិកនៃក្រុម ។

២-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬសតិបញ្ញារបស់សមាជិកនៃក្រុម ។

៣-ការដាក់ឱ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខណ្ឌ ដែលនាំឱ្យវិនាសអន្តរាយទាំងស្រុង ឬមួយផ្នែកនៃក្រុម ។

៤-វិធានការដោយបង្ខំ ឬមធ្យោបាយដោយមិនបង្ខំ សំដៅរារាំងកំណើតទារកនៅក្នុងក្រុម ។

៥-ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។

**មាត្រា ១៨៤.-** ទោសដែលត្រូវទទួល

បទឧក្រិដ្ឋប្រល័យពូជសាសន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ១៨៥.-** បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍

ការចូលរួមក្នុងក្រុមណាមួយដែលបង្កើតឡើង ឬចូលរួមក្នុងសន្និដ្ឋិភាពដែលធ្វើឡើងដើម្បីរៀបចំអំពើឧក្រិដ្ឋប្រល័យពូជសាសន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

ការត្រៀមរៀបចំត្រូវមានលក្ខណៈសំគាល់ដោយអំពើជាក់ស្តែងមួយឬច្រើន ។

## ជំពូកទី ២
## បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

**មាត្រា ១៨៨.-** បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅ ឬជាប្រព័ន្ធ សំដៅប្រឆាំងប្រជាជនស៊ីវិល :

១-ឃាតកម្ម ។

២-ការសម្លាប់រង្គាល ។

៣-ការធ្វើឱ្យទៅជាទាសករ ។

៤-ការនិរទេស ឬជម្លៀសប្រជាជនដោយបង្ខំ ។

៥-ការដាក់ពន្ធនាគារ ឬគ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបំពានទៅលើបទប្បញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ ។

៦-ការធ្វើទារុណកម្ម ។

៧-ការចាប់បង្ខំសេពសន្ថវៈ ការធ្វើទាសកម្មខាងផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគភ៌ដោយបង្ខំ វណ្ឌកម្មដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀតនៃអំពើហិង្សាខាងផ្លូវភេទ ដែលមានទម្ងន់ប្រហាក់ប្រហែលគ្នា ។

៨-ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសមូហភាពដោយមូលហេតុនយោបាយ ពូជសាសន៍ ក្រុមជាតិ ជាតិពន្ធុ វប្បធម៌ សាសនា ឬភេទ ។

៩-ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ។

១០-ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍ជាប្រព័ន្ធតាមបែបអាប៉ាថេដ ។

១១-គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយ ។

**មាត្រា ១៨៩.-** ទោសដែលត្រូវទទួល

បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ជំពូកទី ៣
## បទឧក្រិដ្ឋសង្គ្រាម

**មាត្រា ១៩៣.-** បទឧក្រិដ្ឋសង្គ្រាម

បទឧក្រិដ្ឋសង្គ្រាម គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនោះត្រូវបានប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិដែលការពារដោយអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ :

១-ឃាតកម្ម ។

២-ទារុណកម្ម ឬគ្រប់អំពើអមនុស្សធម៌ រួមបញ្ចូលទាំងការពិសោធជីវសាស្ត្រ ។

៣-អំពើបង្កដោយចេតនានូវការឈឺចាប់ ឬដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បូរណភាពខាងរូបកាយ ឬសុខភាព ។

៤-ការបំផ្លាញ ឬការធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយគ្មានហេតុផលចាំបាច់ខាងយោធា និងក្នុងទ្រង់ទ្រាយធំដោយខុសច្បាប់ និងតាមទំនើងចិត្ត ។

៥-អំពើបង្ខំឈ្លើយសឹក ឬជនស៊ីវិល ឱ្យបម្រើក្នុងកងកម្លាំងប្រដាប់អាវុធរបស់សត្រូវ ។

៦-អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬជនស៊ីវិល ក្នុងការទទួលការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតលំអៀង ។

៧-ជម្លៀស ការបញ្ជូន ឬការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ ។

៨-ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង ។

**មាត្រា ១៩៤.-** បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត

អំពើណាមួយដូចមានចែងខាងក្រោមនេះ គឺជាបទឧក្រិដ្ឋសង្គ្រាមដែរ កាលបើ អំពើនោះ ត្រូវបានប្រព្រឹត្តក្នុងឱកាសជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ ឬមិនមែនអន្តរជាតិ :

១-ការប្រើប្រាស់អាវុធដែលមានជាតិពុល ឬអាវុធដែលស្ថាបនាឡើងដើម្បីបង្កការឈឺចាប់ឥតប្រយោជន៍ ។

២-អំពើវាយប្រហារ ឬទម្លាក់គ្រាប់បែកដោយចេតនា តាមមធ្យោបាយណាក៏ដោយទៅលើទីក្រុង ភូមិ ទីកន្លែងរស់នៅ ឬអគារដែលមិនមានការការពារ និងដែលមិនមែនជាកម្មវត្ថុខាងយោធា ។

៣-អំពើវាយប្រហារដោយចេតនាទៅលើមនុស្ស ឬសម្ភារៈដែលប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃបេសកកម្មមនុស្សធម៌ ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ។

៤-អំពើបង្កគ្រោះទុរ្ភិក្សដោយចេតនា ដល់ប្រជាជនស៊ីវិល ដោយដកហូតនូវទ្រព្យសម្បត្តិចាំបាច់សម្រាប់បន្តការរស់រានមានជីវិតរបស់ជនស៊ីវិលទាំងនេះ ។

៥-អំពើប្រើប្រាស់ជនស៊ីវិល ដើម្បីបញ្ចៀសពីគោលដៅនៃប្រតិបត្តិការយោធាទៅលើអគារខ្លះ តំបន់ខ្លះនៃដែនដី ឬកងកម្លាំងយោធាខ្លះ ។

៦-អំពើបំផ្លាញ ឬធ្វើឱ្យខូចខាតដោយចេតនា នូវអគារសម្រាប់សាសនា សប្បុរសធម៌ អប់រំ សិល្បៈ និងវិទ្យាសាស្ត្រ វិមានប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈ ឬស្នាដៃដែលមានលក្ខណៈវិទ្យាសាស្ត្រ ។

៧-អំពើបង្កដល់បរិស្ថានធម្មជាតិ នូវការខូចខាតដ៏ធំ យូរអង្វែង និងធ្ងន់ធ្ងរដែលមានលក្ខណៈហួសហេតុយ៉ាងជាក់ស្តែង បើប្រៀបទៅនឹងផលប្រយោជន៍ពិតប្រាកដ និងផ្ទាល់ ខាងផ្នែកយោធាដែលសង្ឃឹមទុក ។

៨-ការលួចប្លន់សម្បត្តិសាធារណៈ ឬឯកជន ។

**មាត្រា ១៩៥.-** ទោសដែលត្រូវទទួល

បទឧក្រិដ្ឋសង្គ្រាម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

## ជំពូកទី ៣
## ការបំពានខាងផ្លូវភេទ
### ផ្នែកទី ១
### ការរំលោភសេពសន្ថវៈ

**មាត្រា ២៣៩.-** បទរំលោភសេពសន្ថវៈ

គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្មក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ ។

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

**មាត្រា ២៤០.-** ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងជនល្មើស

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើង :

១-ដោយការប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ ។

២-ដោយការប្រើគ្រឿងញៀន ឬគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់ ។

៣-ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ ។

៤-ដោយបុគ្គលដែលរំលោភអំណាចដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ ។

៥-ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ។

**មាត្រា ២៤១.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ

១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

**មាត្រា ២៤២.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះនាំឱ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**មាត្រា ២៤៣.-** ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ ។

**មាត្រា ២៤៤.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់។

**មាត្រា ២៤៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ខាត ដោយអ្នកដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល នោះ ដោយយោងទៅតាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូលបានឡើយ ។

## ផ្នែកទី ៣
## សមត្ថភាពខាងឆន្ទៈ

**មាត្រា ១៤.–** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

**មាត្រា ១៥.–** និយមន័យនៃសកម្មភាព

ពាក្យ “សកម្មភាព” ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

## ផ្នែកទី ៤
## សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.–** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

### កថាភាគទី ១
### អនីតិជន

**មាត្រា ១៧.–** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ៧៥៤.–** អំពើអនីត្យានុកូលរួម

១-បើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពាននីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពាននីមួយៗបានបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាត ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត តាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទទួលស្គាល់ថាមានការសមគំនិត ឬ មានទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកប្រព្រឹត្តអំពើបំពាន ។

៣-បើជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម បានសងការខូចខាតទាំងអស់ ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀតដែលប្រព្រឹត្តអំពើអនីត្យានុកូលរួមនោះបាន តាមសមាមាត្រនៃភាគដែលជនម្នាក់ៗបានបង្ក ។

**មាត្រា ៧៥៥.–** និយមន័យនៃការការពារជាធម្មានរូប និង ស្ថានភាពចាំបាច់

១-អំពើការពារជាធម្មានរូប សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបានដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និង អំពើវិលោភនោះ ស្ថិតជិតគ្នា និង មានតុល្យភាពរវាងវិធីការពារនិងកម្រិតនៃអំពើបំពាននោះ ។

២-អំពើដោយសារស្ថានភាពចាំបាច់ សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ឆាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាព រវាងវិធីការពារ និង កម្រិតគ្រោះថ្នាក់នោះ ។

**មាត្រា ៧៥៦.–** មូលហេតុនៃការរួចផុតពីភាពផ្ទុយច្បាប់

១-អ្នកប្រព្រឹត្តអំពើបំពានត្រូវរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការ

# ច្បាប់

# ស្តីពី

# យុត្តិធម៌អនីតិជន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលបំណង

ច្បាប់នេះមានគោលបំណង៖

- ជានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស
- គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍
- ជានាការពារផលប្រយោជន៍សង្គមនិងសហគមន៍ ។

### មាត្រា ២.- គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន ។

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងច្បាប់ដោយឡែកផ្សេងទៀត ត្រូវយកមកអនុវត្ត លើកលែងតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់នេះ ។

### មាត្រា ៣.- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើករណីអនីតិជនប្រព្រឹត្តបទល្មើស ។

### មាត្រា ៤.- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

១- យុត្តិធម៌អនីតិជន សំដៅដល់ការការពារសិទ្ធិអនីតិជនតាមរយៈយន្តការ វិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងអនុវត្តដោយហ្មត់ចត់ ព្រមទាំងវិធាននៃការកំណត់ទោសក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស ។

២- អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់បុគ្គល ឬស្ថាប័នដែលអនុវត្តដោយស្របច្បាប់នូវមុខងាររបស់ខ្លួនដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជន ។

៣- អនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៤- អនីតិជនត្រូវការកិច្ចការពារ និងថែទាំ សំដៅដល់អនីតិជនដែលត្រូវការកិច្ចការពារ និងថែទាំ ដោយមូលហេតុអនីតិជននោះគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬគ្មានការថែទាំ និងគ្រប់គ្រងត្រឹមត្រូវពីសំណាក់អ្នកតំណាងដែលច្បាប់បានកំណត់ ហើយកំពុងប្រឈមនឹងសភាពគ្រោះថ្នាក់ ឬរងការរំលោភបំពាន ឬបង្ហាញការគំរាមកំហែងដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន ។

៥- អ្នកតំណាងដែលច្បាប់បានកំណត់ សំដៅដល់អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ ។

៦- អ្នកទំនុកបម្រុង សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវបានជ្រើសរើសដោយអនីតិជន ឬដោយអាជ្ញាធរមានសមត្ថកិច្ច និងមានការយល់ព្រមពីអនីតិជនឲ្យទទួលខុសត្រូវក្នុងការទំនុកបម្រុងខ្លួនក្នុងអំឡុងពេលអនុវត្តនីតិវិធីដែលមានចែងក្នុងច្បាប់នេះ ។

៧- នីតិវិធីកុមារមេត្រី សំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ព័ន្ធនឹងការលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្តី តាមរយៈការប្រើប្រាស់ភាសានិងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និងក្នុងបរិយាកាសដែលផ្តល់ឲ្យអនីតិជននូវសុវត្ថិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន ។

៨- របាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន សំដៅដល់របាយការណ៍ស្តីពីស្ថានភាពទូទៅរបស់អនីតិជន និងការផ្តល់យោបល់វាយតម្លៃផ្សេងៗដែលធ្វើឡើងដោយភ្នាក់ងារសង្គមកិច្ច ។

៩- ភ្នាក់ងារសង្គមកិច្ច សំដៅដល់មន្ត្រីរបស់ក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាលជំនាញផ្នែកកុមារ និងច្បាប់ពាក់ព័ន្ធនឹងអនីតិជន ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១០- មណ្ឌលយុវនីតិសម្បទា សំដៅដល់មណ្ឌលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ផ្តល់សេវាការពារ ថែទាំ អប់រំ ស្តារនីតិសម្បទា និងសមាហរណកម្មដល់អនីតិជន ។

# ជំពូកទី ២
# គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន

## មាត្រា ៥.- គោលការណ៍ជាមូលដ្ឋាន

គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវជានាឲ្យមានការគោរពគោលការណ៍ដូចតទៅ ៖

- ត្រូវយកចិត្តទុកដាក់ និងពិចារណាពល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា
- ត្រូវប្រព្រឹត្តប្រកបដោយមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរទៅលើអនីតិជន
- ត្រូវផ្តល់ឱកាសឲ្យអនីតិជនសម្តែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន
- ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្តន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន
- មិនត្រូវរើសអើងចំពោះអនីតិជន មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ឋានៈសង្គម ធនធាន ដើមកំណើតជាតិ និន្នាការនយោបាយ ឬស្ថានភាពឯទៀត
- មិនត្រូវប្រើខ្នោះ និងឧបករណ៍ផ្សេងៗទៀតដែលប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់អនីតិជន លើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះដែលវិធានការទាំងឡាយមិនអាចអនុវត្តបាន ឬគ្មានប្រសិទ្ធភាព
- មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក តាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជន
- មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អនីតិជន និងដែលនាំឲ្យបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព ។ ការផ្សព្វផ្សាយរឿងក្តីអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជ-អាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ
- សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

## មាត្រា ៦.- សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ។

# ជំពូកទី ៣

# ការទទួលខុសត្រូវព្រហ្មទណ្ឌ និងវិជ្ជបូវេណីរបស់អនីតិជន

## មាត្រា ៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

## មាត្រា ៨._ ការទទួលខុសត្រូវរដ្ឋប្បវេណី

បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៧៤៥ (អសមត្ថភាពក្នុងការទទួលខុសត្រូវ) និងមាត្រា ៧៤៦ (ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ) នៃជំពូកទី ១៦ (អំពើអនីត្យានុកូល) ក្នុងគន្ថីទី ៥ (កិច្ចសន្យាសំខាន់ៗ និងអំពើអនីត្យានុកូល)នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការទទួលខុសត្រូវរដ្ឋប្បវេណីរបស់អនីតិជន ។

## មាត្រា ៩._ ការកំណត់អាយុ

អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ។

កស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត ។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន ។

ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ ។

# ជំពូកទី ៤
# ជំនួយផ្នែកសេវាសង្គមកិច្ច

## មាត្រា ១០._ ការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច

ការតែងតាំង ការទទួលស្គាល់ និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ចជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

បែបបទនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។

## មាត្រា ១១._ ភ្នាក់ងារសង្គមកិច្ច

ភ្នាក់ងារសង្គមកិច្ចមានភារកិច្ចជាអាទិ៍ ៖

- ជួបអនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី ជាពិសេស នៅដំណាក់កាលដំបូងនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ និងនៅក្នុងពន្ធនាគារ ដើម្បីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាបន្ទាន់ដល់អនីតិជន

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នក តំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

## មាត្រា ១៤.- នីតិវិធីទាក់ទងនឹងអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ

អនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

គ្រប់អំពើដែលជាបទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

## មាត្រា ៤៩.- ការឲ្យរួចផុតពីបទចោទ

ក្នុងករណីតុលាការរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឲ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឲ្យដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ ទោះបីមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីតុលាការរកឃើញថាអនីតិជនខាងលើពិតជាបានប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី ប្រសិនបើមានបណ្ដឹងរដ្ឋប្បវេណី ។

ប្រសិនបើតុលាការរកឃើញថា អំពើដែលចោទប្រកាន់មកលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនមែនជាបទល្មើស ឬអនីតិជនជាប់ចោទគ្មានកំហុសទេ តុលាការត្រូវសម្រេចឲ្យរួចខ្លួនពីបទចោទ និងបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ប្រសិនបើអនីតិជននោះមិនត្រូវបានជាប់ឃុំពីបទល្មើសផ្សេងទៀតទេ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

## មាត្រា ៥០.- ជំនួយរបស់មេធាវី

ជំនួយរបស់មេធាវីត្រូវតែមានជាចំខាតនៅក្នុងសវនាការ ។ បើគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃតាមគំនិតផ្ដើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ។ សោហ៊ុយសម្រាប់ធ្វើការ ចម្លងសំណុំរឿងជាបន្ទុករបស់រដ្ឋ ។

តុលាការត្រូវផ្ដល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿង ទៅឲ្យមេធាវីសម្រាប់រៀបចំការពារក្ដី ។ សោហ៊ុយសម្រាប់ធ្វើការចម្លងសំណុំរឿងជាបន្ទុករបស់មេធាវីដែលត្រូវបានជ្រើសរើសដោយអនីតិជន ។

# ច្បាប់
# ស្ដីពី
# ពន្ធនាគារ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/១២១១/០២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីពន្ធនាគារ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលបំណងកំណត់អំពីការគ្រប់គ្រងពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលដៅដូចតទៅ :

- អប់រំ កែប្រែ ស្តារនីតិសម្បទា ដើម្បីធ្វើសមាហរណកម្មជនជាប់ឃុំទៅក្នុងសង្គមវិញ និង ទប់ស្កាត់ការប្រព្រឹត្តបទល្មើសសាជាថ្មី
- គ្រប់គ្រងជនជាប់ឃុំឲ្យបានសន្តិសុខ សុវត្ថិភាព សុខភាព និង មនុស្សធម៌ ស្របតាមគោលការណ៍អន្តរជាតិ និង វិធានសហប្រជាជាតិ សម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តលើពន្ធនាគារទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែពន្ធនាគារយោធា ឬកន្លែងឃាត់ខ្លួនរបស់នគរបាលយុត្តិធម៌ ឬមណ្ឌលឃុំខ្លួនដទៃទៀត ដែលកំណត់ដោយច្បាប់ផ្សេង ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

**ពន្ធនាគារ** សំដៅដល់កន្លែងប្រើសម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផង ។

**អនីតិជន** សំដៅដល់បុគ្គលទាំងឡាយណា ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ឡើង ដល់ក្រោម ១៨ ឆ្នាំ ។

**ជនជាប់ឃុំ** សំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិតដែលត្រូវបានបញ្ជូនមកឃុំខ្លួននៅក្នុងពន្ធនាគារ តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ ។

**មន្ត្រីពន្ធនាគារ** សំដៅដល់មន្ត្រីដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ។